ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
東埔寨郵政銀行 CAMBODIA POST BANK PLC.

របាយការណ៍ប្រចាំឆ្នាំ ២០១៩

មាតិកា

ព័ត៌មានអំពីធនាគារ

- ប្រវត្តិរបស់ធនាគារ ៤
- ភាគទុនិក ៥
- ចក្ខុវិស័យ និងបេសកកម្ម ៦
- ក្រមសីលធម៌វិជ្ជាជីវៈ ៦
- តម្លៃស្នូល "RICE" ៧
- ប្រវត្តិជោគជ័យរបស់ធនាគារ ៨
- បណ្តាញប្រតិបត្តិការ ១០
- អភិបាលកិច្ចសាជីវកម្ម ១៤
- ការគ្រប់គ្រងហានិភ័យ ១៧
- ការប្រតិបត្តិតាម ១៩

ការដឹកនាំ

- សមិទ្ធផលសម្រេចបាន (របាយការណ៍រូប) ២០
- រចនាសម្ព័ន្ធអង្គភាព ២២
- សេចក្តីថ្លែងការណ៍ពីប្រធានក្រុមប្រឹក្សាភិបាល ២៤
- សេចក្តីថ្លែងការណ៍ពីប្រធាននាយកប្រតិបត្តិ ២៦
- ក្រុមប្រឹក្សាភិបាល ២៨
- គណៈគ្រប់គ្រង ៣២

ព្រឹត្តិការណ៍សំខាន់ៗ

- ព្រឹត្តិការណ៍សំខាន់ៗ ៣៦
- ការចូលរួមចំណែកក្នុងសង្គម ៣៨
- ប្រវត្តិអតិថិជនជោគជ័យ ៣៩

របាយការណ៍ហិរញ្ញវត្ថុ ៤២

អំពីធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ជាធនាគារពាណិជ្ជដ៏ធំមួយក្នុងចំណោមធនាគារពាណិជ្ជល្បីៗឈានមុខគេនៅប្រទេសកម្ពុជា ដែលត្រូវបានបង្កើតឡើងក្នុងខែកញ្ញា ឆ្នាំ២០១៣ ដែលមានដៃគូយុទ្ធសាស្ត្ររវាង កាណាឌីយ៉ា អ៊ីនវេសមិនហូលឌីង ប្រៃសណីយ៍កម្ពុជា នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា និងហ្វូឡឹតុន ហ្វាយណាន់ស៊ល្យហូលឌីង។

ធនាគារមានសន្ទុះនៃការអភិវឌ្ឍន៍ និងរីកចម្រើនយ៉ាងខ្លាំងគិតត្រឹមរយៈពេលជាង ៦ឆ្នាំចុងក្រោយនេះ ដោយធនាគារមានចក្ខុវិស័យក្លាយខ្លួនជាធនាគារពាណិជ្ជឈានមុខគេនៅកម្ពុជាដែលផ្តល់សេវាហិរញ្ញវត្ថុជូនអតិថិជនគ្រប់កម្រិតដើម្បីលើកកម្ពស់ជីវភាព និងជួយបំពេញបំណងនៃភាពរីកចម្រើនរបស់ប្រជាជនកម្ពុជា ហើយបង្កើតតម្លៃជានិរន្តរ៍ដល់ភាគទុនិក បុគ្គលិក និងសង្គមផងដែរ។

ចាប់ផ្តើមពីការបង្កើតឡើងដំបូង ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានចុះបញ្ជីដើមទុន ៣៨លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ដែលបានកើនឡើងរហូតដល់ ៥៨លានដុល្លារអាមេរិកក្នុងខែមករា ឆ្នាំ២០១៧។ ធនាគារបានបង្កើនដើមទុនរហូតដល់៧០.៧៩លានដុល្លារអាមេរិកក្នុងខែកញ្ញា ឆ្នាំ២០១៧ និងបង្កើនដើមទុនរហូតដល់ ៧៦លានដុល្លារអាមេរិក ដើម្បីឆ្លើយតបទៅនឹងបទប្បញ្ញត្តិថ្មីរបស់ធនាគារជាតិនៃកម្ពុជា ក្នុងខែមីនា ឆ្នាំ២០១៨។

ធនាគារតែងតែឈានមុខគេ ក្នុងការផ្តល់បច្ចេកវិទ្យាហិរញ្ញវត្ថុបែបទំនើបកម្មដើម្បីផ្តល់នូវបទពិសោធន៍ថ្មីៗជូនអតិថិជនឱ្យកាន់តែងាយស្រួល និងកាន់តែប្រសើរឡើងក្នុងការប្រើប្រាស់ផលិតផល និងសេវាកម្មរបស់ធនាគារ។ ក្នុងឆ្នាំ២០១៩នេះ ធនាគារបានពង្រីកនូវវឌ្ឍនភាពជាមួយនឹងបណ្តាញប្រតិបត្តិការសាខាចំនួន ៥១ ម៉ាស៊ីនអេធីអឹម ៦០កន្លែង និងបុគ្គលិកបម្រើការងារ ១,៥៨៥នាក់សម្រាប់បម្រើសេវាកម្មជូនអតិថិជន។ នៅក្នុងឆ្នាំ២០១៩ ធនាគារបានដាក់ដំណើរការ សេវាធនាគារ ៣៦៥ថ្ងៃ ចំនួន៣សាខារួមមាន សាខាការិយាល័យកណ្តាល សាខាអូឡាំពិក សាខាសែនសុខ (ផ្សារទំនើបអ៊ីអនសែនសុខ) ការដាក់ដំណើរការប័ណ្ណវីសា ការពង្រីកវិសាលភាពនៃការទូទាត់នៃ **QR Scan** តាមរយៈសេវាធនាគារចល័ត ប្រព័ន្ធអនុម័តឥណទានដោយស្វ័យប្រវត្តិ ទាំងនេះជាគំនិតផ្តួចផ្តើមថ្មីមួយរបស់យើងសម្រាប់ឆ្នាំ២០១៩។

ក្នុងឆ្នាំ២០២០ ធនាគារនឹងអនុវត្តប្រព័ន្ធគ្រប់គ្រងការប្រមូលឥណទានដើម្បីសម្រួលដល់ការប្រមូលឥណទានស្វ័យប្រវត្តិកម្ម។ ធនាគារនឹងដាក់ឱ្យដំណើរការនូវប្រព័ន្ធបើកគណនីអនឡាញ និងប្រព័ន្ធស្នើសុំឥណទានដោយខ្លួនឯងជាមួយបច្ចេកវិទ្យាដ៏ទំនើប។ ធនាគារក៏នឹងពង្រឹងប្រព័ន្ធសុវត្ថិភាពការពារទី១ និងទី២ ផងដែរ សម្រាប់ការកាត់បន្ថយហានិភ័យប្រតិបត្តិការដើម្បីធានាបាននូវសុវត្ថិភាពខ្ពស់ និងត្រឹមត្រូវសម្រាប់ប្រតិបត្តិការធនាគារ។ ដូច្នេះអតិថិជនរបស់យើងនឹងមានអារម្មណ៍ថាមានសុវត្ថិភាពគ្រប់ពេលវេលា ទោះបីជាអតិថិជនកំពុងប្រើប្រាស់សេវាកម្មផ្សេងៗគ្នាក៏ដោយ។

ធនាគារប្តេជ្ញាក្នុងការកសាងគោលជំហរដ៏មុតមាំមួយប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងបទដ្ឋានត្រឹមត្រូវក្នុងការថែរក្សា និងលើកកម្ពស់ប្រសិទ្ធភាពការងារដើម្បីផ្តល់ជូនបទពិសោធន៍នៃការបម្រើសេវាអតិថិជនល្អប្រសើរបំផុតស្របតាមចក្ខុវិស័យដ៏មុតមាំគឺ "គ្រួសារមួយ គណនីធនាគារមួយ" ក្នុងពេល ៥ ឆ្នាំខាងមុខនេះ។

ភាគទុនិក



១. កាណាឌីយ៉ាអ៊ីនវេសមិនហូលឌីង

គឺជាក្រុមហ៊ុនធំមួយដែលទទួលបានជោគជ័យបំផុតលើវិស័យហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ដោយមានការវិនិយោគហិរញ្ញវត្ថុក្នុងវិស័យធនាគារ មីក្រូហិរញ្ញវត្ថុ ធានារ៉ាប់រងអាយុជីវិត សាជីវកម្មខ្នាតធំ សហគ្រាសខ្នាតតូច និងមធ្យម និងអាជីវកម្មផ្សេងៗទៀតទូទាំងប្រទេសកម្ពុជា។ កាណាឌីយ៉ាអ៊ីនវេសមិនហូលឌីង មានបទពិសោធន៍ច្បាស់លាស់នៅ ក្នុងទីផ្សារកម្ពុជា និងធ្វើប្រតិបត្តិការដោយមានវិន័យ និងប្រកបដោយប្រសិទ្ធភាព។



២. ហ្វូឡឹតុនហ្វាយណាន់ស៊ល្យហូលឌីង

បានវិនិយោគ និងធ្វើប្រតិបត្តិការជាស្ថាប័នហិរញ្ញវត្ថុនៅក្នុងទីផ្សារ ដែលកំពុងរីកចម្រើនដោយផ្តោតលើការបម្រើសេវាកម្មដល់សហគ្រាសខ្នាតតូច និងមធ្យម និងអាជីវកម្ម ទីផ្សារចម្រុះតាមរយៈការអភិវឌ្ឍន៍ និងប្រតិបត្តិនូវខ្នាតគំរូ អាជីវកម្មប្រកបដោយភាពច្នៃប្រឌិតខ្ពស់ និងល្អដាច់គេ។

ត្រឹមដំណាច់ឆ្នាំ២០១៩នេះ ហ្វូឡឹតុនហ្វាយណាន់ស៊ល្យហូលឌីងបានវិនិយោគនៅក្នុងប្រទេសចំនួន ៨ នៅតំបន់អាស៊ីអាគ្នេយ៍ ដែលមានទ្រព្យសកម្មរហូតដល់ ២១ពាន់លានដុល្លារ ជាមួយនឹងបណ្តាញប្រតិបត្តិការសរុបចំនួន ១,៦០០កន្លែង និងបាន ផ្តល់សេវាជូនអតិថិជនប្រមាណ ៧លាននាក់។



៣. ប្រៃសណីយ៍កម្ពុជា

ប្រៃសណីយ៍កម្ពុជា ជាអង្គភាពស្វយ័តស្ថិតក្រោមបទប្បញ្ញាតិនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍កម្ពុជា និងស្ថិតក្រោមបទប្បញ្ញាតិហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ប្រៃសណីយ៍កម្ពុជា ទទួលបានសិទ្ធិអំណាចពិសេសដែលផ្តល់ដោយរាជរដ្ឋាភិបាលក្នុងការជួយគាំទ្រនូវគោលបំណង បេសកកម្ម ចក្ខុវិស័យ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

ចក្ខុវិស័យ

ជាធនាគារផ្តល់សេវាកម្មហិរញ្ញវត្ថុឈានមុខគេជូន
អតិថិជនគ្រប់កម្រិតដើម្បីលើកកម្ពស់ជីវភាព និង
ជួយបំពេញបំណងរីកចម្រើនរបស់ប្រជាជនកម្ពុជា
ហើយបង្កើតតម្លៃជានិរន្តរ៍ដល់ភាគទុនិក
បុគ្គលិក និងសង្គម។

បេសកកម្ម

អភិវឌ្ឍផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកប
ដោយភាពច្នៃប្រឌិតតាមតម្រូវការទីផ្សារ ព្រមទាំង
បម្រើសេវាល្អបំផុតជូនអតិថិជន។

តម្លៃស្នូល "RICE"

ការជឿទុកចិត្ត

ផ្តល់នូវភាពជឿជាក់ និងទំនុកចិត្ត
ក្នុងការបម្រើសេវាកម្មជូនអតិថិជន
ជាពិសេសគុណភាពនៃផលិតផល
និងសេវាកម្ម។

ការច្នៃប្រឌិត

អនុវត្តឱ្យមានប្រសិទ្ធភាពលើការបង្កើត
ផលិតផលដំណើរការសេវាកម្ម បច្ចេកវិទ្យា
និងគំនិតថ្មីៗ ដើម្បីផ្តល់នូវ
ដំណោះស្រាយសមស្របតាមតម្រូវការរបស់
អតិថិជន និងតម្រូវការទីផ្សារគោលដៅ។

ការយកចិត្តទុកដាក់

យកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់ជូនសេវា
កម្មដ៏ល្អបំផុតជូនអតិថិជនខាងក្នុង និង
អតិថិជនខាងក្រៅដើម្បីកសាង និងរក្សា
បាននូវទំនាក់ទំនងយូរអង្វែង។

សហគ្រិនភាព

លើកកម្ពស់ការអនុវត្តន៍គំនិតថ្មីៗ និង
ទំនួលខុសត្រូវរវាងបុគ្គលិក ដើម្បីបន្តច្នៃប្រឌិត
ឱ្យស្របតាមផ្នត់គំនិតរបស់សហគ្រិន។

ប្រវត្តិជោគជ័យ របស់ធនាគារ

២០១៤

- ការបង្កើតធនាគារស្នូល T24
- ការបង្កើតឡើងនូវប្រតិបត្តិការថ្នាក់កណ្តាល
- បង្កើតមុខងារប្រតិបត្តិការហានិភ័យជាប្រព័ន្ធសុវត្ថិភាពការពារទី២
- ការបង្កើតនូវមុខងារនាយកប្រតិបត្តិគ្រប់គ្រងហានិភ័យរួមបញ្ចូលគ្នា
- ការបង្កើតនូវមុខងារនាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ
- បើកប្រតិបត្តិការចំនួន ១៩ សាខាភាគច្រើននៅក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តសក្តានុពល
- កំណើនទ្រព្យសកម្មសរុបរហូតដល់ចំនួន ១២៩លានដុល្លារអាមេរិក និងមានបុគ្គលិកបម្រើការងារចំនួន ៧៤០នាក់
- ធនាគារចាប់ផ្តើមមានប្រាក់ចំណេញប្រចាំឆ្នាំចំនួន ១.៤លានដុល្លារអាមេរិក

២០១៥

- ការបង្កើតនូវមុខងារ ប្រធាននាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ
- ចាប់ផ្តើមវិភាគទិន្នន័យការិយាល័យឥណទានកម្ពុជារៀងរាល់ ៦ខែម្តង
- ដំណើរការប្រតិបត្តិការវិស្វកម្មឡើងវិញ
- បង្កើតមុខងារត្រួតពិនិត្យឥណទានក្នុងប្រព័ន្ធសុវត្ថិភាពការពារទី២
- ការពង្រីកប្រតិបត្តិការ ១២សាខាបន្ថែម ដែលសាខាសរុបកើនឡើងចំនួន ៣១សាខា ក្នុងរាជធានីភ្នំពេញ តាមបណ្តាខេត្តធំៗ និងស្រុកសក្តានុពល
- កំណើនទ្រព្យសកម្មសរុបកើនឡើងរហូតដល់ចំនួន ២៥៥លានដុល្លារអាមេរិក និងមានបុគ្គលិកបម្រើការងារចំនួន ១,០២៥នាក់
- សម្រេចបានប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំចំនួន ៤,៥លានដុល្លារអាមេរិក

ពានរង្វាន់ The Outstanding Emerging Retail Banking Bank Award in 2015

ពានរង្វាន់នេះប្រគល់ជូនដល់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ក្នុងនាមជាធនាគារដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការផ្តល់ផលិតផល និងសេវាកម្មដើម្បីជួយគាំទ្រការអភិវឌ្ឍន៍ទីផ្សារកម្ពុជា

២០១៦

- បង្កើតនូវបណ្តាញផ្តល់សេវាកម្មតាមប្រព័ន្ធឌីជីថល
- ការដាក់ដំណើរការសេវាអេធីអឹម
- ដំណើរការសាកល្បងសេវាធនាគារចល័ត
- កំណែទម្រង់តួនាទី ដើម្បីពង្រឹងបន្ថែមសេវាកម្មអតិថិជន
- ដំណើរការការគ្រប់គ្រងថ្នាក់តំបន់ដើម្បីធ្វើឱ្យប្រសើរឡើងនៅមុខងារ MIS និងការវិភាគ
- ការពង្រីកប្រតិបត្តិការចំនួន ៦សាខាបន្ថែមដែលសាខាសរុបកើនឡើងចំនួន ៣៧សាខា
- កំណើនទ្រព្យសកម្មសរុបកើនឡើងរហូតដល់ចំនួន៤១៦លានដុល្លារអាមេរិក និងមានបុគ្គលិកបម្រើការងារចំនួន ១,១៨២នាក់
- សម្រេចបានប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំរហូតដល់ចំនួន ៨លានដុល្លារអាមេរិក
- ការបង្កើតភ្នាក់ងារប្រមូលសំណងតាមទូរសព្ទនៅស្នាក់ការកណ្តាល

ពានរង្វាន់ The ESQR's Quality Choice Prize Award Program in 2016

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ទទួលបានពានរង្វាន់ ESQR'S Quality Choice Prize Award "កម្រិតមាស" ពីអង្គការអន្តរជាតិ "ESRQ" នៅប្រទេសអាឡឺម៉ង់ នាខែធ្នូ ឆ្នាំ២០១៦

២០១៧

- ទិញភាគហ៊ុនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វូណាន ១០០% ជាមួយទីតាំងប្រតិបត្តិការចំនួន ៥១សាខា
- ទំហំទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វូណានកើនឡើង៣ដងក្នុងមួយឆ្នាំ
- ដាក់ដំណើរការជាផ្លូវការនូវសេវាធនាគារចល័ត
- ក្លាយជាសមាជិកផ្លូវការ នៃប្រព័ន្ធ FAST
- ក្លាយជាដៃគូសហការជាមួយក្រុមហ៊ុន វីងលើសេវាបង់សងឥណទាន
- ពង្រីកប្រតិបត្តិការ ៥សាខាបន្ថែម ដែលចំនួនសាខាសរុបកើនឡើង ៤២សាខាទូទាំងប្រទេស
- ក្លាយជាធនាគារដៃគូរបស់ធនាគារអន្តរជាតិ DBS Bank និង ICBC
- ការអនុវត្តន៍ប្រព័ន្ធ Mobile Touch Point ចំនួន២០
- ប្រតិបត្តិការទ្រព្យសកម្មកណ្តាល
- កំណើនទ្រព្យសកម្មសរុបកើនឡើងរហូតដល់ ៥៧៧លានដុល្លារអាមេរិក និងមានបុគ្គលិកបម្រើការងារចំនួន ១,២៨១នាក់
- សម្រេចបានប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំរហូតដល់ចំនួន ៨,៥លានដុល្លារអាមេរិក

២០១៨

- បានអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃការស្នើសុំឥណទាន
- បង្កើតនូវមុខងារការគ្រប់គ្រងមូលធន
- ការពង្រីកប្រតិបត្តិការចំនួន ៣សាខាបន្ថែមដែលសាខាកើនឡើងរហូតដល់ចំនួន ៤៥សាខា
- ក្លាយខ្លួនជាសមាជិកឈានមុខគេលើប្រព័ន្ធប្រតិបត្តិការឆ្លងធនាគារ (CSS)
- បង្កើនដើមទុនចុះបញ្ជីរហូតដល់ ៧៦លានដុល្លារអាមេរិក
- កិច្ចសហការជាដៃគូជាមួយក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតសុវណ្ណភូមិឡាយហ្វ៍
- ក្លាយជាដៃគូសហការជាមួយក្រុមហ៊ុន តារាផេលើសេវាបង់សងឥណទាន
- កំណើនទ្រព្យសកម្មកើនឡើងរហូតដល់ចំនួន ៧៨៣លានដុល្លារអាមេរិក និងមានបុគ្គលិកបម្រើការងារចំនួន ១,៤៤១នាក់
- សម្រេចបានប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំរហូតដល់ចំនួន ១៧លានដុល្លារអាមេរិក

ពានរង្វាន់ The BIZZ AWARD in 2018

The BIZZ Award ឆ្នាំ ២០១៨ ត្រូវបានប្រគល់ជូនធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ផ្នែកឧត្តមភាពអាជីវកម្ម នៅទីក្រុងMaimi រដ្ឋ Florida

២០១៩

- ដាក់ដំណើរការ "សេវាធនាគារ ៣៦៥ថ្ងៃ" លើប្រតិបត្តិការសាខាចំនួន ៣សាខា នៅក្នុងរាជធានីភ្នំពេញរួមមាន សាខាការិយាល័យកណ្តាល សាខាអូឡាំពិក សាខាសែនសុខ (ផ្សារទំនើបអ៊ីអន សែនសុខ)
- ដាក់ដំណើរការប័ណ្ណឥណពន្ធវីសាក្នុងទីផ្សារ
- ក្លាយជាសមាជិកដំបូងនៃប្រព័ន្ធបាគង
- ដាក់ដំណើរការមុខងារទូទាត់តាមរយៈ QRកូដដោយឥតគិតថ្លៃក្នុងសេវាធនាគារចល័ត
- ដាក់ដំណើរការបញ្ចូលទឹកប្រាក់ក្នុងកាបូបលុយអេឡិចត្រូនិចទៅកាន់ តារាផេ និងគណនីវីងតាមរយៈសេវាធនាគារចល័ត
- ការពង្រីកប្រតិបត្តិការចំនួន ៦សាខាបន្ថែមដែលចំនួនសាខាកើនឡើងរហូតដល់ ៥១សាខា
- ការធ្វើតេស្តសាកល្បងប្រព័ន្ធទូទាត់ឥណទានរហ័ស (Loan Origination System)
- ភ្នាក់ងារបឹក្សាយោបល់តាមទូរសព្ទ និងគេហទំព័រ ២៤ម៉ោង លើ២៤ម៉ោង
- រៀបចំសិក្ខាសាលាអន្តរជាតិស្តីពី "ស្ត្រី និងហិរញ្ញវត្ថុ" ក្រោមកិច្ចសហការជាមួយ
- WSBI
  កំណើនទ្រព្យសកម្មសរុបកើនឡើងរហូតដល់ចំនួន ៨២០លានដុល្លារអាមេរិក
- និងចំនួនបុគ្គលិកបម្រើការងារចំនួន ១,៥៨៥នាក់
  សម្រេចបានប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំរហូតដល់ចំនួន២០លានដុល្លារអាមេរិក

បណ្តាញប្រតិបត្តិការ

ស្នាក់ការកណ្តាល

អគារលេខ២៦៥-២៦៩ វិថីព្រះអង្គឌួង សង្កាត់វត្តភ្នំ
ខណ្ឌដូនពេញ រាជធានីភ្នំពេញ

លេខទូរស័ព្ទ: **(855) 23 260 888**
អ៊ីម៉ែល: info@cambodiapostbank.com
គេហទំព័រ: www.cambodiapostbank.com.kh
Swift Code: CPBPKHP2

សាខារាជធានីភ្នំពេញ

សាខាការិយាល័យកណ្តាល 070 6000 98
អគារលេខ២៦៥-២៦៩ វិថីព្រះអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
365 DAYS

សាខាសែនសុខ (ផ្សារទំនើបអ៊ីអន សែនសុខ) 069 7000 99
ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
365 DAYS

សាខាអូឡាំពិក 070 6000 15
ផ្ទះលេខ០៥៧-០៥៨-០៥៩ មហាវិថីព្រះសីហនុ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
365 DAYS

សាខាបឹងត្របែក 069 6000 92
ភូមិ៥ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ

សាខាកាណាឌីយ 070 6000 25
ផ្ទះលេខ អា១-អា២ ផ្លូវវេងស្រេង ភូមិចោមចៅ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

សាខាជ្រោយចង្វារ 070 6000 64
ផ្ទះលេខ ២អេចអានិងបេ ក្រុមទី១ ផ្លូវជាតិលេខ៦អា ភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

សាខាច្បារអំពៅ 070 6000 14
ផ្លូវជាតិលេខ១ ភូមិដើមស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

សាខាដូនពេញ 070 6000 26
អគារអា ផ្លូវលេខ១៣ កែងផ្លូវលេខ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

សាខាអូរបែកក្អម 070 600 357
ផ្ទះលេខ១១៧អា ផ្លូវលេខ២៧១ ភូមិ១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ

សាខាឫស្សីកែវ 093 6000 73
ផ្លូវជាតិលេខ៥ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

សាខាសុវណ្ណ 070 6000 89
ផ្ទះលេខឌី៣៣ ផ្លូវដាយមិន សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ

សាខាទឹកថ្លា 070 6000 13
ផ្ទះលេខ អា១២៧-១២៩ ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

សាខាវិមានឯករាជ្យ 069 6000 29
ផ្ទះលេខ១៣២ សេ មហាវិថីព្រះនរោត្តម ភូមិ៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

សាខាតាមបណ្តាខេត្ត

សាខាខេត្តបាត់ដំបង 070 6000 97
ផ្ទះលេខ ២៤៨ ផ្លូវជាតិលេខ៥ ភូមិអូរចារ សង្កាត់អូរចារ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

សាខាខេត្តបន្ទាយមានជ័យ 070 6000 46
ភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ

សាខាខេត្តកំពង់ចាម 070 6000 52
ភូមិទី៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម

សាខាខេត្តកំពង់ឆ្នាំង 069 6000 45
ភូមិកណ្តាល សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

សាខាខេត្តកំពង់ធំ 070 6000 27
ផ្លូវជាតិលេខ៦អា ភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ

សាខាខេត្តកំពង់ស្ពឺ 070 6000 74
ផ្លូវជាតិលេខ៤ ភូមិសំណង់ សង្កាត់ការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

សាខាខេត្តកំពត 070 6000 31
ភូមិកំពង់បាយខាងត្បូង សង្កាត់កំពង់បាយ ក្រុងកំពត ខេត្តកំពត

សាខាខេត្តក្រចេះ 070 7000 58
វិថីសង្គមរាស្ត្រនិយម ភូមិវត្ត សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ

សាខាក្រុងបាត់ដំបង 070 6000 62
ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

សាខាក្រុងបាវិត 070 6000 42
ផ្លូវជាតិលេខ១ ភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង

សាខាខេត្តសៀមរាប 070 6000 35
ភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប

សាខាខេត្តឧត្តរមានជ័យ 070 6000 42
ភូមិសំរោង សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ

សាខាខេត្តប៉ៃលិន 070 6000 73
ភូមិប៉ាហុីត្បូង សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន

សាខាក្រុងប៉ោយប៉ែត 070 6000 45
ភូមិគីឡូលេខ៤ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

សាខាខេត្តព្រះសីហនុ 070 7000 84
អគារលេខ១៩៧ ជាន់ផ្ទាល់ដី និងជាន់ទីមួយ ផ្លូវឯករាជ្យ ភូមិ២ សង្កាត់២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

សាខាខេត្តព្រៃវែង 070 6000 94
ភូមិលេខ៤ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង

សាខាខេត្តពោធិ៍សាត់ 070 6000 78
ភូមិស្ពានីយ៍ សង្កាត់ស្វាយអាត់ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

សាខាខេត្តស្វាយរៀង 070 6000 76
ភូមិកៀនសាំង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង

សាខាសៀមរាប-ផ្សារលើ 070 7000 34
ផ្លូវជាតិលេខ៦ ភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប

សាខាខេត្តតាកែវ 070 6000 34
ផ្លូវជាតិលេខ២ ភូមិ៣ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ

សាខាក្រុងតាខ្មៅ 070 6000 87
ផ្លូវជាតិលេខ២ ភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល

សាខាតាមបណ្តាស្រុក

សាខាស្រុកអង្គស្នួល 070 7000 54
ផ្ទះលេខ១ និងលេខ២ ផ្លូវជាតិលេខ៤ ភូមិបូរីកម្មករ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល

សាខាស្រុកបាកាន 070 6000 84
ផ្លូវជាតិលេខ៥ ភូមិបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់

សាខាស្រុកបារាយណ៍ 093 7000 32
ផ្លូវជាតិលេខ៦ ភូមិព្រៃតាត្រាវ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ

សាខាស្រុកជើងព្រៃ 070 6000 96
ភូមិស្គន់ ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម

សាខាស្រុកកៀនស្វាយ 070 6000 92
ផ្លូវជាតិលេខ១ ភូមិដីឥដ្ឋកោះផុស ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល

សាខាស្រុកមុខកំពូល 070 6000 47
ភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល

សាខាស្រុកមេមត់ 093 7000 19
ផ្លូវជាតិលេខ៧ ភូមិម៉ាស៊ីនទឹក ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ

សាខាស្រុកពាមរក៍ 070 6000 57
ភូមិព្រែករាំង ឃុំបន្ទិចប្រាសាទ ស្រុកពាមរក៍ ខេត្តព្រៃវែង

សាខាស្រុកពញាក្រែក 093 6000 26
ផ្លូវជាតិលេខ៧ ភូមិក្រែកត្បូង ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ

សាខាស្រុកពញាឮ 070 6000 73
ភូមិទេពប្រណម្យ ឃុំវិហារហ្លួង ស្រុកពញាឮ ខេត្តកណ្តាល

សាខាស្រុកពួក 070 6000 93
ផ្លូវជាតិលេខ៦ ភូមិចំបក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប

សាខាស្រុករតនមណ្ឌល 070 6000 50
ភូមិស្ដៅ ឃុំស្ដៅ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង

សាខាស្រុកថ្មគោល 070 6000 91
ផ្ទះលេខ២៨ ផ្លូវជាតិលេខ៥ ភូមិគោកត្រប់ ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង

សាខាស្រុកត្រាំកក់ 070 6000 48
ភូមិព្រៃរំដេង ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ

សាខាស្រុកសំពៅលូន 070 6000 84
ផ្លូវជាតិលេខ៥៧បេ ភូមិត្រពាំងព្រលិត ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង

សាខាស្រុកស្អាង 070 6000 19
ផ្លូវជាតិលេខ២១ ភូមិព្រែករុន ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល

សាខាស្រុកស្ទោង 070 6000 43
ផ្លូវជាតិលេខ៦ ភូមិលាបទង ឃុំកំពង់ចិនត្បូង ស្រុកស្ទួង ខេត្តកំពង់ធំ

ប្រតិបត្តិការហិរញ្ញវត្ថុលើ
សេវាធនាគារចល័ត
រហ័ស & ងាយស្រួល
សារជូនដំណឹង
ត្រួតពិនិត្យសមតុល្យគណនី
ទូទាត់តាម QR Scan
មុខងារស្កេនមុខ ឬស្នាមក្រយៅដៃ
បញ្ចូលទឹកប្រាក់ក្នុង E-Wallet
ទូទាត់វិក្កយបត្រផ្សេងៗ
ដកប្រាក់
បើក ឬផ្អាកដំណើរការប័ណ្ណអេធីអឹម
ផ្ទេរប្រាក់
ប្តូរលេខសម្ងាត់
សេវាប្រឹក្សាអតិថិជន
Hotline Number
24/7
023 260 888
www.cpbank.com.kh
GET IT ON
Google Play
Download on the
App Store

អភិបាលកិច្ចសាជីវកម្ម

អភិបាលកិច្ចសាជីវកម្មជួយបង្កើតកេរ្តិ៍ឈ្មោះ និងភាពទាក់ទាញដល់អតិថិជន អ្នកវិនិយោគ អ្នកផ្គត់ផ្គង់ និងសហគមន៍ប្រកបដោយទំនុកចិត្ត។ ធនាគារបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីកសាងនូវវប្បធម៌ការងារល្អ ព្រមទាំងបានបង្កើតនូវមុខងារត្រួតពិនិត្យផ្ទៃក្នុង ដើម្បីធានាបាននូវប្រសិទ្ធភាព។

ការបង្កើតនូវរចនាសម្ព័ន្ធអភិបាលកិច្ចសាជីវកម្ម គឺរួមបញ្ចូលធាតុសំខាន់មួយចំនួនដូចជា (ក) បង្កើតឱ្យមានឯករាជ្យភាពជាតិនៃមុខងារសវនកម្មផ្ទៃក្នុង និងការប្រតិបត្តិតាម ដោយត្រូវរាយការណ៍ផ្ទាល់ទៅកាន់ប្រធានគណៈកម្មាធិការសវនកម្មផ្ទៃក្នុងកម្រិតក្រុមប្រឹក្សាភិបាល (ខ) ក្រុមហ៊ុនសវនកម្មត្រូវបានជ្រើសតាំងដោយក្រុមប្រឹក្សាភិបាល ហើយរបាយការណ៍របស់ក្រុមហ៊ុនសវនកម្មនោះ ត្រូវបានរាយការណ៍ទៅក្រុមប្រឹក្សាភិបាលផងដែរ (គ) បង្កើតឱ្យមានគណៈកម្មាធិការប្រតិបត្តិក្នុងជួរគណៈគ្រប់គ្រង ដើម្បីធានានូវប្រសិទ្ធភាពក្នុងការអនុវត្តន៍កិច្ចការប្រចាំថ្ងៃ (ឃ) បង្កើតឱ្យមានក្រមសីលធម៌វិជ្ជាជីវៈក្នុងការអនុវត្តន៍ការងារ និងគោលនយោបាយនិវេទនកម្ម (ង) គណៈកម្មាធិការកម្រិតក្រុមប្រឹក្សាភិបាលមានតួនាទីក្នុងការត្រួតពិនិត្យ និងសម្រេចនូវកិច្ចការសំខាន់ៗដូចជា ផែនការថវិកាប្រចាំឆ្នាំ ផែនការធនធានមនុស្ស ផែនការសវនកម្ម គោលនយោបាយឥណទាន (ច) ការគ្រប់គ្រងហានិភ័យឯករាជ្យ គឺត្រូវបានរាយការណ៍ដោយផ្ទាល់ទៅគណៈកម្មាធិការគ្រប់គ្រងហានិភ័យកម្រិតក្រុមប្រឹក្សាភិបាល។

តួនាទីរបស់ក្រុមប្រឹក្សាភិបាលត្រូវបានកំណត់តាមខ្នាតគំរូអន្តរជាតិដោយអនុលោមតាមក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិក្នុងប្រទេស និងតំបន់។ រចនាសម្ព័ន្ធសាជីវកម្មបច្ចុប្បន្នត្រូវបានរួមបញ្ចូលទាំងក្រុមប្រឹក្សាភិបាល អនុគណៈកម្មាធិការក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនាយក។

ក្រុមប្រឹក្សាភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាលទាំង ៣ នឹងជួយដល់ក្រុមប្រឹក្សាភិបាលក្នុងការផ្តោតលើបញ្ហាជាក់លាក់ បំពេញតួនាទី និងភារកិច្ចដែលបានធ្វើប្រតិភូកម្មដោយក្រុមប្រឹក្សាភិបាល រាយការណ៍ទៅកាន់ក្រុមប្រឹក្សាភិបាលលើការសម្រេចចិត្ត និងការអនុវត្តន៍នូវផែនការសកម្មភាពតាមដានការអនុវត្តន៍របស់គណៈគ្រប់គ្រង និងផ្តល់អនុសាសន៍ចាំបាច់ផ្សេងៗដល់គណៈគ្រប់គ្រង។ គណៈកម្មាធិការទាំង ៣ រួមមាន៖

១. គណៈកម្មាធិការសវនកម្ម

២. គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

៣. គណៈកម្មាធិការតម្លៃការ និងតែងតាំង

១. គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការនេះ ត្រូវបានបង្កើតក្រោមគោលការណ៍អភិបាលកិច្ចសាជីវកម្ម និងត្រូវបានផ្តល់ឱ្យនូវអំណាច ពិសេសចាំបាច់ដូចបានកំណត់ក្នុងតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការទាំងនេះ ដើម្បីសម្រេចបាននូវគោលដៅរបស់ខ្លួន។ អំណាច តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្មមានភាពទូលំទូលាយ និងគោរពតាមលក្ខខណ្ឌដូចបានកំណត់ក្នុងមាត្រា ១៣១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក៏ដូចជាប្រការ ៨ នៃប្រកាសលេខ ធ៧-០៨-២១១ប្រ.ក របស់ធនាគារជាតិនៃកម្ពុជា ស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ប្រធានគណៈកម្មាធិការនេះ គឺសមាជិកក្រុមប្រឹក្សាភិបាលដែលមិនប្រតិបត្តិ និងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យដែលនឹងត្រូវឆ្លើយនូវសំណួរទាំងអស់ពីភាគទុនិកនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ។

សមាជិក

គណៈកម្មាធិការមានសមាជិក ៣រូប។ ប្រធាននៃគណៈកម្មាធិការ គឺសមាជិកក្រុមប្រឹក្សាភិបាលសវនកម្មមិនប្រតិបត្តិ និងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យនៅក្នុងធនាគារ។សមាជិកទាំងអស់នៃគណៈកម្មាធិការមានឯករាជ្យភាពក្នុងក្រុមហ៊ុន។

- លោក **Giang Sovann** ប្រធាន
- **DR. Pung Carolyne** សមាជិក
- លោក **Teo Meng Poh Philip** សមាជិក

កិច្ចប្រជុំ

កិច្ចប្រជុំនៃគណៈកម្មាធិការសវនកម្មនឹងត្រូវប្រារព្ធធ្វើឡើង ជាញឹកញាប់តាមការស្នើសុំ ប៉ុន្តែមិនត្រូវតិចជាង ៤ ដងក្នុងមួយឆ្នាំនោះទេ។

២. គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

គណៈកម្មាធិការនេះមានសមាជិក ៣រូប ដែលត្រូវបានជ្រើសតាំងដោយក្រុមប្រឹក្សាភិបាល។ ប្រធានគណៈកម្មាធិការនេះ គឺជាបុគ្គលដែលមានបទពិសោធន៍ និងជំនាញក្នុងការគ្រប់គ្រងហានិភ័យក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ គណៈកម្មាធិការនេះ មានភារកិច្ចសំខាន់ៗដូចមានចែងក្នុងតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងអនុវត្តភារកិច្ចផ្សេងៗទៀត តាមការចាត់តាំងរបស់ក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការនេះមានភារកិច្ចត្រួតពិនិត្យលើការអនុវត្តន៍គោលនយោបាយគ្រប់គ្រងហានិភ័យដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការនេះ ក៏បានដើរតួនាទីយ៉ាងសំខាន់ផងដែរក្នុងការផ្តល់ប្រឹក្សា លើកិច្ចការពាក់ព័ន្ធនឹងហានិភ័យរបស់ធនាគារស្របតាមស្តង់ដារអន្តរជាតិ។

សមាជិក

ក្រុមប្រឹក្សាភិបាលជាអ្នកជ្រើសតាំង ប្រធានគណៈកម្មាធិការគ្រប់គ្រងហានិភ័យដែលមានអាណត្តិរយៈពេល ៣ឆ្នាំ សម្រាប់តំណែងនេះ រាប់ចាប់ពីកាលបរិច្ឆេទនៃការជ្រើសតាំង។ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ គឺជាសមាជិកក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិ និងមានឯករាជ្យភាពពីគណៈគ្រប់គ្រង មិនជាប់ពាក់ព័ន្ធនឹងមុខជំនួញណាមួយ ឬទំនាក់ទំនងផ្សេងៗដែលអាចជ្រៀតជ្រែកលើការវិនិច្ឆ័យឯករាជ្យរបស់ពួកគាត់។

- លោក **Teo Meng Poh Philip** ប្រធាន
- លោក **Giang Sovann** សមាជិក
- លោក **Neo Poh Kiat** សមាជិក

កិច្ចប្រជុំ

កិច្ចប្រជុំនឹងត្រូវបានប្រារព្ធធ្វើឡើងនៅពេលដែលសមរម្យ ប៉ុន្តែយ៉ាងហោចណាស់ ៤ដងក្នុងមួយឆ្នាំ។ ប្រធានគណៈកម្មាធិការគ្រប់គ្រងហានិភ័យនេះអាចកោះហៅប្រជុំបន្ថែមទៀត ប្រសិនបើមានករណីចាំបាច់ណាមួយ។

៣. គណៈកម្មាធិការតម្លៃការ និងតែងតាំង

គណៈកម្មាធិការនេះ ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលស្របតាមតម្រូវការអភិបាលកិច្ច ដើម្បីផ្តល់នូវការអនុវត្តន៍ដ៏ល្អបំផុតសម្រាប់ធនាគារ។ ប្រធានគណៈកម្មាធិការ គឺជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ។ គណៈកម្មាធិការនេះ ទទួលអនុវត្តគោលនយោបាយតម្លៃការ ដើម្បីឱ្យមានសង្គតិភាពជាមួយនឹងទិសដៅរយៈពេលវែង និងតម្លៃសាជីវកម្មរបស់ធនាគារ។ គណៈកម្មាធិការនេះ ផ្តល់អនុសាសន៍ខ្លះៗលើនីតិវិធី ដើម្បីជ្រើសរើស និងបំពេញបន្ថែមនូវសមាជិកក្រុមប្រឹក្សាភិបាល និងសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យដែលមានសក្តានុពល ដើម្បីក្លាយជាសមាជិកគណៈកម្មាធិការនេះ។ គណៈកម្មាធិការតម្លៃការ និងតែងតាំងត្រូវធ្វើការអនុម័តជ្រើសតាំងគណៈគ្រប់គ្រងជាន់ខ្ពស់ផងដែរ។ គណៈកម្មាធិការនេះ ត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាលដែលមានសមាជិក ៣រូប និងលេខាធិការនៃគណៈកម្មាធិការ១រូប។ ក្រុមប្រឹក្សាភិបាលមានអំណាចគ្រប់ពេល ក្នុងការដកសមាជិកណាមួយចេញពីគណៈកម្មាធិការនេះ និងតែងតាំងសមាជិកថ្មី ដើម្បីបំពេញកន្លែងទំនេរក្រោយពីការដកចេញនោះ។

- លោក **Neo Poh Kiat** ប្រធាន
- **DR. Pung Carolyne** សមាជិក
- លោក **Yeo Hong Ping** សមាជិក

កិច្ចប្រជុំ

ការប្រជុំនឹងត្រូវបានប្រារព្ធឡើងនៅពេលដែលសមរម្យ ប៉ុន្តែយ៉ាងហោចណាស់ ២ដងក្នុងមួយឆ្នាំ។ ប្រធានគណៈកម្មាធិការនេះ អាចរៀបចំឱ្យមានការប្រជុំបន្ថែមទៀត ប្រសិនបើចាំបាច់។

គណៈកម្មាធិការនាយក

គណៈកម្មាធិការនាយកទាំង ៨ នឹងជួយដល់ប្រធាននាយកប្រតិបត្តិក្នុងការផ្តោតទៅលើបញ្ហាជាក់លាក់ តាមរយៈការត្រួតពិនិត្យ និងតាមដាននូវដំណើរការប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារ ហើយថែមទាំងធ្វើកិច្ចការផ្សេងៗទៀត តាមការចាត់តាំងរបស់ប្រធាននាយកប្រតិបត្តិ និងរាយការណ៍ជូនប្រធាននាយកប្រតិបត្តិ ដើម្បីធ្វើសេចក្តីសម្រេចចិត្ត និងដោះស្រាយនូវបញ្ហាផ្សេងៗ ត្រួតពិនិត្យលទ្ធផលការងាររបស់ធនាគារ និងផ្តល់អនុសាសន៍ចាំបាច់មួយចំនួន ដើម្បីដោះស្រាយនូវប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ។

១. គណៈកម្មាធិការប្រតិបត្តិ

គណៈកម្មាធិការនេះ រួមមានប្រធាននាយកប្រតិបត្តិ និងនាយកប្រតិបត្តិគ្រប់គ្រងនាយកដ្ឋានទាំងអស់ដែលត្រូវរាយការណ៍ផ្ទាល់ទៅកាន់ប្រធាននាយកប្រតិបត្តិ និងនាយកប្រតិបត្តិគ្រប់គ្រងនាយកដ្ឋានផ្សេងទៀត អាចត្រូវបានអញ្ជើញចូលរួមប្រសិនបើមានករណីចាំបាច់។ គណៈកម្មាធិការប្រតិបត្តិត្រូវជួយដល់ប្រធាននាយកប្រតិបត្តិការត្រួតពិនិត្យ និងតាមដានដំណើរការ ការអនុវត្តន៍ប្រតិបត្តិការទាំងមូលរបស់ធនាគារ និងរាយការណ៍ពីវឌ្ឍនភាពនៃសកម្មភាពការងារប្រចាំថ្ងៃពីគ្រប់ផ្នែកពាក់ព័ន្ធទៅប្រធាននាយកប្រតិបត្តិ ព្រមទាំងផ្តល់នូវអនុសាសន៍ដើម្បីគាំទ្រដល់ ការអនុម័តលើបញ្ហាទូទៅដែលកើតឡើងនៅក្នុងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ។

សមាជិក

សមាជិកគណៈកម្មាធិការប្រតិបត្តិ គឺជានាយកប្រតិបត្តិ ឬនាយកនៃនាយកដ្ឋានដែលរាយការណ៍ផ្ទាល់ទៅកាន់នាយកប្រតិបត្តិរួមមាន៖

- ប្រធាននាយកប្រតិបត្តិ ប្រធាន
- ប្រធាននាយកប្រតិបត្តិធនធានមនុស្ស សមាជិក
- ប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ សមាជិក
- ប្រធាននាយកប្រតិបត្តិប្រតិបត្តិការ សមាជិក
- ប្រធាននាយិកាប្រតិបត្តិពាណិជ្ជកម្ម និងអភិបាលសាខា សមាជិក
- ប្រធាននាយកប្រតិបត្តិបច្ចេកវិទ្យាព័ត៌មានស្តីទី សមាជិក
- នាយកប្រតិបត្តិឥណទាន សមាជិក
- ប្រធានផ្នែកនីតិកម្ម លេខាកត់ត្រា

កិច្ចប្រជុំ

កិច្ចប្រជុំនឹងត្រូវបានប្រារព្ធធ្វើឡើង នៅពេលណាមួយសមរម្យប៉ុន្តែជារួមការប្រជុំគណៈកម្មាធិការប្រតិបត្តិ គឺប្រារព្ធឡើងជារៀងរាល់សប្តាហ៍លើកលែងតែមានការមមាញឹកផ្សេងៗការប្រជុំនឹងត្រូវលើកទៅសប្តាហ៍ក្រោយបន្ទាប់ទៀតបាន។

២. គណៈកម្មាធិការទ្រព្យសកម្ម អកម្ម និងបំណុល

គោលបំណងនៃគណៈកម្មាធិការទ្រព្យសកម្ម អកម្ម និងបំណុល គឺដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងនូវទ្រព្យសម្បត្តិ និងបំណុលរបស់ធនាគារទាំងមូល។ គណៈកម្មាធិការនេះត្រួតពិនិត្យ និងឃ្លាំមើលជាប្រចាំនូវស្ថានភាពហានិភ័យនានា ដែលអាចប៉ះពាល់ដល់ធនាគាររួមមានអនុបាតសន្ទនីយភាព អនុបាតសមតុល្យប្រាក់កម្ចីធៀបនឹងសមតុល្យប្រាក់បញ្ញើសន្សំ ផលប៉ះពាល់ដែលបណ្តាលមកពីទំហំប្រាក់បញ្ញើសន្សំដែលបានពីមួយប្រភព ឬអតិថិជនណាមួយ ការកំណត់សំណាងអតិបរមា និងអប្បបរមានៃទ្រព្យសកម្ម អកម្ម និងបំណុលព្រមទាំងការប្រែប្រួលនៃអត្រាការប្រាក់។ អត្ថប្រយោជន៍របស់របស់ធនាគារត្រូវបានធានាតាមរយៈការគ្រប់គ្រងនូវរាល់ធាតុសកម្មនានា នៃទ្រព្យសកម្ម អកម្ម និងបំណុលយ៉ាងត្រឹមត្រូវ និងប្រកបដោយតម្លាភាព។

សមាជិក

គណៈកម្មាធិការគ្រប់គ្រងហានិភ័យកម្រិតក្រុមប្រឹក្សាភិបាល មានតួនាទីតែងតាំងប្រធានគណៈកម្មាធិការទ្រព្យសកម្ម អកម្ម និងបំណុល ហើយមានអាណត្តិ ៣ឆ្នាំ ដោយរាប់ចាប់ពីពេលតែងតាំង។ គណៈកម្មាធិការនេះរួមមានសមាជិកដូចខាងក្រោម៖

- ប្រធាននាយកប្រតិបត្តិ ប្រធាន
- ប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ សមាជិក
- ប្រធាននាយកប្រតិបត្តិប្រតិបត្តិការ សមាជិក
- ប្រធាននាយិកាប្រតិបត្តិពាណិជ្ជកម្ម និងអភិបាលសាខា សមាជិក
- នាយិកាប្រតិបត្តិរតនាភិបាល សមាជិក
- នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ សមាជិក
- លេខាក្រុមហ៊ុន លេខាកត់ត្រា

កិច្ចប្រជុំ

កិច្ចប្រជុំនឹងត្រូវបានប្រារព្ធធ្វើឡើងនៅពេលណាមួយសមរម្យ ប៉ុន្តែយ៉ាងហោចណាស់ធ្វើឡើង ១ដងក្នុងមួយខែ។ ប្រធានគណៈកម្មាធិការនេះអាចរៀបចំឱ្យមានការប្រជុំបន្ថែមទៀត ប្រសិនបើចាំបាច់។

៣. គណៈកម្មាធិការឥណទាន

គណៈកម្មាធិការឥណទានត្រូវបានបង្កើតឡើងដើម្បីធានាបាននូវការអនុលោមតាមអភិបាលកិច្ច និងការគ្រប់គ្រងផលបត្ររបស់ធនាគារ។ គោលបំណងនៃគណៈកម្មាធិការនេះ៖

- អនុម័តគោលការណ៍ណែនាំឥណទាន ដែលស្ថិតនៅក្រោមក្របខ័ណ្ឌអភិបាលកិច្ច និងកម្រិតឥណទានដែលបានផ្តល់ជូនអតិថិជន ឬក្រុមអតិថិជនដែលជាប់ពាក់ព័ន្ធតាមសិទ្ធអំណាចដែលផ្តល់ឱ្យពីគណៈកម្មាធិការក្រុមប្រឹក្សាភិបាល។
- ទទួលខុសត្រូវចំពោះការអនុវត្តន៍ និងតាមដានប្រព័ន្ធគ្រប់គ្រងហានិភ័យឥណទាន និងគោលនយោបាយទាក់ទងនឹងអាជីវកម្មរបស់ធនាគារទាំងមូល។
- ធានាឱ្យបានការអនុលោមតាមកម្មវិធីអភិបាលកិច្ច និងប្រព័ន្ធត្រួតពិនិត្យ។

សមាជិក

សមាសភាពគណៈកម្មាធិការឥណទានរួមមាន៖

- នាយកប្រតិបត្តិឥណទាន ប្រធាន
- ប្រធាននាយកប្រតិបត្តិ សមាជិក
- ប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ សមាជិក
- ប្រធាននាយកប្រតិបត្តិប្រតិបត្តិការ សមាជិក
- នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ លេខាកត់ត្រា

កិច្ចប្រជុំ

ការអនុម័តអាចធ្វើឡើងដោយប្រើប្រាស់សារអេឡិចត្រូនិក នៅពេលមានករណីចាំបាច់ណាមួយ។ កិច្ចប្រជុំត្រូវបានប្រារព្ធធ្វើឡើងនៅពេលណាមួយសមរម្យ ប៉ុន្តែយ៉ាងហោចណាស់ធ្វើឡើង ១ដងក្នុងមួយខែ។ ប្រធានគណៈកម្មាធិការអាចរៀបចំឱ្យមានការប្រជុំបន្ថែមទៀត ប្រសិនបើចាំបាច់។

៤. គណៈកម្មាធិការសេវាកម្ម និងដោះស្រាយបណ្តឹងអតិថិជន

គោលបំណងនៃការបង្កើតឱ្យមានគណៈកម្មាធិការសេវាកម្ម និងដោះស្រាយបណ្តឹងអតិថិជននេះឡើង គឺដើម្បីផ្តល់ព័ត៌មានដល់សមាជិកពីសារៈសំខាន់នៃសេវាអតិថិជន និងដើម្បីចូលរួមសម្របសម្រួល អប់រំបណ្តុះបណ្តាល ក៏ដូចជាបង្កើតឱ្យមានវប្បធម៌នៃការបម្រើសេវាអតិថិជនល្អសម្រាប់ធនាគារទាំងមូល។ លើសពីនេះទៅទៀតគណៈកម្មាធិការនឹងធ្វើការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់ជាអនុសាសន៍ចាំបាច់នានាទៅគ្រប់ទិដ្ឋភាពទាំងអស់នូវគំនិត និងការយល់ឃើញរបស់អតិថិជន ព្រមទាំងធ្វើការដោះស្រាយនូវភាពមិនពេញចិត្តរបស់អតិថិជនទាំងអតិថិជនខាងក្នុង និង អតិថិជនខាងក្រៅ។

សមាជិក

សមាជិកគណៈកម្មាធិការនេះតម្រូវមានប្រធាន១រូប និងសមាជិកយ៉ាងតិច៧រូបរួមមាន៖

នាយិកាប្រតិបត្តិប្រតិបត្តិតាម	ប្រធាន
ប្រធាននាយកប្រតិបត្តិ	សមាជិក
ប្រធាននាយកប្រតិបត្តិប្រតិបត្តិការ	សមាជិក
ប្រធាននាយកប្រតិបត្តិធនធានមនុស្ស	សមាជិក
ប្រធាននាយិកាប្រតិបត្តិពាណិជ្ជកម្ម និងអភិបាលសាខា	សមាជិក
នាយកគ្រប់គ្រងទីផ្សារ	សមាជិក
ប្រធានផ្នែកនីតិកម្ម	លេខាកត់ត្រា

កិច្ចប្រជុំ

កិច្ចប្រជុំត្រូវបានប្រារព្ធធ្វើឡើងនៅពេលណាមួយសមរម្យ ប៉ុន្តែយ៉ាងហោចណាស់ធ្វើឡើង ១ដងក្នុងមួយខែ។ ប្រធានគណៈកម្មាធិការអាចរៀបចំឱ្យមានការប្រជុំបន្ថែមទៀត ប្រសិនបើចាំបាច់។

៥. គណៈកម្មាធិការធនធានមនុស្ស

គោលបំណងនៃការបង្កើតគណៈកម្មាធិការធនធានមនុស្ស៖

- ដើម្បីធានាបានថាគោលនយោបាយធនធានមនុស្សត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនជាមួយគោលបំណងយូរអង្វែង និងគុណតម្លៃរបស់ធនាគារ។
- ផ្តល់អនុសាសន៍លើនីតិវិធីដល់ថ្នាក់គ្រប់គ្រងអំពីរឿងរ៉ាវពាក់ព័ន្ធនឹងកិច្ចការធនធានមនុស្សណាមួយដែលមិនមានចែងនៅក្នុងគោលនយោបាយរបស់ធនាគារ។
- ផ្តល់អនុសាសន៍ដល់ថ្នាក់គ្រប់គ្រង អំពីនីតិវិធីវិន័យបុគ្គលិក ចំពោះបញ្ហាដែលពួកគាត់មិនអាចធ្វើការសម្រេចចិត្តបានដោយខ្លួនឯងនៅក្នុងនាយកដ្ឋានរបស់ពួកគាត់។
- ការទំនួលខុសត្រូវចំពោះបញ្ហាណាមួយដែលទាក់ទងនឹងបញ្ហាបុគ្គលិក ដែលចាត់តាំងដោយប្រធាននាយកប្រតិបត្តិ។

សមាជិក

សមាជិកគណៈកម្មាធិការគួរតែប្រុងប្រយ័ត្នដើម្បីជៀសវាងទំនាស់ផលប្រយោជន៍ ដែលអាចធ្វើឲ្យប៉ះពាល់ដល់ការវិនិច្ឆ័យរបស់ពួកគេ ហើយគួរតែដកខ្លួនចេញពីការសម្រេចចិត្តណាមួយដែលអាចនឹងមានទំនាស់ផលប្រយោជន៍ (ទោះបីជាវាអាចនឹងកើតមានឬកើតមានជាក់ស្តែងក៏ដោយ)។ គណៈកម្មាធិការធនធានមនុស្សមានសមាជិកអចិន្ត្រៃយ៍ដែលមានសមាសភាពដូចខាងក្រោម៖

ប្រធាននាយកប្រតិបត្តិធនធានមនុស្ស	ប្រធាន
ប្រធាននាយកប្រតិបត្តិ	សមាជិក
ប្រធានផ្នែកសម្របសម្រួលកិច្ចការធនធានមនុស្ស	លេខាកត់ត្រា

សមាជិកផ្សេងទៀតអាចនឹងតែងតាំងជាតំណាងក្នុងករណីដែលសមាជិកខាងលើមិនអាចចូលរួមការប្រជុំបាន។ ក្នុងករណីប្រធានគណៈកម្មាធិការនេះត្រូវបានតែងតាំង នោះកិច្ចប្រជុំត្រូវបានដឹកនាំដោយសមាជិកណាម្នាក់ផ្សេងទៀតដែលត្រូវបានជ្រើសរើសដោយសមាជិកនៃកិច្ចប្រជុំ។

កិច្ចប្រជុំ

កិច្ចប្រជុំនេះ នឹងត្រូវបានធ្វើឡើងនៅពេលមួយដ៏សមស្របដែលបានកំណត់។ ប្រធានគណៈកម្មាធិការនេះ អាចរៀបចំឱ្យមានការប្រជុំបន្ថែមទៀតប្រសិនបើចាំបាច់។

៦. គណៈកម្មាធិការគ្រប់គ្រងហានិភ័យប្រតិបត្តិការ

គណៈកម្មាធិការគ្រប់គ្រងហានិភ័យប្រតិបត្តិការត្រូវបានបង្កើតឡើងដើម្បីធានាដល់ការកំណត់អត្តសញ្ញាណការត្រួតពិនិត្យ និងគ្រប់គ្រងរាល់ហេតុការណ៍ហានិភ័យប្រតិបត្តិការទាំងអស់របស់ធនាគារ។ គោលបំណងនៃគណៈកម្មាធិការគ្រប់គ្រងហានិភ័យប្រតិបត្តិការគឺ៖

- អនុវត្ត និងរក្សារចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យប្រតិបត្តិការរបស់ធនាគារ។
- ត្រួតពិនិត្យ និងកែលម្អរាល់ហេតុការណ៍ហានិភ័យប្រតិបត្តិការដែលអាចធ្វើឱ្យប៉ះពាល់ដល់ធនាគារធ្ងន់ធ្ងរ ដើម្បីបញ្ចៀស ឬកាត់បន្ថយឱ្យស្ថិតក្នុងកម្រិតទាបមួយដែលអាចទទួលយកបាន។
- ទទួលខុសត្រូវលើការអនុវត្តន៍ និងការគ្រប់គ្រងហានិភ័យប្រតិបត្តិការ រួមទាំងគោលនយោបាយនានា ដែលសមស្របទៅនឹងអាជីវកម្ម និងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងហានិភ័យ។
- ធ្វើឱ្យប្រាកដថា ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ អនុលោមតាមគោលនយោបាយគ្រប់គ្រង និងត្រួតពិនិត្យរបស់ធនាគារទាំងមូល។

សមាជិក

សមាសភាពគណៈកម្មាធិការគ្រប់គ្រងហានិភ័យប្រតិបត្តិការត្រូវដឹកនាំដោយប្រធាននាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ និងមានសមាជិកដូចខាងក្រោម៖

ប្រធាននាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ	ប្រធាន
ប្រធាននាយកប្រតិបត្តិ	អនុប្រធាន
ប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ	សមាជិក
ប្រធាននាយកប្រតិបត្តិប្រតិបត្តិការ	សមាជិក
ប្រធាននាយិកាប្រតិបត្តិពាណិជ្ជកម្ម និងអភិបាលសាខា	សមាជិក
ប្រធាននាយកប្រតិបត្តិបច្ចេកវិទ្យាព័ត៌មានស្តីទី	សមាជិក
នាយកប្រតិបត្តិឥណទាន	សមាជិក
នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ	សមាជិក
នាយកប្រតិបត្តិប្រព័ន្ធបណ្តាញធនាគារអេឡិចត្រូនិច	សមាជិក
នាយកប្រតិបត្តិសវនកម្មផ្ទៃក្នុង	សមាជិក
នាយិកាប្រតិបត្តិប្រតិបត្តិតាម	សមាជិក
ប្រធានផ្នែកគ្រប់គ្រងហានិភ័យប្រតិបត្តិការ	ជាលេខាកត់ត្រា

កិច្ចប្រជុំ

កិច្ចប្រជុំផ្លូវការលើការគ្រប់គ្រងហានិភ័យប្រតិបត្តិការនឹងត្រូវធ្វើឡើងយ៉ាងហោចណាស់មួយដងក្នុងមួយខែ។ ប្រធានគណៈកម្មាធិការគ្រប់គ្រងហានិភ័យប្រតិបត្តិការ អាចរៀបចំឱ្យមានការប្រជុំបន្ថែមទៀត ប្រសិនបើចាំបាច់។

៧. គណៈកម្មាធិការលទ្ធកម្ម

គោលបំណងគណៈកម្មាធិការលទ្ធកម្ម គឺដើម្បីស្វែងយល់លើគុណតម្លៃនៃសាច់ប្រាក់នៅគ្រប់ការធ្វើលទ្ធកម្ម។ តម្លៃដែលត្រូវបានសម្រេចជ្រើសរើសតាមរយៈការប្រកួតប្រជែងដោយបើកចំហនៅពេលដែលអ្នកផ្គត់ផ្គង់ណាមួយអាចជឿទុកចិត្តបានថា គម្រោងសំណើរបស់ពួកគេត្រូវបានវាយតម្លៃថាអាចទទួលយកបានមិនមានន័យថា "តម្លៃទាប" ជានិច្ចកាលត្រូវបានជ្រើសរើសដោយស្វ័យប្រវត្តិនោះទេ ពោលគឺរួមបញ្ចូលទាំងការពិចារណាទៅលើភាពសមស្រប និងគោលបំណងតម្លៃលើទីផ្សារ ចំណូលលើការវិនិយោគ ការចំណាយទាំងអស់ក្នុងមួយវដ្តជីវិត ការផ្គត់ផ្គង់ទាន់ពេលវេលា ការគាំទ្របន្ទាប់ពីផ្គត់ផ្គង់រួច និងនិរន្តរភាពបរិស្ថានទំនួលខុសត្រូវសង្គមភស្តុតាងនៃបទពិសោធន៍ដែលបានអនុវត្តដើម្បីការធានាបាននូវប្រសិទ្ធិភាព និងការអនុលោមទៅតាមច្បាប់។

សមាជិក

សមាសភាពគណៈកម្មាធិការលទ្ធកម្មរួមមាន៖

ប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ	ប្រធាន
ប្រធាននាយកប្រតិបត្តិ	អនុប្រធាន
ប្រធាននាយកប្រតិបត្តិប្រតិបត្តិការ	សមាជិក
នាយកប្រតិបត្តិឥណទាន	សមាជិក
នាយកគ្រប់គ្រងរដ្ឋបាល និងលទ្ធកម្ម	សមាជិក និង លេខាកត់ត្រា

កិច្ចប្រជុំ

កិច្ចប្រជុំត្រូវបានធ្វើឡើងនៅពេលមួយដ៏សមស្របយ៉ាងហោចណាស់១ ដងក្នុងមួយខែ។ ប្រធានគណៈកម្មាធិការលទ្ធកម្មអាចនឹងកោះហៅប្រជុំបន្ថែម ប្រសិនបើចាំបាច់។

៨.គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាន

គោលបំណងនៃគណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាន គឺទទួលខុសត្រូវក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើបញ្ហាបច្ចេកវិទ្យាព័ត៌មាន ហេដ្ឋារចនាសម្ព័ន្ធ សេវាកម្ម ការដាក់ដំណើរការ ការអនុវត្តន៍ ការគ្រប់គ្រង និងត្រួតពិនិត្យឡើងវិញនូវគោលនយោបាយ ការអនុវត្តន៍គោលការណ៍ណែនាំ និងគម្រោងនៃបច្ចេកវិទ្យា ក្នុងមានគោលបំណងដើម្បីសម្រេចបាននូវតម្រូវការអាជីវកម្ម និងការបង្កើនធនធានក្នុងការកាត់បន្ថយហានិភ័យ។

សមាជិក

ប្រធាននាយកប្រតិបត្តិបច្ចេកវិទ្យាព័ត៌មានស្តីទី	ប្រធាន
ប្រធាននាយកប្រតិបត្តិ	អនុប្រធាន
ប្រធាននាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ	សមាជិក
ប្រធាននាយកប្រតិបត្តិប្រតិបត្តិការ	សមាជិក
ប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ	សមាជិក
ប្រធាននាយិកាប្រតិបត្តិពាណិជ្ជកម្ម និងអភិបាលសាខា	សមាជិក
នាយកប្រតិបត្តិប្រព័ន្ធបណ្តាញធនាគារអេឡិចត្រូនិច	សមាជិក
ប្រធានផ្នែកផ្គត់ផ្គង់ប្រព័ន្ធគោល និងអភិវឌ្ឍរបាយការណ៍ព័ត៌មានវិទ្យា	លេខាកត់ត្រា

សមាជិកដទៃទៀតត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំនៅពេលមានករណីពាក់ព័ន្ធ។

កិច្ចប្រជុំ

កិច្ចប្រជុំនេះត្រូវរៀបចំ និងធ្វើឡើងតាមការស្នើសុំពីប្រធាននៃគណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាន។

ការគ្រប់គ្រង ហានិភ័យ

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ នូវតែបន្តការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការកសាងប្រព័ន្ធគ្រប់គ្រងហានិភ័យប្រកបដោយសុវត្ថិភាព ដែលមានឯករាជ្យភាព និងរួមបញ្ចូលការអនុវត្តន៍បែបអន្តរជាតិ ស្របតាមគោលដៅយុទ្ធសាស្ត្ររបស់ធនាគារ។ ការគ្រប់គ្រងហានិភ័យរបស់ធនាគារត្រូវបានត្រួតពិនិត្យដោយផ្ទាល់ពីគណៈកម្មាធិការត្រួតពិនិត្យហានិភ័យ នៃក្រុមប្រឹក្សាភិបាលរបស់ធនាគារ ហើយមុខងារមួយនេះ ត្រូវបានគ្របដណ្តប់លើសកម្មភាពគ្រប់គ្រងហានិភ័យទាំងមូលរបស់ធនាគារ។

ប្រព័ន្ធគ្រប់គ្រងហានិភ័យរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ផ្តើមចេញពីការកំណត់ហានិភ័យរបស់ធនាគារ ដែលត្រូវបានធ្វើឡើងដោយក្រុមប្រឹក្សាភិបាល និងស្របតាមយុទ្ធសាស្ត្រអាជីវកម្មរបស់ធនាគារដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងវត្ថុបំណងច្បាស់លាស់។ ប្រព័ន្ធនេះក៏មានតួនាទីក្នុងការពង្រឹងវប្បធម៌ហានិភ័យរបស់ធនាគារតាមរយៈ "tone from the top" ដែលបញ្ជាក់យ៉ាងច្បាស់ពីហានិភ័យដែលធនាគារនឹងត្រូវប្រកាន់យក។ អាស្រ័យហេតុនេះ ហានិភ័យវត្ថុធាតុដើមរួមមាន ហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ ហានិភ័យសន្ទនីយភាព និងហានិភ័យទីផ្សារត្រូវបានត្រួតពិនិត្យ និងកាត់បន្ថយឱ្យកាន់តែមានប្រសិទ្ធភាពដើម្បីធានាថា ធនាគារអាចរក្សាបាននូវមូលធនសេដ្ឋកិច្ច ការគ្រប់គ្រងដើមទុន សន្ទនិយភាព និងបទប្បញ្ញត្តិផ្សេងៗទៀត។

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ មានអនុគណៈកម្មាធិការគ្រប់គ្រងមួយចំនួនរួមមាន CC (គណៈកម្មាធិការឥណទាន) សម្រាប់ការគ្រប់គ្រងហានិភ័យឥណទាន និងផលប័ត្រឥណទាន ALCO (គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល) សម្រាប់ការគ្រប់គ្រងអត្រាការប្រាក់ និងការគ្រប់គ្រងហានិភ័យសន្ទនិយភាព និង ORMC (គណៈកម្មាធិការគ្រប់គ្រងហានិភ័យប្រតិបត្តិការ) សម្រាប់ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ ដែលរាប់បញ្ចូលទាំងហានិភ័យប្រតិបត្តិតាម ហានិភ័យនីតិកម្ម ហានិភ័យសុវត្ថិភាពព័ត៌មាន ហានិភ័យការលួចបន្លំ និងហានិភ័យនៃការលាងលុយកខ្វក់ជាដើម។ ធនាគារបានគ្រប់គ្រងការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការកាត់បន្ថយហានិភ័យដែលកំពុងស្វែងចេញតាមរយៈដំណើរការ នៃអភិបាលកិច្ចផ្ទៃក្នុងដោយប្រើឧបករណ៍គ្រប់គ្រងហានិភ័យ និងដំណើរការគ្រប់គ្រងហានិភ័យ។ការឆ្លោះទៅរកការកំណត់អត្តសញ្ញាណ និងការវាយតម្លៃនៃផលប៉ះពាល់របស់ធនាគារ គឺមានគោលបំណងដើម្បីធានាថាធនាគារនឹងកាត់បន្ថយផលប៉ះពាល់នៃហានិភ័យទាំងនេះ ដែលជះឥទ្ធិពលលើលទ្ធផលហិរញ្ញវត្ថុគោលដៅយុទ្ធសាស្ត្ររយៈពេលវែង និងកេរ្តិ៍ឈ្មោះរបស់ធនាគារ។

ផ្អែកលើការវិភាគរបស់ធនាគារ ហានិភ័យផលប័ត្រត្រូវបានត្រួតពិនិត្យឡើងវិញដោយប្រើការវាយតម្លៃហានិភ័យតាមបែបប្រពៃណី និងការវិភាគសេណារីយ៉ូម៉ាក្រូសេដ្ឋកិច្ច និងនយោបាយ។ វិធីសាស្ត្រទាំងពីរយ៉ាងនេះធ្វើឱ្យធនាគារមើលឃើញពីហានិភ័យ ដែលមានឥទ្ធិពលគ្របដណ្តប់លើហានិភ័យរបស់ធនាគារក៏ដូចជាការជាប់ទាក់ទងទៅនឹងផលប័ត្រជាក់លាក់។

ធនាគារប្តេជ្ញាបន្តពង្រឹងសមត្ថភាព និងការគ្រប់គ្រងហានិភ័យជាមួយនឹងការពង្រឹងនីតិវិធីហានិភ័យ គោលនយោបាយហានិភ័យ ឧបករណ៍គ្រប់គ្រងហានិភ័យ ការវិភាគហានិភ័យ និងរបាយការណ៍ហានិភ័យ។ ទន្ទឹមនឹងនេះ នីតិវិធីនៃការគាំទ្រ និងការត្រួតពិនិត្យឥណទានរបស់ធនាគារក៏ដូចជាគោលនយោបាយឥណទានក៏ត្រូវបានត្រួតពិនិត្យឡើងវិញយ៉ាងទៀងទាត់ និងត្រូវបានកែលម្អដើម្បីធ្វើឱ្យមានតុល្យភាពរវាងល្បឿន សាច់ប្រាក់ និងការគ្រប់គ្រងហានិភ័យរួមជាមួយនឹងការផ្លាស់ប្តូរបទប្បញ្ញត្តិផ្សេងៗ។ ចំណេះដឹងហានិភ័យត្រូវបានបង្ហាញឡើងតាមរយៈការបណ្តុះបណ្តាលផ្ទៃក្នុង។ តាមរយៈការអនុវត្តន៍ឥតឈប់ឈរក្នុងការលើកកម្ពស់គុណភាពផលប័ត្រ ធនាគារបានធ្វើការគ្រប់គ្រងអត្រា NPL បានយ៉ាងល្អ ទោះបីជាមានកំណើនឥណទានទាបជាងឆ្នាំមុនៗ នៅក្នុងបរិយាកាសទីផ្សារដែលមានការប្រកួតប្រជែងក៏ដោយ។

ការគ្រប់គ្រងហានិភ័យឥណទាន

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានបង្កើតគោលនយោបាយឥណទានបម្រុងប្រយ័ត្ន និងប្រព័ន្ធគ្រប់គ្រងព័ត៌មានដ៏រឹងមាំសម្រាប់ផលិតផលឥណទាន អតិថិជន និងការអនុវត្តន៍បច្ចេកទេសវាស់វែងហានិភ័យកម្រិតខ្ពស់។ គ្រប់បណ្តាផលិតផលឥណទានរបស់ធនាគារត្រូវបានគ្រប់គ្រងដោយកម្មវិធីមួយប្រភេទ ដែលត្រូវបានបង្កើតឡើងដោយផ្អែកលើតម្រូវការរបស់អតិថិជន និងត្រូវបានអនុម័តដោយគណៈកម្មាធិការក្រុមប្រឹក្សាភិបាល ហើយកម្មវិធីទាំងនេះត្រូវបានត្រួតពិនិត្យឡើងវិញ ជាប្រចាំសម្រាប់ការអនុវត្តន៍និងការកាត់បន្ថយហានិភ័យ។ផលប័ត្រឥណទានត្រូវបានត្រួតពិនិត្យជាប្រចាំដោយផ្អែកលើគន្លឹះ នៃផលប័ត្រខុសៗគ្នាដើម្បីធានាថាប្រតិបត្តិការរបស់ធនាគារស្ថិតនៅក្នុងព្រំដែនដែលបានកំណត់។ គោលនយោបាយឥណទានទាំងអស់ត្រូវបានរាយការណ៍ ទៅគណៈកម្មាធិការក្រុមប្រឹក្សាដើម្បីអនុម័ត។ ធនាគារមានរបាយការណ៍ផលប័ត្រប្រចាំថ្ងៃ ប្រចាំសប្តាហ៍ និងប្រចាំខែដើម្បីធ្វើការតាមដាន និងត្រួតពិនិត្យ ដូច្នេះធនាគារអាចចាត់វិធានទាន់ពេលវេលា និងអាចកាត់បន្ថយហានិភ័យឥណទានបាន។

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ តែងតែតាមដាន និងត្រួតពិនិត្យហានិភ័យដោយផ្អែកលើផលិតផល អតិថិជន និងអាជីវកម្ម -ល-។ យើងមានប្រព័ន្ធអនុម័តឥណទានឆាប់រហ័ស ដែលកំពុងដំណើរការសាកល្បង និងប្រព័ន្ធគ្រប់គ្រងការប្រមូលទិន្នន័យ គឺជិតបញ្ចប់រួចរាល់ជាស្ថាពរហើយ ដែលនឹងជួយក្នុងការសម្របសម្រួល ហានិភ័យសម្រាប់ដំណាក់កាលនីមួយៗនៃវដ្តឥណទាន។ ធនាគារមានគោលដៅចង់ក្លាយជាធនាគារ មួយដែលមានលទ្ធភាពគ្មានដែនកំណត់ដែលគាំទ្រ ដោយបច្ចេកវិទ្យាដើម្បីបង្កើនសមត្ថភាពក្នុងការបម្រើអតិថិជន ឱ្យកាន់តែមានភាពងាយស្រួលជាមួយនឹងបទពិសោធន៍ដ៏អស្ចារ្យ និងគួរជាទីគាប់ចិត្ត។

នៅឆ្នាំ២០១៩ សេដ្ឋកិច្ចពិភពលោកបានជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន ដែលធ្វើឱ្យមានការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចទាំងនៅក្នុងប្រទេសអភិវឌ្ឍន៍និងសេដ្ឋកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ក្នុងចំណោមបញ្ហាប្រឈមទាំងអស់ គឺបញ្ហាប្រឈមដ៏តានតឹងគឺការធ្វើសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងចិនដែលបណ្តាលឱ្យមានការធ្លាក់ចុះនៃពាណិជ្ជកម្ម និងការវិនិយោគអន្តរជាតិ។ ទន្ទឹមនឹងនេះការផ្លាស់ប្តូរអាកាសធាតុបានគំរាមកំហែងដល់កសិកម្ម និងជះឥទ្ធិពលយ៉ាងខ្លាំងដល់សេដ្ឋកិច្ចផងដែរ។ ម៉្យាងវិញទៀតបដិវាទកម្មនៅក្នុងប្រទេសមួយចំនួន ក៏បាននាំឱ្យមានភាពមិនច្បាស់លាស់លើផ្នែកនយោបាយ និងសេដ្ឋកិច្ច ស្របពេលដែលមិនទាន់ឈានដល់កិច្ចព្រមព្រៀងដកប្រាក់នៅឡើយ។ លើសពីនេះភាពជឿនលឿនផ្នែកបច្ចេកវិទ្យាបានបង្កើតទាំងឱកាស និងបញ្ហាប្រឈមជាពិសេសនៅក្នុងខ្សែសង្វាក់ផលិតកម្មទីផ្សារការងារ និងការតភ្ជាប់។

សេដ្ឋកិច្ចកម្ពុជាក៏ប្រឈមនឹងហានិភ័យមួយចំនួនដែរ ដែលរួមមានហានិភ័យ ពីខាងក្រៅដូចជា (ក) ការធ្លាក់ចុះនៃសេដ្ឋកិច្ចចិនលឿនជាងការរំពឹងទុកដែលជះឥទ្ធិពលដល់សេដ្ឋកិច្ចកម្ពុជា ដោយសារទំនាក់ទំនងជិតស្និទរវាងប្រទេសទាំងពីរ (ខ) ការអនុម័តគោលនយោបាយគាំពារនិយមក៏អាចប៉ះពាល់ដល់ការនាំចេញផងដែរ។ ហានិភ័យផ្ទៃក្នុងរួមមាន(ក) ការបាត់បង់សក្តានុពលនៃ "EBA" ដែលនឹងជះឥទ្ធិពលដោយផ្ទាល់ដល់ឧស្សាហកម្ម កាត់ដេរ និងវិស័យផ្សេងទៀតដែលទទួលបានផលប្រយោជន៍ដោយប្រយោលពីវិស័យនេះ (ខ) សន្ទុះនៃកំណើនឥណទានដ៏ច្រើនលើសលប់ក្នុងវិស័យសំណង់ក៏បានបង្កឱ្យហានិភ័យកើនឡើងនៅពេលដែលការផ្គត់ផ្គង់អចលនៈទ្រព្យកើនឡើងលើសតម្រូវការ (គ) ការផ្តល់ឥណទានទ្រព្យសកម្មពីក្រុមហ៊ុនអចលនទ្រព្យដែលមិនទាន់មានបទប្បញ្ញត្តិច្បាស់លាស់។

ធនាគារបានបង្កើតការវាយតម្លៃលផលប៉ះពាល់ នៃហានិភ័យសក្តានុពលដែលត្រូវបានដាក់បញ្ចូលទៅក្នុងស្ត្រេសតេស្ត (Stress Test) របស់ធនាគារដែលអាចវាយតម្លៃពីសមត្ថភាព ក្នុងការស្រូបយកគ្រប់ព្រឹត្តិការណ៍ទាំងអស់ប្រសិនបើវាកើតឡើង។ ធនាគារក៏បានត្រួតពិនិត្យឡើងវិញនូវគោលនយោបាយ និងនីតិវិធីសម្រាប់ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គមដើម្បីនិរន្តរភាពដែលស្របទៅនឹងការប្តេជ្ញាចិត្តរបស់ធនាគារចំពោះសង្គម ដែលយើងកំពុងប្រតិបត្តិការ។ ជាមួយបទប្បញ្ញត្តិនៃការអនុវត្តន៍ CIFRS ធនាគារបានធ្វើការអនុលោមតាម IFRS9 លើភាពចុះខ្សោយរួចជាស្រេចហើយ។

ការផ្តោតសំខាន់ជារួមលើការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងមូលធនក្នុងឆ្នាំ២០១៩ ត្រូវបានរក្សាទម្រង់នៃហានិភ័យរបស់ធនាគារឱ្យស្របតាមយុទ្ធសាស្ត្រហានិភ័យ និងការបង្កើនមូលដ្ឋានដើមទុនដើម្បីគាំទ្រគំនិតផ្តួចផ្តើមសម្រាប់គ្រប់គ្រងយុទ្ធសាស្ត្ររបស់ធនាគារ ដោយផ្តោតលើការបង្កើនប្រសិទ្ធភាពតារាងតុល្យការ។

ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានអនុវត្តគម្រោងគ្រប់គ្រងហានិភ័យប្រតិបត្តិការដែលស្ថិតក្រោមគោលនយោបាយគ្រប់គ្រងហានិភ័យប្រតិបត្តិការ។ ធនាគារមានប្រព័ន្ធសម្រាប់ការប្រមូលទិន្នន័យដែលបាត់បង់ និងមានសូចនាករហានិភ័យសំខាន់ៗ (KRIs) សម្រាប់អាជីវកម្មដើម្បីតាមដានហានិភ័យ។ លើសពីនេះទៀត ធនាគារបានអនុវត្តនូវសកម្មភាពវាយតម្លៃលើការត្រួតពិនិត្យហានិភ័យ(RCSAs) ដើម្បីជួយបង្កើតវប្បធម៌ក្នុងការគ្រប់គ្រងហានិភ័យប្រតិបត្តិការ នៅទូទាំងបណ្តាញប្រតិបត្តិការរបស់ធនាគារ។ កម្មវិធី RCSA កំពុងត្រូវបានដាក់ដំណើរការនៅគ្រប់មុខងារ និងបណ្តាញប្រតិបត្តិការសាខាទាំងអស់ ដើម្បីលើកកម្ពស់ការអនុវត្តន៍ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ។ ធនាគារកំពុងបន្តអនុវត្តជាបន្តបន្ទាប់ដើម្បីកាត់បន្ថយហានិភ័យដែលកំពុងកើតឡើងដូចជាហានិភ័យនៃអនុលោមភាព ហានិភ័យការលួចបន្លំ ហានិភ័យនៃដៃគូអាជីវកម្ម និងហានិភ័យបច្ចេកវិទ្យាជាដើម ដោយស្ថិតនៅក្រោមគម្រោងនៃការគ្រប់គ្រងហានិភ័យប្រតិបត្តិការដើម្បីធ្វើឱ្យមានភាពល្អិតល្អន់ និងសម្រេចបាននូវប្រសិទ្ធភាពខ្ពស់បំផុត។

ធនាគារក៏បានបង្កើតការធ្វើតេស្តលើគម្រោងនិរន្តរភាពអាជីវកម្ម (BCP) ពីរដងក្នុងកំឡុងឆ្នាំ២០១៩ រួមជាមួយការអនុវត្តន៍តាមរយៈការទំនាក់ទំនងតាមទូរស័ព្ទដើម្បីវាយតម្លៃលើសមត្ថភាព ដែលស្ថិតក្រោមព្រឹត្តិការណ៍ដែលមិនបានមើលឃើញទុកជាមុន។

ការគ្រប់គ្រងហានិភ័យសន្ទនីយភាព

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានធ្វើការតាមដានលើស្ថានភាពសន្ទនីយភាពជាមួយនឹងការត្រួតពិនិត្យមូលដ្ឋានរង្វាស់ដូចជា អនុបាតសាច់ប្រាក់ងាយរងគ្រោះ (LCR) និងការតាមដានជារៀងរាល់ថ្ងៃ។ លើសពីនេះទៅទៀត ធនាគារក៏បានត្រួតពិនិត្យលំហូរសាច់ប្រាក់ផងដែរដើម្បីធានាបាននូវអតិបរិមានៃសាច់ប្រាក់នៅក្នុងប្រតិបត្តិការធនាគារ។ ការអនុវត្តន៍ទាំងនេះបាននឹងកំពុងគាំទ្រដល់ធនាគារក្នុងការព្យាករណ៍ និងឆ្លើយតប ក្នុងសេណារីយ៉ូធម្មតា និងស្រេួស ឱ្យកាន់តែមានប្រសិទ្ធភាព ហើយវាក៏ជួយឱ្យធនាគាររក្សានូវលំនឹង សន្ទនីយភាពផងដែរ។ ធនាគារបានបង្កើតការវិភាគលើគម្លាតកាលកំណត់សម្រាប់ការគ្រប់គ្រងហានិភ័យទីផ្សារ ដើម្បីធានាបាននូវការផ្តល់មូលនិធិជាមួយនឹងកាលកំណត់ដែលត្រូវការ ដើម្បីកាត់បន្ថយគម្លាតអប្បបរមា។ ធនាគារក៏បានកំណត់មូលដ្ឋានគ្រឹះ សម្រាប់សកម្មភាពគ្រប់គ្រងដែលជាផ្នែកមួយនៃរបាយការណ៍ហានិភ័យ ក្នុងការឈានទៅរកការអនុវត្តន៍ប្រកបដោយសុវត្ថិភាពលើការគ្រប់គ្រងហានិភ័យសន្ទនីយភាព។

ក្នុងឆ្នាំ២០១៩ ធនាគារប្រៃសណីយ៍កម្ពុជា ក.អ រក្សាបាននូវសន្ទនីយភាពបានយ៉ាងល្អដោយអនុលោមតាមបទប្បញ្ញត្តិ។ ធនាគារក៏បានកំណត់មូលដ្ឋានគ្រឹះមួយចំនួនផងដែរ ដែលស្ថិតក្រោមរបាយការណ៍ហានិភ័យដើម្បីឈានទៅរកការអនុវត្តន៍ប្រកបដោយសុវត្ថិភាព ក្នុងការគ្រប់គ្រងហានិភ័យនៅដំណាក់កាលដំបូង។

ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យាព័ត៌មាន

ការលូតលាស់ និងរីកចម្រើននៃបច្ចេកវិទ្យាព័ត៌មានបាននាំមកនូវការផ្លាស់ប្តូរយ៉ាងឆាប់រហ័សលើអាជីវកម្ម និងប្រតិបត្តិការដែលកំពុងត្រូវបានអនុវត្តនៅក្នុងធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ។ ការគ្រប់គ្រងសុវត្ថិភាព និងការកំណត់អត្តសញ្ញាណនៃការគំរាមកំហែង បានក្លាយជាទិដ្ឋភាពចាំបាច់នៃការអនុវត្តន៍បច្ចេកវិទ្យា។ ប្រព័ន្ធហិរញ្ញវត្ថុ និងបណ្តាញគាំទ្រដល់ប្រតិបត្តិការអាជីវកម្មមានការរីកចម្រើន ក្នុងវិសាលភាពដ៏ធំធេងជាច្រើនឆ្នាំ ហើយបានផ្តល់ជូននូវភាពខុសគ្នានៃផលិតផល និងសេវាកម្មដែលមានប្រព័ន្ធប្រតិបត្តិការនៅតាមទីតាំងជាច្រើន និងត្រូវបានជួយជ្រោមជ្រែងពីអ្នកផ្តល់សេវាកម្មផ្សេងៗគ្នា។

ធនាគារយល់ច្បាស់ពីហានិភ័យ និងបានរៀបចំគោលការណ៍ណែនាំសម្រាប់គម្រោងគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានដូចខាងក្រោម៖

ក. ការបង្កើតគម្រោងគ្រប់គ្រងហានិភ័យបច្ចេកវិទ្យារឹងមាំ

ខ. ការពង្រឹងប្រព័ន្ធសុវត្ថិភាព ភាពជឿជាក់ ភាពរឹងមាំ និងការបង្កើតឡើងវិញ

គ. ការដំណើរការការផ្ទៀងផ្ទាត់ត្រឹមត្រូវ ដើម្បីការពារទិន្នន័យប្រតិបត្តិការ និងប្រព័ន្ធព័ត៌មានរបស់អតិថិជន

ធនាគារមិនត្រឹមតែធ្វើការគ្រប់គ្រង និងត្រួតពិនិត្យហានិភ័យនៃបច្ចេកវិទ្យាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើការតេស្តលើការជ្រៀតចូលដើម្បីធានាបាននូវភាពរឹងមាំនៃសុវត្ថិភាពប្រព័ន្ធរបស់ធនាគារ និងចាត់វិធានការយ៉ាងច្បាស់លាស់ដើម្បីបង្កើនសុវត្ថិភាពក្នុងការរក្សាប្រព័ន្ធឱ្យមានសុវត្ថិភាព។ យើងមានការគ្រប់គ្រងទិន្នន័យបម្រុងទុកសម្រាប់ការពារព័ត៌មានក៏ដូចជាការសង្គ្រោះគ្រោះមហន្តរាយបន្ថែមលើគេហទំព័រ BCP របស់យើង។

ធនាគារបានដំណើរការប្រព័ន្ធគ្រប់គ្រង ការប្រើប្រាស់របស់អតិថិជនដើម្បីធានាថាការគ្រប់គ្រងប្រើប្រាស់បានត្រឹមត្រូវនៅក្នុងធនាគារ។ ធនាគារក៏បានដំណើរការប្រព័ន្ធគ្រប់គ្រងការផ្លាស់ប្តូរសំណើនៅនឹងកន្លែង ដើម្បីធានាថារាល់ការផ្លាស់ប្តូរត្រូវបានវាយតម្លៃបានគ្រប់គ្រាន់មុនពេលដាក់ដំណើរការ។ ធនាគារបានដាក់ឱ្យប្រើប្រាស់នូវ ប្រព័ន្ធគ្រប់គ្រងហានិភ័យបច្ចេកវិទ្យាព័ត៌មានដើម្បីធ្វើការកំណត់អត្តសញ្ញាណ វិភាគ វាយតម្លៃ ឆ្លើយតប តាមដាន និងត្រួតពិនិត្យហានិភ័យឡើងវិញ។

ការប្រតិបត្តិតាម

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បាន ប្តេជ្ញាចិត្តអនុវត្តឱ្យបានល្អប្រសើរទៅតាមបទដ្ឋានទីផ្សារនៅក្នុងតំបន់ ដែលប្រកបដោយគណនេយ្យភាព តម្លាភាព និងក្រមសីលធម៌ក្នុងការប្រកបអាជីវកម្មដើម្បីលើកកម្ពស់នូវនិរន្តរភាព។ អភិបាលកិច្ចល្អ និងការរួមចំណែកទទួលខុសត្រូវនៅក្នុងសង្គមជាផ្នែកនៅក្នុងការបង្កើតបាននូវទីផ្សារស្តង់ដារ។ ចំណុចស្នូលនៃកិច្ចប្រឹងប្រែងទាំងនេះគឺសំដៅដល់សុចរិតភាព និងហានិភ័យកេរ្តិ៍ឈ្មោះរបស់ធនាគារដែលត្រូវប្រឈមនៅក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួន។ ដើម្បីគ្រប់គ្រងនូវបញ្ហាទាំងនេះ ធនាគារបានបង្កើតនូវមុខងារប្រតិបត្តិតាមឯករាជ្យមួយ។ ធនាគារបានបង្កើតគោលការណ៍ប្រតិបត្តិតាមក្នុងគោលបំណងដើម្បីបង្ហាញជូនអំពីការកំណត់នូវតួនាទី និងភារកិច្ច ព្រមទាំងការទទួលខុសត្រូវរបស់មុខងារប្រតិបត្តិតាមចំពោះការគ្រប់គ្រងហានិភ័យប្រតិបត្តិតាមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ។ គោលការណ៍នេះ ត្រូវបានធ្វើបច្ចុប្បន្នកម្មដែលអនុម័តដោយក្រុមប្រឹក្សាភិបាល និងបានចូលជាធរមាននៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩។ គោលការណ៍នេះ ត្រូវពិនិត្យឡើងវិញយ៉ាងហោចណាស់រៀងរាល់មួយឆ្នាំម្តង ឬតាមចាំបាច់ ដើម្បីឆ្លើយតបទៅនឹងឧត្តមភាពទីផ្សារ និងការអនុវត្តន៍ដ៏ល្អបំផុតស្របតាមបរិបទអាជីវកម្មរបស់ធនាគារ ការវិវឌ្ឍន៍នៃច្បាប់ និងបទប្បញ្ញត្តិ។ ការអនុវត្តន៍មុខងារប្រតិបត្តិតាមមានដូចខាងក្រោម៖

ក. ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT):

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានប្តេជ្ញាចិត្តយ៉ាង មុតមាំក្នុងការប្រឆាំងនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ធនាគារបានបង្កើតនូវគោលការណ៍ និងនីតិវិធីស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលអនុលោមទៅតាមច្បាប់ និងប្រកាសស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ គ្រប់បុគ្គលិកទាំងអស់ដែលពាក់ព័ន្ធត្រូវបានបណ្តុះបណ្តាលដើម្បីអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍ និងនីតិវិធីនេះ។

ខ. ការប្រតិបត្តិតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ:

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានប្រកាន់ខ្ជាប់យ៉ាងពេញលេញទៅនឹងការគោរពទៅតាមច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ។ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានបង្កើតបញ្ជីត្រួតពិនិត្យការប្រតិបត្តិតាមដើម្បីវាយតម្លៃទៅលើការអនុវត្តន៍របស់ធនាគារ។ នាយកដ្ឋាននីតិកម្ម និងប្រតិបត្តិតាមរួមធនាគារ គឺជាអ្នកសម្របសម្រួល និងត្រួតពិនិត្យលើការអនុវត្តន៍របស់ធនាគារទាំងមូលក្នុងការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។

គ. និវេទនកម្ម:

ធនាគារបានប្តេជ្ញាចិត្តក្នុងការថែរក្សា និងសម្រេចឱ្យបាននូវបទដ្ឋានខ្ពស់បំផុតក្នុងការបើកចំហទៅលើការបញ្ចេញមតិសុចរិតភាពនិងគណនេយ្យភាព។ ភាគីពាក់ព័ន្ធ ឬបុគ្គលិក នៅគ្រប់កម្រិតទាំងអស់ត្រូវបានអនុញ្ញាតឱ្យចូលរួមអនុវត្តដោយភាពស្មោះត្រង់មិនលំអៀង និងសុចរិតភាពប្រកបដោយប្រសិទ្ធភាព។ ការអនុវត្តន៍នេះត្រូវបានពង្រឹងនៅក្នុងធនាគារទាំងមូល ដោយលើកទឹកចិត្តបុគ្គលិកធនាគារឱ្យរាយការណ៍ពីបញ្ហាសំខាន់ៗដោយគ្មានការរារាំងដូចជា៖

- ការរំលោភលើច្បាប់ ឬបទប្បញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធ
- ការអនុវត្តន៍មិនត្រឹមត្រូវ កំហុសឆ្គង ឬការកែបន្លំដែលទាក់ទងទៅនឹងការត្រួតពិនិត្យផ្ទៃក្នុង គណនេយ្យ សវនកម្ម និងបញ្ហាហិរញ្ញវត្ថុផ្សេងៗ
- គ្រោះថ្នាក់សុខភាព និងសុវត្ថិភាពរបស់បុគ្គល
- ការរំលោភលើច្បាប់នៃការអនុវត្តន៍ការងារនៅក្នុងធនាគារ
- ការបិទបាំងដោយចេតនានូវចំណុចណាមួយដែលបានរៀបរាប់ខាងលើ
- ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌការរំលោភបំពានច្បាប់រដ្ឋប្បវេណី និងការផ្តល់យុត្តិធម៌មិនបានត្រឹមត្រូវ
- ទំនាស់ផលប្រយោជន៍
- ការខូចខាតដែលប៉ះពាល់ដល់បរិស្ថាន
- ការប្រព្រឹត្តមិនត្រឹមត្រូវ ឬឥរិយាបថដែលគ្មានក្រមសីលធម៌ ដែលអាចជាផលប៉ះពាល់ដល់គោលជំហររបស់ធនាគារ

ឃ. ការដោះស្រាយបណ្តឹងរបស់អតិថិជន:

ធនាគារ បានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការផ្តល់ជូន នូវសេវាកម្មដ៏ល្អបំផុតជូនដល់អតិថិជន។ ធនាគារបានបង្កើតនូវគោលនយោបាយ ការដោះស្រាយបណ្តឹងរបស់អតិថិជន ដើម្បីផ្តល់នូវការដោះស្រាយបណ្តឹងរបស់អតិថិជនប្រកបដោយយុត្តិធម៌ ប្រសិទ្ធភាព និងមានគុណភាពឱ្យអនុលោមទៅតាមប្រកាសលេខ ធ-៧០១៧-២៩៩ ប្រ.ក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថាន ធនាគារ និងហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។ គោលនយោបាយនេះគឺដាក់ឱ្យប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងធនាគារទាំងមូល ដែលទាក់ទងទៅនឹងផលិតផល សេវាកម្ម បុគ្គលិក និងការដោះស្រាយបណ្តឹង។

ង. ការប្រតិបត្តិតាមអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់បុគ្គលអាមេរិក:

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ក៏បានអនុវត្តផងដែរនូវកម្មវិធី FATCA។ បច្ចុប្បន្ននេះ FATCA ត្រូវបានក្លាយទៅជាច្បាប់នៅក្នុងស្រុកដោយសារតែរាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលតាមគំរូ IB (IGA IB) ជាមួយរដ្ឋាភិបាលសហរដ្ឋអាមេរិកនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥។ ដូច្នេះស្ថិតក្រោមកិច្ចព្រមព្រៀង IGA នេះមានន័យថា រាជរដ្ឋាភិបាល និងស្ថាប័នហិរញ្ញវត្ថុត្រូវមានកាតព្វកិច្ចអនុវត្តទៅតាមរាល់បទប្បញ្ញត្តិរបស់ FATCA។ ការរាយការណ៍ចំពោះគណនីជនជាតិអាមេរិកជាមួយស្ថាប័នហិរញ្ញវត្ថុ និងធនាគារ គឺស្ថិតនៅក្រោមយុត្តាធិការនៃកម្ពុជាដែលតម្រូវឱ្យធ្វើរបាយការណ៍ទៅអគ្គនាយកដ្ឋានពន្ធដារ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដូចនេះដើម្បីអនុវត្តតាមច្បាប់អនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់បុគ្គលអាមេរិកធនាគារបានដាក់ចេញគោលការណ៍ណែនាំដូចខាងក្រោម៖

- សេចក្តីសម្រេច លេខធបក ១៦៣/១៥ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវគោលការណ៍ប្រតិបត្តិស្តីពីអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់បុគ្គលអាមេរិក (FATCA)
- បន្ថែមពីលើនេះទៅទៀត ធនាគារបានបង្កើតឱ្យមាននូវគណៈកម្មាធិការសម្រាប់ FATCA នេះដែលមានសមាសភាពពីគណៈគ្រប់គ្រងជាន់ខ្ពស់នៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ដែលជាអ្នកបង្កើតប្រព័ន្ធរបាយការណ៍ FATCA នេះឡើង។

សមិទ្ធផលសម្រេចបាន
(របាយការណ៍រួម)

សមតុល្យឥណទាន
៦៦៧លានដុល្លារ



ប្រាក់ចំណូលសរុប
៨៨លានដុល្លារ



ទ្រព្យសកម្មសរុប
៨២៤លានដុល្លារ



ប្រាក់ចំណេញ
២០លានដុល្លារ



*២០១៥-២០១៧: ស្តង់ដារគណនេយ្យអន្តរជាតិ នៃកម្ពុជា
*២០១៨-២០១៩: ស្តង់ដាររបាយការណ៍ទាក់ទង និងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា

*២០១៥-២០១៧: ស្តង់ដារគណនេយ្យអន្តរជាតិ នៃកម្ពុជា
*២០១៨-២០១៩: ស្តង់ដាររបាយការណ៍ទាក់ទង និងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា

រចនាសម្ព័ន្ធអង្គភាព



សេចក្តីថ្លែងការណ៍ ប្រធានក្រុមប្រឹក្សាភិបាល

" ការដាក់ចេញនូវយុទ្ធសាស្រ្តបង្ហាញផ្លូវដើម្បី ក្លាយជាស្ថាប័នផ្តល់សេវាហិរញ្ញវត្ថុឈានមុខគេ នៅកម្ពុជាប្រកបទៅដោយភាពឆ្លាតវៃ ការឆ្លើយតបខ្ពស់ កាលានុវត្តភាព និងបច្ចេកវិទ្យាឌីជីថល "

ក្នុងនាមជាធនាគារមួយដែលកំពុងដំណើរការឥតឈប់ឈរ យើងកំពុងធ្វើការផ្លាស់ប្តូរដ៏ធំមួយក្នុងគោលបំណងដើម្បីសម្រេចនូវមហិច្ឆតារបស់យើង ដើម្បីក្លាយខ្លួនជាធនាគារឌីជីថលឈានមុខគេនៅក្នុងប្រទេសកម្ពុជា។ យើងបានប្រើប្រាស់ដើមទុនជាច្រើនក្នុងអាជីវកម្ម ដើម្បីសម្រេចគោលដៅឱ្យកាន់តែរីកចម្រើនបំផុត ក្នុងសេដ្ឋកិច្ចទីផ្សារ អាស៊ីអាគ្នេយ៍នាពេលបច្ចុប្បន្ននេះ។

ក្នុងកំឡុងឆ្នាំ២០១៩ យើងបានប្រកាន់គោលជំហរដើម្បីផ្តល់ជូនបុគ្គលិកទាំងអស់នូវរង្វាន់លើកទឹកចិត្ត និងការបណ្តុះបណ្តាលដែលមានលក្ខណៈទូលំទូលាយ យុទ្ធសាស្រ្ត និងការកំណត់យ៉ាងច្បាស់។ ជាការពិតប្រភេទនៃការធ្វើសមាហរណកម្មជម្រុញ ដោយការផ្លាស់ប្តូរមិនអាចត្រូវបានសម្រេចចិត្តក្នុងរយៈពេលមួយសប្តាហ៍ឬរយៈពេលពីរបីខែទេ។ ផ្ទុយទៅវិញ ការធ្វើឱ្យមានផលប៉ះពាល់កើនឡើងជារៀងរាល់ថ្ងៃជាមួយនឹងគោលបំណងដើម្បី សម្រេចបាននូវការផ្លាស់ប្តូររួមមួយក្នុងរយៈពេលមួយច្បាស់លាស់។ ដូច្នេះនៅឆ្នាំ២០១៩ យើងបានដាក់ផែនការយុទ្ធសាស្រ្តរបស់យើង ដើម្បីកសាងស្ថាប័នហិរញ្ញវត្ថុឈានមុខគេនៅកម្ពុជាដែលមានភាពរហ័ស ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពឱកាសនិយម និងបច្ចេកវិទ្យាឌីជីថល។ នាឆ្នាំ២០១៩ ជាពេលវេលាដែលយើងដាំគ្រាប់ពូជ។ អ្វីដែលផ្តល់ឱ្យខ្ញុំនូវទំនុកចិត្តដែលអាចឱ្យយើងនឹងទទួលបាននូវភាពជោគជ័យក្នុងរយៈពេលវែង គឺការពិតដែលថាសព្វថ្ងៃនេះ យើងមានតារាងតុល្យការលើសពី ៨២៤ លានដុល្លារអាមេរិក និងយើងទទួលបានមូលធនប័ត្រត្រឹមត្រូវ។ យើងបានបម្រើអតិថិជនជាង ១00,000 នាក់នៅតាមខេត្តចំនួន ១៩ ទូទាំងប្រទេស ទោះបីជាយើងជឿជាក់ថានឹងមានវិសាលភាពធំធេងក្នុងការពង្រីកប្រតិបត្តិការ ក៏យើងនូវតែមានការជួយជ្រោមជ្រែងពីបច្ចេកវិទ្យាដ៏រឹងមាំរបស់យើងផងដែរ។

សេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្នមានកំណើន ៧ ភាគរយក្នុងរយៈពេល ៥ឆ្នាំជាប់ៗគ្នា។ ទោះជាយ៉ាងណាក៏ដោយការរក្សាបាន និងបង្កើនល្បឿននៃកំណើននេះ គឺជាបញ្ហាប្រឈមមួយនៅក្នុងចំណោមភាពងាយរងគ្រោះដែលកំពុងកើនឡើង និងភាពមិនច្បាស់លាស់ដែលកំពុងកើនឡើង។ ទោះយ៉ាងណាក្តីធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានបង្ហាញឱ្យឃើញពីភាពខ្លាំង និងភាពរឹងមាំដើម្បីផ្តល់តម្លៃដល់អ្នកពាក់ព័ន្ធទាំងអស់។ នៅឆ្នាំ២០១៩ យើងទទួលបានវឌ្ឍនភាពគួរឱ្យកោតសរសើរក្នុងការអភិវឌ្ឍន៍ធនាគារ ដែលបានផ្តល់ភាពងាយស្រួលសុវត្ថិភាព និងការយកចិត្តទុកដាក់ខ្ពស់លើអតិថិជន និងសូមអរគុណចំពោះការដឹកនាំប្រកបដោយភាពឆ្លាតវៃ ដែលបានដើរតួនាទីជាកាតាលីករដ៏សំខាន់ក្នុងការគ្រប់គ្រងធនាគារប្រឈមនឹងបញ្ហាជាច្រើន។

ដោយសង្កេតឃើញថាមានការកើនឡើងនៃធនាគារឌីជីថល យើងបានធ្វើការអភិវឌ្ឍន៍ឱ្យកាន់តែប្រសើរឡើង នូវហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា និងប្រព័ន្ធឥណទានមួយចំនួន ដោយផ្តោតសំខាន់លើកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈររបស់ធនាគារក្នុងការអភិវឌ្ឍន៍ និងការកែលម្អ។ ក្នុងឆ្នាំ២០១៩ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សម្រេចបាននូវសមិទ្ធផលគួរជាទីគាប់ប្រសើរ ជាមួយបណ្តាញប្រតិបត្តិការសាខាទូទាំងប្រទេសរហូតដល់ ៥១ សាខា ម៉ាស៊ីនអេធីអឹម ៦០ គ្រឿង និងបណ្តាញចែកចាយសេវាកម្មជាច្រើនផ្សេងទៀត។ យើងក៏រក្សាបាននូវសាច់ប្រាក់ងាយស្រួល និងជំហរមូលធនពេញមួយឆ្នាំ។

ក្នុងនាមជាអ្នកផ្តល់ហិរញ្ញប្បទាន ប្រកបដោយទំនួលខុសត្រូវនៅក្នុងប្រទេសកម្ពុជា យើងប្តេជ្ញាចិត្តចំពោះបរិស្ថានជុំវិញ និងនិរន្តរភាពផងដែរ។ យើងបានដាក់បញ្ចូលគោលនយោបាយគ្រប់គ្រងបរិស្ថាន និងសង្គមរួចហើយដើម្បីទទួលបាននិរន្តរភាពក្នុងប្រតិបត្តិការរបស់យើង។

ការប្រឈមមុខនឹងការប្រកួតប្រជែងពេញមួយឆ្នាំ យើងបានបង្ហាញឱ្យឃើញពីសមិទ្ធផលដ៏អស្ចារ្យដែលឆ្លុះបញ្ចាំងពីភាពខ្លាំង និងភាពធន់នៃសិទ្ធិអាជីវកម្មរបស់យើង។ នេះសបញ្ជាក់ថាយុទ្ធសាស្រ្តរបស់យើងកំពុងតែបន្តដំណើរការ។ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ទទួលបានសន្ទុះកំណើនផលប័ត្រ ជាមួយនឹងសមាមាត្រប្រាក់ចំណេញខ្ពស់បំផុតក្នុងឆ្នាំ២០១៩។ទំហំទ្រព្យសកម្មសរុបរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ មានចំនួន ៨២៤ លានដុល្លារអាមេរិកគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។ ជាមួយនឹងការកើនឡើង ២៣% នៃប្រាក់ចំណូលប្រតិបត្តិការសរុបលើឆ្នាំ២០១៨ ប្រាក់ចំណេញមុនពេលបង់ពន្ធមានចំនួន ២៦ លានដុល្លារអាមេរិកដែលបានកើនឡើងចំនួន ៥ លានដុល្លារអាមេរិក (២៥%) ជាងឆ្នាំ២០១៨ ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វូណាន ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារក៏បានទទួលកំណើននៅឆ្នាំ២០១៩ ដែលផលប័ត្រនៃឥណទានបានកើនឡើងដល់ ៥៦ លានដុល្លារអាមេរិក នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ (កើនឡើង ២០ ភាគរយលើឆ្នាំ២០១៨)។ ប្រាក់ចំណូលប្រតិបត្តិការសុទ្ធបានកើនឡើងប្រហែល ១៩% នៅក្នុងឆ្នាំ២០១៩ ដែលប្រាក់ចំណេញសុទ្ធបានកើនឡើងដល់ ៣ លានដុល្លារអាមេរិក បើធៀបនឹងឆ្នាំមុនត្រឹមតែ ២ លានដុល្លារអាមេរិក។

ជាមួយចក្ខុវិស័យរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ "ដើម្បីក្លាយជាធនាគារផ្តល់សេវាហិរញ្ញវត្ថុឈានមុខគេជូនអតិថិជនគ្រប់កម្រិតដើម្បីលើកកម្ពស់ជីវភាព និងជួយបំពេញបំណងភាពរីកចម្រើនរបស់ប្រជាជនកម្ពុជា ហើយបង្កើតតម្លៃជានិរន្តដល់ភាគទុនិក បុគ្គលិក និងសង្គមផង" យើងតែងតែប្តេជ្ញាចិត្តចំពោះសង្គមដែលយើងកំពុងធ្វើប្រតិបត្តិការ។

តាមទស្សនៈរបស់ខ្ញុំភាពរីកចម្រើនដែលធនាគារសម្រេចបាន គឺជាសក្ខីកម្មរបស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកគ្រប់រូបរបស់ធនាគារដែលកើតចេញពីការគ្រោងទុកជាមុន និងការប្រកាន់ខ្ជាប់នូវការផ្លាស់ប្តូរ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសហការីរបស់ខ្ញុំ សម្រាប់ដំបូន្មានដ៏មានតម្លៃរបស់ពួកគេ ដែលបានរួមចំណែកដល់លទ្ធផលគួរជាទីគាប់ប្រសើរសម្រាប់ធនាគារនៅឆ្នាំ២០១៩។ ខ្ញុំសូមថ្លែងអំណរគុណចំពោះស្ថាប័នជាប់ពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសអគ្គនាយកដ្ឋានពន្ធដារ នៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ការជួយជ្រោមជ្រែង។ ខ្ញុំសូមថ្លែងអំណរគុណដល់អតិថិជនរបស់ធនាគារទាំងអស់ចំពោះការជឿទុកចិត្ត និងការគាំទ្រដែលមិនផ្លាស់ប្តូរ។ ជាកិច្ចបញ្ចប់ខ្ញុំសូមអរគុណដល់បុគ្គលិករបស់ធនាគារទាំងអស់ សម្រាប់ការខិតខំប្រឹងប្រែងរយៈពេលមួយឆ្នាំនៃការបំពេញការងារ។

ដោយឈរលើមហិច្ឆតារបស់យើង ក្នុងការក្លាយជាអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុឈានមុខគេនៅកម្ពុជា នូវតែត្រូវបានពង្រឹងបន្ថែមទៀតនាពេលបច្ចុប្បន្ន។ យើងនៅតែប្តេជ្ញាចិត្តចំពោះភាពជោគជ័យនៃប្រតិបត្តិការរបស់យើងនៅទូទាំងប្រទេសហើយនឹងបន្តផ្តោតលើការជួយជ្រោមជ្រែងដល់ប្រជាជនរបស់យើង និងបម្រើអតិថិជនរបស់យើងដោយនាំមកនូវអ្វីដែលល្អបំផុតដល់ពួកគេគ្រប់ពេលវេលា។

អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ

ប្រធានក្រុមប្រឹក្សាភិបាល

“ ការកំណត់យុទ្ធសាស្ត្រឆ្ពោះទៅរកគោលដៅក្លាយជាមគ្គុទេសទីផ្សារក្នុងវិស័យ MSME ”

សេចក្តីថ្លែងការណ៍ពីប្រធាននាយកប្រតិបត្តិ

ត្រឹមតែរយៈពេល ៦ឆ្នាំ នៃប្រតិបត្តិការ ធនាគារត្រូវបានគេទទួលស្គាល់នៅក្នុង ឧស្សាហកម្មហិរញ្ញវត្ថុនៅកម្ពុជា ថាជាធនាគារទី ១០ ផ្អែកលើទ្រព្យសកម្ម និងធនាគារទី ៥ ផ្អែកលើបណ្តាញសាខា ដែលមានកំណើនប្រកបដោយចីរភាពក្នុងចំណោមធនាគារពាណិជ្ជធំៗទូទាំងប្រទេស។

ជាកិច្ចចាប់ផ្តើម ខ្ញុំសូមថ្លែងអំណរគុណដល់បុគ្គលិកគ្រប់រូបរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ដែលតែងតែខិតខំប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការបំពេញការងារ ព្រមទាំងក្រុមប្រឹក្សាភិបាលរបស់ធនាគារដែលតែងតែបន្តគាំទ្រ និងផ្តល់ការណែនាំ។ ក្រោមភាពជាដៃគូយុទ្ធសាស្ត្ររវាងកាណាឌីយ៉ា អ៊ិនវេសមិនហូឌីង ហ្វទ្បីតុនហ្វាយណាន់ស៊ល្យហ្វូលឌីង និងប្រៃសណីយ៍កម្ពុជានៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា។ ធនាគារមានឯកសិទ្ធិពេញលេញក្នុងការផ្តល់ជូនសេវាកម្ម ប្រកបដោយនិរន្តរភាពដល់អតិថិជនគ្រប់កម្រិតជីវភាព។

ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ធនាគារបានផ្លាស់ប្តូរយុទ្ធសាស្ត្រដើម្បីប្រឈមមុខនឹងទិដ្ឋភាពដែលទាក់ទងនឹងការកំណត់អត្តសញ្ញាណ និងការអនុវត្តន៍ទូទៅរបស់ធនាគារ។ ដើម្បីសម្រេចគោលដៅនេះ ធនាគារបានត្រៀមប្រឈមនឹងបញ្ហាដែលនឹងកើតមានឡើងនាពេលខាងមុខ និងការកំណត់គោលដៅដើម្បីក្លាយជាធនាគារឌីជីថលឈានមុខគេនៅក្នុងប្រទេស។

សព្វថ្ងៃនេះ ទោះបីធនាគារបានធ្វើដំណើរមកដល់ឆ្ងាយយ៉ាងណាក្តី ក៏ធនាគារនៅតែបន្តដំណើរឆ្ពោះទៅមុខទៀត។ ទោះយ៉ាងណា ខ្ញុំពិតជាមានមោទនភាពចំពោះភាពរីកចម្រើនរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ។ ជាមួយនឹងជោគវាសនាដែលមាននៅក្នុងដៃ ធនាគារនឹងបន្តប្រើប្រាស់មូលដ្ឋានគ្រឹះដ៏រឹងមាំមួយនេះក្នុងការវិនិយោគដើម្បីសម្រេចបាននូវកំណើនប្រកបដោយចីរភាពនាឆ្នាំខាងមុខៗទៀត។

ក្នុងរយៈពេលត្រឹមតែ ៣ឆ្នាំ ធនាគារទទួលបានប្រាក់ចំណេញកើនឡើងទ្វេដង។ ទោះជាយ៉ាងនេះក្តី ធនាគារនូវតែប្តេជ្ញាថានឹងធ្វើការបន្តវឌ្ឍនភាពមួយនេះឱ្យកាន់តែរីកចម្រើនថែមទៀត ដើម្បីសម្រេចនូវជោគជ័យដ៏ធំវិសេសវិសាល។ លើសពីនេះទៅទៀត ក្នុងនាមជាធនាគារដែលប្តេជ្ញាចិត្តចំពោះគុណតម្លៃដ៏រឹងមាំរបស់ខ្លួន ធនាគារបានកំណត់យ៉ាងច្បាស់លាស់ថាភាពជោគជ័យមិនត្រូវបានកំណត់ដោយតួលេខនោះទេ។ ជាការពិតទន្ទឹមនឹងប្រាក់ចំណេញ ធនាគារខិតខំធ្វើយ៉ាងណាឱ្យនូវតែបន្តធ្វើប្រតិបត្តិការក្នុងនាមជាធនាគារដែលមានទំនួលខុសត្រូវខ្ពស់ និងប្រតិបត្តិតាមដើម្បីផ្តល់អត្ថប្រយោជន៍កាន់តែទូលំទូលាយជូនអតិថិជន សង្គមជាតិ និងសកលលោក។ នៅឆ្នាំ២០១៩នេះ ធនាគារមានមោទនភាពជាខ្លាំងក្នុងការសម្រេចបាននូវកំណើនថេរ ទោះបីមានបញ្ហាប្រឈមជាច្រើនដែលធនាគារបានជួបប្រទះ។

ធនាគារបានពង្រីកបណ្តាញប្រតិបត្តិការសាខារហូតដល់ ៥១សាខា នៅចុងឆ្នាំ២០១៩ ដែលត្រូវបានចាត់ទុកថាជាការប្តេជ្ញាចិត្តដ៏មុតមាំដើម្បីឆ្ពោះទៅរកការបម្រើសេវាអតិថិជនឱ្យស្ថិតនៅជិត និងក្បែរផ្ទះពួកគាត់បំផុត។ ធនាគារបាននូវតែបន្តការអនុវត្តន៍ក្នុងការគ្រប់គ្រងហានិភ័យប្រតិបត្តិការ និងមុខងារហានិភ័យឯករាជ្យផ្សេងៗទៀត។ ធនាគារបានគ្រប់គ្រងហានិភ័យប្រតិបត្តិការបានយ៉ាងល្អដោយគ្មានការខូចខាតប្រតិបត្តិការគួរឱ្យកត់សម្គាល់ណាមួយសម្រាប់ឆ្នាំ២០១៩ ឡើយ។

ក្នុងឆ្នាំ២០១៩ ធនាគារបានប្រកាន់យកការផ្លាស់ប្តូរគំរូ (**Paradigm Shift**) ដោយអនុវត្តការផ្លាស់ប្តូរជាមូលដ្ឋាននៅទូទាំងបណ្តាញប្រតិបត្តិការសាខារបស់ធនាគារ។ ការឆ្ពោះទៅរកវិសាលភាពនេះ ធនាគារផ្តោតការយកចិត្តទុកដាក់លើបច្ចេកវិទ្យាបង្កប់ដើម្បីបង្កើតមតិយោបល់វិជ្ជមាន និងជម្រុញវប្បធម៌នៃការបើកចំហការច្នៃប្រឌិត និងការសហការគ្នា។ ទាំងអស់នេះហើយជាផ្នែកមួយ ដែលបានពង្រឹងមូលដ្ឋានគ្រឹះដ៏រឹងមាំរបស់ធនាគារ។ ដោយផ្អែកលើយុទ្ធសាស្ត្ររបស់ធនាគារ ធនាគារបានបន្តការទទួលយកបច្ចេកវិទ្យាជួរមុខ ដើម្បីផ្តល់ជូនអតិថិជននូវបទពិសោធន៍ដ៏អស្ចារ្យលើការប្រើប្រាស់សេវាកម្មរបស់ធនាគារ។ នៅឆ្នាំ២០១៩ ធនាគារបានអនុវត្តប្រព័ន្ធអនុម័តឥណទានឆាប់រហ័សបំផុត ដែលអាចឱ្យមន្ត្រីឥណទានផ្តល់ជូនសេវាកម្មយ៉ាងឆាប់រហ័ស និងទាន់ពេលវេលាជូនអតិថិជន។ ឥឡូវនេះ អតិថិជន និងសាធារណជន អាចបើកគណនីជាមួយធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានគ្រប់ទីកន្លែងតាមរយៈការប្រើប្រាស់សេវាកម្មបើកគណនីតាមអនឡាញ។ ធនាគារបានដាក់ឱ្យដំណើរការនូវប័ណ្ណវីសារួចជាស្រេចហើយ និងរង់ចាំការបើកដំណើរការជាទ្រង់ទ្រាយធំនៅឆ្នាំ២០២០ ខាងមុខ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វូណន ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារក៏មានសន្ទុះនៃការរីកចម្រើនគួរឱ្យកត់សម្គាល់ និងបាននាំយកផលិតផលជាច្រើនផ្សេងៗគ្នា បម្រើជូនអតិថិជននាឆ្នាំ២០១៩នេះផងដែរ។

ធនាគារបានផ្តួចផ្តើមគំនិតដើម្បីអភិវឌ្ឍសមត្ថភាពបុគ្គលិក និងភាពរឹងមាំរបស់ធនាគារក្នុងឆ្នាំ២០១៩ ដែលខ្ញុំជឿជាក់ថាគឺជាតម្លៃស្នូលដ៏សំខាន់មួយរបស់ធនាគារ។ ធនាគារបានរៀបចំសិក្ខាសាលាតម្រង់ទិស និងពិព័រណ៍ការងារមួយចំនួនរួចមកហើយក្នុងគោលបំណងលើកកម្ពស់កិត្តិនាមរបស់ធនាគារ ដែលខ្ញុំជឿជាក់ថាយើងជាធនាគារជម្រើសដំបូងគេសម្រាប់សាធារណជននៅក្នុងប្រទេសកម្ពុជា។

នៅឆ្នាំ២០១៩ ប្រាក់ចំណូលសរុបរបស់ធនាគារបានកើនឡើងចំនួន ២២% ប្រាក់ចំណេញសុទ្ធមុនពេលបង់ពន្ធកើនឡើងចំនួន ២៥% រួមជាមួយថ្លៃដើមនៃប្រាក់ចំណូលដែលបានកើនឡើង ២៥% បើប្រៀបធៀបទៅនឹងលទ្ធផលកាលពីឆ្នាំមុន។ តួលេខទាំងនេះក៏ជាសក្ខីភាពនៃគោលដៅរបស់យើងក្នុងការក្លាយជាធនាគារពាណិជ្ជកំពូល និងឈានមុខគេក្នុងចំណោមធនាគារពាណិជ្ជធំៗទាំង៥ នៅក្នុងផ្នែក MSME នៅក្នុងប្រទេសកម្ពុជា។

លោក គួច ចៅចេក
ប្រធាននាយកប្រតិបត្តិ

ក្រុមប្រឹក្សាភិបាល

អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ

ប្រធានក្រុមប្រឹក្សាភិបាល

អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ ជាប្រធានក្រុមប្រឹក្សាភិបាល ធនាគារ កាណាឌីយ៉ា និងក្រុមហ៊ុនវិនិយោគទុនអាណិកជនកម្ពុជា (Overseas Cambodian Investment Corporat ion, OCIC)។ លោកបានចូលរួមយ៉ាងសកម្មក្នុងការវិនិយោគ និងការអភិវឌ្ឍន៍ក្រុមហ៊ុនទាំងពីរ។ លោកជាសហគ្រិនដ៏ឆ្នើម និងជាអ្នកដឹកនាំដ៏គួឱ្យគោរពក្នុងប្រទេសកម្ពុជា និងប្រទេស កា ណាដា។ អ្នកឧក ញ៉ាបណ្ឌិត ពុង ឃាវសែ បានបម្រើការងារជាប្រធានក្រុមប្រឹក្សាភិបាល ប្រធាននាយ កប្រតិបត្តិ និងអភិបាលរបស់ក្រុមហ៊ុនជាច្រើនមានដូចជា៖ Oriental Ship Supplies, Oriental Co mmercial Inc, ហើយលោកបានដឹកនាំធនាគារ កាណាឌីយ៉ា ឱ្យរីកចម្រើនចាប់តាំងពីឆ្នាំ១៩៩១។ បន្ថែមពី នេះទៅទៀត លោកធ្លាប់កាន់តួនាទីជាប្រធានសមាគមអ្នកសាងសង់កម្ពុជា និងធ្វើការជិតស្និទ្ធជាមួយប្រធានឧស្សាហកម្ម ដើម្បីណែនាំការអភិវឌ្ឍន៍វិស័យធនាគារ និងសំណង់នៅក្នុងប្រទេសកម្ពុជាផងដែរ។

អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ ទទួលបានពានរង្វាន់កិត្តិយសថ្នាក់ មហាសិរីវឌ្ឍនៈពីព្រះករុណាព្រះបាទនរោត្តមសីហនុ ក្នុងឆ្នាំ២០០២ និងទទួលបានមេដៃស្ថាបនាជាតិថ្នាក់លេខមួយ ដែលប្រគល់ដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក្រោមអធិបតីភាពរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ២០១២។ សម្រាប់ការចូលរួមដ៏សំខាន់ដែលលោកបានធ្វើ និងកំពុងបន្តធ្វើឱ្យមានការឆ្ពោះទៅរកការអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា។

នាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ លោកបានទទួលគោរមងារកិត្តិយសជា អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក្នុងពិធីសម្ពោធអគារឥន្ទ្រទេវីនៃរាជបណ្ឌិតសភាកម្ពុជា។

លោក YEO HONG PING

អនុប្រធានក្រុមប្រឹក្សាភិបាល

លោក Yeo មានតួនាទីត្រួតពិនិត្យលើការបង្កើតសិទ្ធិធុរកិច្ចរបស់ Fullerton Investment Holding Pte Ltd, និងការអភិវឌ្ឍន៍ចក្ខុវិស័យ និងយុទ្ធសាស្ត្ររបស់ Fullerton Investment Holding Pte Ltd, ដោយមានគោលដៅបង្កើនតម្លៃភាគទុនិកដោយឈរលើនិរន្តរភាព។ ក្នុងនាមជាអគ្គនាយក លោក Yeo មានទំនួលខុសត្រូវទាំងស្រុងលើ Fullerton Investment Holding Pte Ltd, និងក្រុមហ៊ុនវិនិយោគរបស់ខ្លួន។

មុនពេលចូលរួមជាមួយ Fullerton Investment Holding Pte Ltd, លោក Yeo គឺជានាយកគ្រប់គ្រងក្រុមហ៊ុន J.P. Morgan និងជាអ្នកទទួលខុសត្រូវខាងអាជីវកម្មទូទៅនៃធនាគារវិនិយោគ នៅក្នុងប្រទេសសិង្ហបុរី។ លោក Yeo ក៏ធ្លាប់បម្រើការជាសមាជិកគណៈកម្មាធិការគ្រប់គ្រងជាន់ខ្ពស់ក្រុមហ៊ុន J.P. Morgan សិង្ហបុរី និងជាសមាជិកក្រុមប្រឹក្សាភិបាលក្រុមហ៊ុន J.P. Morgan (SEA)។ លោកត្រូវបានធ្វើការតែងតាំងក្នុងតួនាទីជាន់ខ្ពស់ជាច្រើនផ្សេងទៀតរួមមាន នាយកប្រតិបត្តិធនាគារវិនិយោគអចលនទ្រព្យ និងជានាយកប្រតិបត្តិហិរញ្ញវត្ថុសាជីវកម្មនៅអាស៊ីអាគ្នេយ៍។

ឯកឧត្តម អោក បូរ៉ា

ទីប្រឹក្សារបស់ក្រុមប្រឹក្សាភិបាល

លោក អោក បូរ៉ា ត្រូវបានតែងតាំងជា អគ្គនាយកនៃនាយកដ្ឋាន ប្រៃសណីយ៍កម្ពុជា ក្នុងឆ្នាំ២០១០ និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រៃសណីយ៍កម្ពុជាក្នុងឆ្នាំ២០១១ ។

លោកបានបម្រើការងារជា ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងខេត្តបន្ទាយមានជ័យ ហើយលោកក៏ជាសមាជិកនៃវិទ្យាស្ថានវិស្វកម្មកម្ពុជា(Cambodia Engineering Institution) កាលពីឆ្នាំ២០០០ រហូតដល់ឆ្នាំ ២០១០។

លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិត គ្រប់គ្រងពាណិជ្ជកម្ម និងថ្នាក់អនុបណ្ឌិតវិស្វករទូរគមនាគមន៍ពីសាកលវិទ្យាល័យពហុបច្ចេកទេស (University of Hanoi Polytechnic) នៅក្នុងប្រទេសវៀតណាមក្នុងឆ្នាំ១៩៩៧។ ចាប់តាំងពីពេលនោះមក លោកបានចូលរួមក្នុងកម្មវិធី បណ្តុះបណ្តាលបច្ចេកទេសជាច្រើនទៀតទាក់ទងទៅនឹងប្រព័ន្ធទូរគមនាគមន៍ និងព័ត៌មានវិទ្យាទាំងក្នុងស្រុក និងក្រៅប្រទេស។

លោក NEO POH KIAT

សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

បច្ចុប្បន្ននេះ លោក **Neo** គឺជានាយកគ្រប់គ្រង ក្រុមហ៊ុន Advisory Services of Octagon Advisors ។ លោកបានចូលរួមយ៉ាងសកម្មជាមួយអតិថិជនលើជំនាញ M & A នៅក្នុងតំបន់។ លោកធ្លាប់ធ្វើជានាយកប្រតិបត្តិនៃក្រុមហ៊ុនផ្តល់ប្រឹក្សាយោបល់ឈ្មោះ Octagon Advisors Sanghai Limited, ដោយទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងពិគ្រោះយោបល់រាល់គម្រោងនានារបស់ក្រុមហ៊ុនដែលមានមូលដ្ឋាននៅទីក្រុងប៉េកាំង ប្រទេសចិន។

មុនចូលបម្រើការងារជាទីប្រឹក្សា Octagon លោក Neo ជាអនុប្រធាននាយកជាន់ខ្ពស់ និងជាមន្ត្រីទំនាក់ទំនង ប្រទេស ចិ ននៃធនាគារ Singapore's United Overseas Bank។ លោកជាអ្នកទទួលខុសត្រូវផ្នែកទំនាក់ទំនងក្រុមហ៊ុន និងសាជីវកម្មរបស់ធនាគារ UOB ដែលមានមូលដ្ឋាននៅទីក្រុងហុងកុង(Great China Region) ។

មុនពេលដែលលោកប ម្រើ ការងារក្នុង UOB លោក Neo កាន់តួនាទីជាច្រើនក្នុងធនាគារDBS ហើយតួនាទីចុងក្រោយរ បស់លោកគឺជានាយកគ្រប់គ្រង និងចាត់ការទូទៅរបស់ធនាគារDBSសាខាហុងកុង។ ទន្ទឹមនឹងនេះ លោកក៏ធ្លាប់ជានាយ កប្រតិបត្តិនិងជាសមាជិកនៃគណៈកម្មាធិការនាយកនៃធនាគារ DBS Kwo n g និងជានាយកគ្រ ប់គ្រងក្រុមហ៊ុនវិនិយោគ DBS Asia Capital Limited ដែលជាបុត្រសម្ព័ន្ធរបស់ធនាគារ DBS ក្នុងទីក្រុងហុងកុង។ លោកចូលរួមយ៉ាងសកម្មនៅក្នុងការបង្កើតក្រុមហ៊ុន DB S Securities Hong Kong និងក្រោយមកលោកបានក្លាយជានាយកគ្រប់គ្រងនាដើមទសវត្សរ៍៩០។ លោក Neo ទទួលបានបរិញ្ញាបត្រពាណិជ្ជកម្ម (Honours) ពីអតីត Nanyang University ប្រទេសសិង្ហបុរី។

ក្រុមប្រឹក្សាភិបាល

លោក GIANG SOVANN

សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

លោក Giang ជាស្ថាបនិក និងជាប្រធាននាយកប្រតិបត្តិរបស់ Corporate Governance Academy និងជាសមាជិកគណៈកម្មាធិការវិន័យ និងដោះស្រាយបណ្ដឹងរបស់ក្រុមហ៊ុន Public Accountants Oversight Committee, Accounting & Corporate Regulatory Authority (ACRA), and Singapore ហើយលោកក៏ជានាយកក្រុមហ៊ុន ដែលបានចុះបញ្ជីជាមួយ ទីផ្សារភាគហ៊ុនសិង្ហបុរី។

លោក Giang ជានាយកប្រតិបត្តិ Singapore Institute of Directors ជាកន្លែងដែលគាត់ដើរតួនាទីជាគណៈកម្មាធិការរៀបចំរង្វាន់សម្រាប់ក្រុមហ៊ុនសិង្ហបុរី និងជាសហប្រធានគ្រប់គ្រងចាត់ចែងពានរង្វាន់សម្រាប់ក្រុមហ៊ុនសិង្ហបុរីដែលបានចុះបញ្ជី។ លោកក៏ជាគ្រូបង្ហាត់លើមុខវិជ្ជាការទទួលខុសត្រូវ និងភារកិច្ចទទួលខុសត្រូវការចុះបញ្ជីផ្សារភាគហ៊ុនសិង្ហបុរី ស្ដីអំពីអភិបាលកិច្ចសាជីវកម្ម។ លោកបានសរសេរអត្ថបទជាច្រើនស្ដីអំពីក្រុមប្រឹក្សាភិបាល ការគ្រប់គ្រងផ្ទៃ ក្នុ ង និងសវនកម្ម ហើយគាត់បានបម្រើការងារជាអ្នកដឹកនាំឯករាជ្យ ប្រធាននៃគណៈកម្មាធិការសវនកម្ម ប្រធាននៃគណៈកម្មាធិការគ្រប់គ្រងហានិភ័យកម្រិតក្រុមប្រឹក្សាភិបាល សមាជិកគណៈកម្មាធិការជ្រើសតាំង និងគណៈកម្មាធិការវាយតម្លៃការចុះបញ្ជីរបស់ក្រុមហ៊ុន។

លោក Giang បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ រដ្ឋបាល ដោយទទួលបានលទ្ធផលល្អប្រសើរមកពី University of Regina ប្រទេសកាណាដា និងលោកជាអ្នកជំនាញគណនេយ្យរបស់ Canadian Institute of Chartered Accountants។ លោកក៏ជាគណនេយ្យករ និងជាសមាជិករបស់ Singapore Institute of Directors។

លោក Teo Meng Poh Philip

សមាជិកមិនប្រតិបត្តិ

លោក Teo គ្រប់គ្រងលើផ្នែកហានិភ័យផ្សេងៗនៃសិទ្ធិធុរកិច្ចរបស់ Fullerton Investment Holding Pte Ltd, នៅក្នុងប្រទេសចិន និងឥណ្ឌូចិន។ ក្នុងតួនាទីមួយនេះ លោក Teo ក៏ទទួលខុសត្រូវបន្ថែមលើការគ្រប់គ្រងហានិភ័យប្រតិបត្តិការសវនកម្ម និងអនុលោមភាពរបស់ Fullerton Investment Holding Pte Ltd, រួមទាំងការកំណត់គោលនយោបាយ និងក្របខ័ណ្ឌអភិបាលកិច្ច។ គាត់ក៏ជាអ្នកដឹកនាំហានិភ័យសម្រាប់សកម្មភាពតាមដាន និងវាយតម្លៃ។

មុនពេលចូលរួមជាមួយ Fullerton Investment Holding Pte Ltd, លោក Teo គឺជានាយកប្រតិបត្តិសវនកម្ម អតិថិជន និងហិរញ្ញវត្ថុសាជីវកម្មនៅ Standard Chartered Bank។ លោក Teo បានចាប់ផ្ដើមអាជីពរបស់គាត់ជាមួយសាជីវកម្មធនាគារនៅក្រៅប្រទេសចិន ដែលមានតួនាទីជាន់ខ្ពស់ទទួលខុសត្រូវចំពោះ អតិថិជននៅក្នុងសិទ្ធិអាជីវកម្មក្រៅប្រទេសរបស់ធនាគារនៅសៀងហៃ និងបាងកក។

លោក រស់ ភិរុណ

សមាជិកក្រុមប្រឹក្សាភិបាល

ចាប់តាំងពីឆ្នាំ២០០៨ មកដល់បច្ចុប្បន្ន លោក រស់ ភិរុណ កាន់តួនាទីជាអនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។ ភាគច្រើនលោកទទួលខុសត្រូវសម្រាប់ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការបង្កើត និងការអភិវឌ្ឍន៍មូលប័ត្ររបស់រដ្ឋាភិបាលកម្ពុជាទីផ្សារទំនិញប្រាក់សោធននិវត្តន៍គោលនយោបាយស្ថេរភាពហិរញ្ញវត្ថុ និងហិរញ្ញវត្ថុតាមតំបន់នៅប្រទេសកម្ពុជាក្រោមយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ។ លោកជាអនុប្រធានក្រុមប្រឹក្សាភិបាលរបស់បេឡាជាតិសន្តិសុខសង្គម(បសស) សម្រាប់មន្ត្រីរាជការស៊ីវិល (NSSFC) ដើម្បីត្រួតពិនិត្យ និងអនុម័ត សេចក្ដីព្រាងច្បាប់ដែលបានរៀបចំដោយ (បសស) ចាប់ពីឆ្នាំ២០០៩ រហូតដល់ខែមេសា ឆ្នាំ២០១៣។

ចាប់ពីឆ្នាំ២០០៤ រហូតដល់ឆ្នាំ២០០៨ លោកជាប្រធាននាយដ្ឋានគ្រប់គ្រងកាស៊ីណូដែលស្ថិតក្រោមនាយកដ្ឋានហិរញ្ញវត្ថុ និងជាអនុប្រធាននៃអង្គការពាណិជ្ជកម្មពិភពលោកទទួលបន្ទុកផ្នែកនីតិកម្ម និងប្រតិបត្តិតាម និងជំនួយការរបស់មន្ត្រីសេដ្ឋកិច្ចជាន់ខ្ពស់សម្រាប់ប្រទេសកម្ពុជាដែលស្ថិតនៅក្រោមនាយកដ្ឋានអន្តរជាតិ និងអាស៊ាននៃក្រសួងពាណិជ្ជកម្ម។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងវិទ្យាសាស្ត្រនៅក្នុងវិស័យទេសចរណ៍ពី CERAM ESC Sophia Antipolis ពីប្រទេសបារាំងឆ្នាំ២០០២ ហើយបានបញ្ចប់ថ្នាក់អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិ ពីវិទ្យាស្ថានអាស៊ីបច្ចេកវិទ្យាពីប្រទេសថៃ។

លោកស្រីវេជ្ជបណ្ឌិត CAROLYNE PUNG

សមាជិកក្រុមប្រឹក្សាភិបាល

លោកស្រី Carolyne បានចាប់កំណើតនៅទីក្រុងភ្នំពេញ។ លោកស្រីបានធំធាត់ និងបញ្ចប់ការសិក្សានៅទីក្រុង Montreal ប្រទេសកាណាដា។ បន្ទាប់ពីបានបញ្ចប់ការសិក្សាថ្នាក់វិទ្យាសាស្ត្រអនុវត្តនៅមហាវិទ្យាល័យលោកស្រីមានជំនាញវេជ្ជសាស្ត្រគ្រួសារ និងបានបញ្ចប់សិក្សាពីសាកលវិទ្យាល័យ Montreal នៅក្នុងឆ្នាំ២០០២។ អស់រយៈពេលជិត៥ឆ្នាំមកហើយដែលលោកស្រីបានមមាញឹកនិងអាជីពការងារជាគ្រូពេទ្យនៅក្នុងមន្ទីរពេទ្យ និងគ្លីនិកឯកជនពីរនៅក្នុងប្រទេសកាណាដាគឺខេត្ត Quebec និងខេត្តOntario។

នៅក្នុងឆ្នាំ២០០៧ ដោយសារតែហេតុផលគ្រួសារ លោកស្រីបានសម្រេចចិត្តលះបង់ពេលវេលាដើម្បីអាជីវកម្មក្រុមគ្រួសាររបស់លោកស្រីនៅក្នុង ប្រទេសកម្ពុជា។ ដោយការស្រលាញ់ និងចូលចិត្តខាងផ្នែកវេជ្ជសាស្ត្រ លោកស្រីបានធ្វើការក្រៅម៉ោងជាមួយ SOS interna-tional Clinic។ លោកស្រីធ្លាប់ជាជំនួយការផ្ទាល់ របស់ប្រធានក្រុមប្រឹក្សាភិបាលធនាគារ កាណាឌីយ៉ា ភីអិលស៊ី ដែលជាធនាគារនាំមុខគេនៅក្នុងប្រទេសកម្ពុជា។ លោកស្រីក៏ជានាយកនៃនាយកដ្ឋានបដិសណ្ឋារកិច្ចនៃកាណាឌីយ៉ាគ្រុបដែលបច្ចុប្បន្នកំពុងប្រតិបត្តិការក្នុងសណ្ឋាគារ Dara Airport នៅក្នុងរាជធានីភ្នំពេញសណ្ឋាគារឯករាជ្យក្នុងខេត្តព្រះសីហនុ និងសេវាកម្មអាផាតមិនចំនួនពីរក្នុងរាជធានីភ្នំពេញ។ លោកស្រីក៏ជាប្រធានក្រុមប្រឹក្សាភិបាល នៃសាលាអន្តរជាតិកាណាដារាជធានីភ្នំពេញដែលជាសាលាអប់រំដ៏ល្បីនៅក្នុងប្រទេស។ ទោះបីជាការសិក្សាវេជ្ជសាស្ត្រទាមទារពេលវេលាច្រើនក៏ដោយ ក៏លោកស្រីតែងតែព្យាយាមអភិវឌ្ឍខ្លួនដោយសិក្សាជំនាញគណនេយ្យ និងទីផ្សារបន្ថែមទៀត។ លោកស្រីត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ចាប់តាំងពីឆ្នាំ២០១៤មក។

គណៈគ្រប់គ្រង

លោក តូច ចៅចេក
ប្រធាននាយកប្រតិបត្តិ

លោក យី សាគុណ
ប្រធាននាយកប្រតិបត្តិធនធានមនុស្ស

លោក ម៉ាលៃ កុម៉ែ ប៉ូល
ប្រធាននាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ

លោក តូច ចៅចេក មានបទពិសោធន៍ជាង ២០ឆ្នាំក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។ លោកធ្លាប់បម្រើការងារជាបុគ្គលិកជាន់ខ្ពស់ និងជានាយកប្រតិបត្តិក្នុងអគ្គនាយកដ្ឋានឥណទាននៃ ធនាគារអេស៊ីលីដា មុនពេលដែលលោកបានចូលបម្រើការងារជាអនុប្រធាននាយកប្រតិបត្តិ និងប្រធាននាយកប្រតិបត្តិប្រតិបត្តិការ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត ទទួលខុសត្រូវទាំងស្រុងទៅលើប្រតិបត្តិការអាជីវកម្មរបស់គ្រឹះស្ថានមានដូចជា៖ ការគ្រប់គ្រងសំពាធឥណទាន ការកេណ្ឌប្រមូលប្រាក់បញ្ញើសន្សំ ការអភិវឌ្ឍន៍អាជីវកម្ម និងការគ្រប់គ្រងសាខា ក្រៅពីវិស័យធនាគារ និងហិរញ្ញវត្ថុនេះ លោកធ្លាប់បម្រើការងារក្នុងវិស័យផលិតកម្មអស់រយៈពេល ២ឆ្នាំ ដែលមានតួនាទីជានាយកប្រតិបត្តិទីផ្សារ។

លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែកធនាគារ និងហិរញ្ញវត្ថុពីសាកលវិទ្យាល័យកម្ពុជា ក្នុងឆ្នាំ២០០៦ និងបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកទីផ្សារពីសាកលវិទ្យាល័យជាតិគ្រប់គ្រង និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាធារណៈក្នុងឆ្នាំ ១៩៩៩ ហើយលោកក៏បានបញ្ចប់ថ្នាក់បរិញ្ញាបត្ររងផ្នែកវិជ្ជាជីវៈច្បាប់ក្នុងឆ្នាំ១៩៩៦ ពីសាកលវិទ្យាល័យច្បាប់ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចផងដែរ។

លោកក៏បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលប្រតិបត្តិជាច្រើនទាំងក្នុង និងក្រៅប្រទេសលើវិស័យធនាគារ និងហិរញ្ញវត្ថុ ដែលទាក់ទងទៅនឹងភាពជាអ្នកដឹកនាំ ការគ្រប់គ្រង និងការគ្រប់គ្រងហានិភ័យជាដើម។

លោក យី សាគុណ មានបទពិសោធន៍ជាង ១៦ឆ្នាំលើផ្នែកគ្រប់គ្រងធនធានមនុស្ស ការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍ការគ្រប់គ្រងសមិទ្ធផល និងការសម្របសម្រួលកិច្ចការធនធានមនុស្សក្នុងវិស័យហិរញ្ញវត្ថុរួមមាន ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងបដិសណ្ឋារកិច្ច។ លោក សាគុណ មានបទពិសោធន៍ជាច្រើនលើផ្នែកគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស ការបង្កើតវប្បធម៌សាជីវកម្ម ការគ្រប់គ្រងការផ្លាស់ប្តូរធនធានមនុស្ស ការគ្រប់គ្រងការអនុវត្តន៍ និងការគ្រប់គ្រងលើជំនាញនិងទេពកោសល្យ សម្រាប់ក្រុមហ៊ុនដែលទើបបង្កើតថ្មី និងក្រុមហ៊ុនកែទម្រង់ ឬរៀបចំរចនាសម្ព័ន្ធឡើងវិញ។

លោកបានចូលរួមជាមួយធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ចាប់តាំងពីការកកើតឡើងដំបូងនាខែកុម្ភៈ ឆ្នាំ២០១៣។ មុនពេលចូលរួមជាមួយធនាគារប្រៃសណីយ៍កម្ពុជា ក.អ លោកបានកាន់តំណែងជានាយករងប្រតិបត្តិធនធានមនុស្សនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ជានាយកគ្រប់គ្រងធនធានមនុស្ស នាយកសម្របសម្រួលកិច្ចការធនធានមនុស្ស ជាអ្នកសម្របសម្រួលគម្រោងក្នុងប្រទេសរបស់ធនាគារ ANZ រ៉ូយ៉ាល់ និងជានាយកប្រតិបត្តិធនធានមនុស្សនៅសណ្ឋាគារ និងរមណីយដ្ឋាន សុខាគ្រុប (សណ្ឋាគារ និងរមណីយដ្ឋានលំដាប់ផ្កាយ ៥)។

លោកក៏ធ្លាប់បានបម្រើការក្នុងផ្នែកលក់ និងសេវាកម្មអតិថិជនលើផ្នែកបដិសណ្ឋារកិច្ចរាប់បញ្ចូលទាំងសណ្ឋាគារក្នុងប្រទេស និងក្រៅប្រទេសលំដាប់ផ្កាយ ៥ ដូចជាសូហ្វីតែលរ៉ាហ្វល ក្រុមហ៊ុនទេសចរណ៍ និងទូរគមនាគមន៍។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងអាជីវកម្ម និងបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលជាច្រើនទាំងក្នុងប្រទេស និងក្រៅប្រទេសដែលភាគច្រើនទាក់ទងនឹងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងធនធានមនុស្ស។

លោក ម៉ាលៃ មានបទពិសោធន៍ការងារជាង ២៥ឆ្នាំ លោកមានមុខតំណែងចុងក្រោយជា អនុប្រធាននាយកប្រតិបត្តិ គ្រប់គ្រងហានិភ័យរបស់ Fullerton Financial Holdings (FFH) ជាទីកន្លែងដែលលោក បានជួយគាំទ្រដល់ផ្នែកគ្រប់គ្រងហានិភ័យផលបត្រឥណទានរបស់ FFH នៅក្នុងតំបន់ឥណ្ឌូចិន។

មុនពេលដែលលោកចូលបម្រើការងារក្នុង FFH លោកមានតួនាទីជាប្រធាននាយកគ្រប់គ្រងហានិភ័យនៅធនាគារ Mekong Development Bank (MDB) ក្នុងប្រទេសវៀតណាម។ លោក ម៉ាលៃ មានបទពិសោធន៍ជាច្រើននៅក្នុងផ្នែកគ្រប់គ្រងឥណទាន និងការដោះស្រាយបំណុល។ លោកធ្លាប់បម្រើការងារក្នុងតួនាទីជា អនុប្រធាននាយកប្រតិបត្តិ នាយកប្រតិបត្តិឥណទាន និងការដោះស្រាយបំណុលនៅក្នុងផ្នែកលក់ និងអាជីវកម្មតូចៗ នៅធនាគារ The City Bank Ltd. ក្នុងប្រទេសបង់ក្លាដេស ហើយមុនពេលបម្រើការងារក្នុងធនាគារនេះ លោកបានបម្រើការងារក្នុងតួនាទីដូចគ្នានេះដែរនៅក្នុង ធនាគារ PRAC Bank ក្នុងប្រទេសបង់ក្លាដេស។ នៅមុនពេលដែលលោកបម្រើការងារនៅធនាគារខាងលើ លោក ម៉ាលៃ បានបម្រើការងារអស់រយៈពេល ១៣ឆ្នាំ នៅធនាគារ Stadard Chartered Bank ហើយលោកមានតួនាទីចុងក្រោយជា នាយកប្រតិបត្តិដោះស្រាយបំណុលប្រចាំតំបន់រួមមានប្រទេស Barain, Qatar, Jordan និងLebanon។

លោក ម៉ាលៃ ចាប់ផ្តើមការងារក្នុងធនាគារដំបូងរបស់លោកនៅធនាគារ ANZ Grindlays Bank’s មានតួនាទីជាអ្នកគ្រប់គ្រងសាខាធនាគារ និងគ្រប់គ្រងបំណុលមានបញ្ហា ។

លោក ម៉ាលៃ ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកវិទ្យាសាស្ត្រ (ថ្នាក់ដំបូង) ជាមួយសាកលវិទ្យាល័យ ដាកា ក្នុងប្រទេសបង់ក្លាដេស។ គាត់គឺជាគ្រូបង្រៀន (CollectionTrainer) ដែលមានការទទួលស្គាល់ និងបានបញ្ចប់វគ្គបណ្តុះបណ្តាលជាគ្រូបង្គោលដែលបានរៀបចំដោយវិទ្យាស្ថានធនាគារ អភិវឌ្ឍន៍អាស៊ី (ADBI) មជ្ឈមណ្ឌលសិក្សាអភិវឌ្ឍន៍ក្រុងតូក្យូ (TDLC) ដែលជាសមាជិកនៃ GDLN អាស៊ីប៉ាស៊ីហ្វិក និងអង្គការអភិវឌ្ឍន៍មូលធនសហប្រជាជាតិមូលនិធិ (UNCDF) ។

គណៈគ្រប់គ្រង

លោកស្រី សេនឌី ឈួ ផេកជូ
ប្រធាននាយិកាប្រតិបត្តិពាណិជ្ជកម្ម និងអភិបាលសាខា

លោកស្រី សេនឌី ឈួ ផេក ជូ បានចូលរួមជាមួយធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ក្នុងឆ្នាំ២០១៩។ លោកស្រីមានបទពិសោធន៍ក្នុងវិស័យធនាគារចាប់តាំងពីឆ្នាំ២០០៤ មកម្ល៉េះ។ មុ នពេលចូលរួមជាមួយធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ លោកស្រីមានបទពិសោធន៍ជាលេខាធិការនាយកប្រតិបត្តិនៅធនាគារកម្ពុជា អាស៊ី និងកាន់មុខតំណែង ប្រតិបត្តិការ និងការគ្រប់គ្រងជាច្រើនផ្នែកនៅក្នុងធនាគារ ANZ រ៉ូយ៉ាល់ រួមមានផ្នែកធនធានមនុស្ស សេវាកម្មអតិថិជន ប្រតិបត្តិការសាខា ការគ្រប់គ្រងសាខា និងការគ្រប់គ្រងឥណទានថ្នាក់តំបន់។ លោកស្រីក៏ត្រូវបានចាត់តាំងដ ល់ក្រុមហ៊ុនទូទាត់តាមទូរសព្ទដៃ ក្រុមហ៊ុនវីងខេមបូឌា(ជាបុត្រសម្ព័ន្ធរបស់ធនាគារ ANZ ក្នុងឆ្នាំ ២០០៨) ក្នុងនាមជានាយិកាគ្រប់គ្រងតំហែរក្សាអតិថិជន និងគ្រប់គ្រងរដ្ឋបាលទទួលបន្ទុកគ្រប់គ្រងផ្នែកទំនាក់ទនងតាមទូរសព្ទ ផ្នែកលក់រាយផ្នែករដ្ឋបាល និងនាយកដ្ឋានប្រតិបត្តិការ។ លោកស្រីក៏ធ្លាប់មានបទពិសោធន៍ក្នុងមុខតំណែងជាន់ខ្ពស់ជាច្រើននៅក្នុងធនាគារ មេយប៉ែង (ខេមបូឌា) ភីអិលស៊ី លើផ្នែកធនាគារអតិថិជន និងឥណទានខ្នាតតូច និងមធ្យម។

លោកស្រី សេនឌី ឈួ ផេក ជូ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងទូទៅ ពីសាកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី។ លោកស្រីក៏ត្រូវបានទទួលស្គាល់ដោយ LE AN S ix Sigma និង Omega លើជំនាញផ្នែកឥណទានផងដែរ។

លោកស្រី សេនឌី ឈួ ផេកជូ គឺជាក្រុមការងារផ្នែកសេវាធនាគារ និងហិរញ្ញវត្ថុ ក្នុងក្រុមការងារទាំង១៣ផ្នែក ឯកជននៃវេទិកា រាជរដ្ឋាភិបាល-ផ្នែកឯកជន ទទួលស្គាល់ជាផ្លូវការដោយនាយករដ្ឋមន្ត្រីតាំងពីថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១៩។

សមាជិកគណៈ កម្មាធិកាបច្ចេកទេសទី២ តំណាងសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជានិងជាសមាជិកផ្នែកសារធាតុ និងផលិតផលគីមីក្រោម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ លោកស្រីក៏ជាសមាជិក EXCO នៃ CSU_ACA សមាជិកសភាពាណិជ្ជកម្ម សមាជិកនៃសមាគមសហគ្រិនស្ត្រីកម្ពុជា និងជាសមាជិកសហព័ន្ធខ្មែរ ចិននៅកម្ពុជា។

លោក គង់ ឆាយឡុង
ប្រធាននាយកប្រតិបត្តិប្រតិបត្តិការ

លោក គង់ ឆាយឡុង មានបទពិសោធន៍ការងារក្នុងវិស័យ បច្ចេកវិទ្យា និងធនាគារជាង ២៣ឆ្នាំនិងក្នុងឆ្នាំ ២០១៦ បានចូលរួមជាមួយធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ។ លោកបានចំណាយពេល និងចូលរួមជាការងារ ជាមួយក្រុមហ៊ុនបច្ចេកវិទ្យាអន្តរជាតិធំៗ ចំនួន២អស់រយៈពេលជាង ១២ឆ្នាំ។ ក្រោយមកលោកបានចូលរួម និងបម្រើការងារ ដែលមានមុខតំណែងជាន់ខ្ពស់មួយជាមួយធនាគារ ANZ Royal អស់រយៈពេលជាង ១០ឆ្នាំ។ ផ្អែកលើបទពិសោធន៍ផ្នែកប្រព័ន្ធបច្ចេកវិទ្យាការជាច្រើនឆ្នាំ លោកបានធ្វើពិធីកម្មចំណេះដឹងដើម្បីចូលរួមក្នុងវិស័យធនាគារ ធ្វើយ៉ាងណា ឲ្យសេវាកម្មធនាគារកាន់តែមានលក្ខណៈ ងាយស្រួល ឌីជីថល សាមញ្ញ និងស្វ័យប្រវត្តិកម្មដើម្បីបំពេញតាមតម្រូវការទីផ្សារ និងអភិបាលកិច្ចឱ្យល្អគួរជាទីគាប់ប្រសើរ។

លោកបានកាន់មុខតំណែង និងមានការទទួលខុសត្រូវខ្ពស់ជាច្រើននៅធនាគារ ANZ Royal ក្នុងនោះលោកបានដឹកនាំផ្នែក Electronic Channel ដើម្បីជួលសម្រួលដល់ប្រតិបត្តិការសេវាកម្ម ផ្នែកលក់ ផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិ និងផ្នែកសាជីវកម្ម ដើម្បីសម្រេចបាននូវភាពជោគជ័យ និងក្រោយមកក៏ក្លាយជាធនាគារធំមួយនៅលើទីផ្សារស្រុកខ្មែរ។

ដោយការប្តេជ្ញាចិត្ត និងការលះបង់ខ្ពស់របស់លោកទើបធ្វើឱ្យលោកសម្រេចបាននូវលទ្ធផលគួរឱ្យកត់សម្គាល់ ហើយត្រូវក៏បានតែងតាំងជានាយកប្រតិបត្តិប្រតិបត្តិការកណ្តាល មានតួនាទីគ្រប់គ្រង និងដឹកនាំនាយកដ្ឋានចំនួន ៥ ដែលស្ថិតក្រោមការគ្រប់គ្រង។ ក្រៅពីការងារគោលលោកបានទទួលជោគជ័យក្នុងការដឹកនាំនិងអនុវត្តន៍គម្រោងផ្សេងៗជាច្រើនរួមទាំង System Transformation and Processes re-Engineering ។

លោក ឆាយឡុង បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកព័ត៌មានវិទ្យា និងទទួលបានវិញ្ញាបនប័ត្រភាពជាអ្នកដឹកនាំផ្សេងៗ លោកក៏ជាសមាជិកនៃ International Compliance Association និងវិញ្ញាបនប័ត្រផងដែរ។

លោក ជា ប៊ុនហ៊ាន
ប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ

លោក ជា ប៊ុនហ៊ាន បានចូលរួមជាមួយធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ក្នុងតួនាទីជាប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ នាខែវិច្ឆិកា ឆ្នាំ២០១៩។ លោកមានបទពិសោធន៍ជាង ១០ឆ្នាំក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ លោកបានចំណាយពេលជាង ២ឆ្នាំជាមួយក្រុមហ៊ុនកាណាឌីយ៉ាគ្រុប និងទទួលបន្ទុកតួនាទីផ្សេងៗគ្នាដូចជា នាយកប្រតិបត្តិផែនការអាជីវកម្ម និងគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុ នាយកប្រតិបត្តិរតនាគារ នៅធនាគារកាណាឌីយ៉ា និងជាប្រធាននាយកប្រតិបត្តិ នៅក្រុមហ៊ុនកាណាស៊ីយូរីធីអិលធីឌី។

មុនពេលលោកបានចូលរួមជាមួយធនាគារ លោកបានកាន់មុខតំណែងជាច្រើនជាមួយធនាគារក្នុងតំបន់ រួមមានតំណែងជានាយករងប្រតិបត្តិធនាគារពាណិជ្ជអស់រយៈពេល ៤ឆ្នាំ។ លើសពីនេះទៀត លោកបានកាន់តំណែងជាង ៧ឆ្នាំក្នុងផ្នែកសវនកម្ម ដែលចុងក្រោយលោកបានកាន់តំណែងជានាយកគ្រប់គ្រងសវនកម្មនៅក្រុមហ៊ុនសវនកម្មក្នុងស្រុក និងក្រុមហ៊ុនសវនកម្មធំៗចំនួន ៤ នៅប្រទេសសិង្ហបុរី ប្រទេសវៀតណាម និងប្រទេសកម្ពុជា។

លោក ប៊ុនហ៊ាន ទទួលបានវិញ្ញាបនបត្រគណនេយ្យសាធារណៈវិញ្ញាបនបត្រ CPA អូស្ត្រាលី និង KICPAA។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងធុរកិច្ចពីសាកលវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម ទីក្រុងប៉ារីស ប្រទេសបារាំង។ លោកក៏បានបញ្ចប់បរិញ្ញាបត្រសេដ្ឋកិច្ចពីសាកលវិទ្យាល័យលីយ៉ុង ប្រទេសបារាំង និងបរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រទេសកម្ពុជា។

លោកក៏ជាសវនករដែលទទួលបានការទទួលស្គាល់ពីគណៈកម្មការមូលបត្រកម្ពុជាផងដែរ។ លោកមានបទពិសោធន៍ការងារផ្ទាល់ជាមួយនិយ័តករ ដូចជា ធនាគារជាតិនៃកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ KICPAA ក្រុមប្រឹក្សាជាតិគណនេយ្យ និងសភាពាណិជ្ជកម្មនៃសមាគមធនាគារនៃកម្ពុជា និងសភាពាណិជ្ជកម្មម៉ាឡេស៊ី។

លោក គ្រួច ចាន់ថុល
ប្រធាននាយកប្រតិបត្តិបច្ចេកវិទ្យាព័ត៌មានស្តីទី

លោក គ្រួច ចាន់ថុល ជានាយកប្រតិបត្តិបច្ចេកវិទ្យាព័ត៌មានស្តីទីនៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ។ លោកកំពុងដឹកនាំក្រុមការងារនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យា និងឌីជីថល នៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ក្នុងគោលបំណងជម្រុញយុទ្ធសាស្ត្រ បច្ចេកវិទ្យា និង ឌីជីថល ជំនាន់ក្រោយនៅកម្ពុជា។ លោក ចាន់ថុល និងក្រុមការងារបានប្តេជ្ញាចិត្តធ្វើការផ្លាស់ប្តូរនិន្នាការបច្ចេកវិទ្យាបច្ចុប្បន្នឱ្យកាន់តែរីកចម្រើនថែមមួយកម្រិតទៀត និងទាក់ទាញផលិតផលឌីជីថលថ្មីៗប្រកបដោយភាពច្នៃប្រឌិតដែលមានភាពរហ័ស និងបង្កើនប្រសិទ្ធភាពខ្ពស់សម្រាប់កំណើនអាជីវកម្ម។

ជាមួយបទពិសោធជំនាញជាង ២០ឆ្នាំ លោកបានចូលរួមជាសមាជិកស្ថាបនិកអ្នករៀបចំក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ធនាគារ ខេមកូ និង RHB និងបានបើកដំណើរការអាជីវកម្មនេះដោយជោគជ័យក្នុងរយៈពេល ៦ខែ។ នៅក្នុងតួនាទីរបស់លោក គ្រប់គ្រងផែនទីបង្ហាញផ្លូវបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល ហើយក៏ជាប្រធានគណៈកម្មាធិការដឹកនាំផ្នែកព័ត៌មានវិទ្យាដំឡើងហេដ្ឋារចនាសម្ព័ន្ធសេវាកម្ម និងផលិតផលផ្គត់ផ្គង់ប្រតិបត្តិការមជ្ឈមណ្ឌលកាត គ្រប់គ្រងអ្នកផ្គត់ផ្គង់សេវាគំរាមកំហែងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណែតសវនកម្មហានិភ័យអភិបាលកិច្ច និងធានាគុណភាព គាំទ្រផ្នែកបច្ចេកទេស អភិវឌ្ឍកម្មវិធីបន្តនិរន្តរភាពអាជីវកម្ម និង ផែនការស្តារគ្រោះមហន្តរាយ។ លោកកំពុងគ្រប់គ្រងបុគ្គលិកចំនួន ៣៣នាក់ នៅក្រោមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល។

មុនពេលចូលកាន់តួនាទីនេះ លោកបានកាន់មុខតំណែងជាន់ខ្ពស់នៅក្នុងឧស្សាហកម្មធនាគារ និងធានារ៉ាប់រងផ្សេងៗ។ ក្នុងចំណោមការងារពីមុន លោកគឺជាប្រធានផ្នែកព័ត៌មានវិទ្យា និងការគាំទ្រផ្នែកសេវាកម្មនៅធនាគារ UCB RHB និងខេមកូ និងធានារ៉ាប់រងអាយុជីវិតព្រូដិនសល។ លោក ចាន់ថុល បានបញ្ចប់ការសិក្សាផ្នែកវិទ្យាសាស្ត្រព័ត៌មានកុំព្យូទ័រពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងទទួលបានសញ្ញាប័ត្រចំនួនពីរ ពីផ្នែករដ្ឋបាលធុរកិច្ច ៕

មហាសន្និបាទប្រចាំឆ្នាំលើកទី៦

នាថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ នៅសណ្ឋាគារសោម៉ាទេវីអង្គរ ខេត្តសៀមរាប ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានរៀបចំមហាសន្និបាទប្រចាំឆ្នាំលើកទី៦ ដើម្បីអបអរសាទរសមិទ្ធផលការងារដែលសម្រេចបានក្នុងឆ្នាំ២០១៩ និងរៀបចំផែនការយុទ្ធសាស្ត្រថ្មីសម្រាប់ឆ្នាំ២០២០ ។

មហាសន្និបាទប្រចាំឆ្នាំលើកទី៦នេះត្រូវបានប្រារព្ធឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោក តូច ចៅចេក ប្រធាននាយកប្រតិបត្តិនៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ នាយកនាយិកសាខា និងបុគ្គលិកឆ្នើមជាច្រើនរូប។

មហាសន្និបាទប្រចាំឆ្នាំលើកទី៦នេះ ក៏មានការរួមបញ្ចូលកម្មវិធីអភិវឌ្ឍន៍ផ្នត់គំនិតផ្នែកដឹកនាំល្អ និងផ្តល់ឱកាសដល់គណៈគ្រប់គ្រងទាំងអស់ក្នុងការពង្រឹងការទំនាក់ទំនង និងកិច្ចសហការគ្នាដើម្បីបង្កើនប្រសិទ្ធភាពការងារ។

ពិសេសជាងនេះទៅទៀតនោះ មហាសន្និបាទប្រចាំឆ្នាំលើកទី៦ ក៏បានធ្វើការប្រគល់ជូនពានរង្វាន់ និងលិខិតសរសើរជូនបុគ្គលិកឆ្នើម និងសាខាឆ្នើមប្រចាំឆ្នាំ២០១៩ ជាច្រើនទៀត។

សិក្ខាសាលាស្តីពី ស្ត្រី និងវិស័យហិរញ្ញវត្ថុ

នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានធ្វើកិច្ចសហការជាមួយស្ថាប័ន World Savings and Retail Banking Institute (WSBI) រៀបចំសិក្ខាសាលាស្តីពី ស្ត្រី និងហិរញ្ញវត្ថុ "Women & Finance" នៅសណ្ឋាគាររ៉ូយ៉ាល់ព្យាស៊ីធី រាជធានីភ្នំពេញ។ វេទិកានេះត្រូវបានរៀបចំឡើងក្នុងគោលបំណង ផ្តោតលើការពិភាក្សាអំពីបរិយាប័ន្នហិរញ្ញវត្ថុ ក្នុងការលើកកម្ពស់តម្លៃស្ត្រីក្នុងវិស័យហិរញ្ញវត្ថុ និងបញ្ហាវិសមភាពយេនឌ័រ តាមរយៈយុទ្ធសាស្ត្រគោលនយោបាយ បច្ចេកវិទ្យា និងការអប់រំផ្នែកហិរញ្ញវត្ថុ ដែលអាចជួយឱ្យសម្រេចបានសមត្ថិភាពយេនឌ័រ និងលុបបំបាត់អត្រាស្ត្រីដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ និងការពង្រីកមុខរបរឱ្យស្ត្រី។

សិក្ខាសាលានេះ ទទួលបានការអញ្ជើញចូលរួមពីតំណាងស្ថាប័នធនាគារ និងហិរញ្ញវត្ថុទូទាំងពិភពលោកដូចជាឥណ្ឌូនេស៊ី ឥណ្ឌា ស្រីលង្កា ថៃ និងបង់ក្លាដែស រួមទាំងតំណាងពីក្រសួងហិរញ្ញវត្ថុ លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង នៃធនាគារជាតិ នៃកម្ពុជា អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ ប្រធានក្រុមប្រឹក្សាភិបាលធនាគារប្រៃសណីយ៍កម្ពុជា ក.អ និងមានការអញ្ជើញចូលរួមពីវាគ្មិនលោក តូច ចៅចេក ប្រធាននាយកប្រតិបត្តិនៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ លោក Chris De'Noose នាយកគ្រប់គ្រង WSBI ដោយពិភាក្សាលើការចូលរួមរបស់ស្ត្រីក្នុងសេដ្ឋកិច្ចដែលជួយពន្លឿនការសម្រេចបាននូវ ការអភិវឌ្ឍន៍សេដ្ឋកិច្ច ប្រកបដោយចីរភាព និងសមាហរណកម្មនៃការដាក់បញ្ចូលហិរញ្ញវត្ថុឱ្យកាន់តែប្រសើរឡើង។

ព្រឹត្តិការណ៍សំខាន់ៗ

ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូលើការផ្តល់សេវាទូទាត់ និងសងប្រាក់កម្ចីពីអតិថិជនរបស់ធនាគារតាមរយៈ តារាផេ និងហ្វូណាន មីក្រូហិរញ្ញវត្ថុ

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានធ្វើការប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូលើការផ្តល់សេវាទូទាត់ និងសងប្រាក់កម្ចីពីអតិថិជនរបស់ធនាគារតាមរយៈ តារាផេ និងហ្វូណាន មីក្រូហិរញ្ញវត្ថុ។ កិច្ចព្រមព្រៀងភាពជាដៃគូនេះ បានបង្ហាញពីជំនឿចិត្តដ៏មុតមាំរបស់ធនាគារប្រៃសណីយ៍កម្ពុជា ជាមួយគ្រឹះស្ថាន ហ្វូណាន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី និងតារាផេក្នុងការធ្វើជាបណ្តាញប្រតិបត្តិការហិរញ្ញវត្ថុបន្ថែម សម្រាប់អតិថិជនទូទាត់សងប្រាក់កម្ចីទៅកាន់ធនាគារ។ ពិធីចុះកិច្ចព្រមព្រៀងនេះបានធ្វើឡើងនៅសណ្ឋាគារ Dara Airport និងមានការចូលរួមពីសំណាក់ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិច្រើនជាង ១០០នាក់ មកពីស្ថាប័នទាំងបី ដោយមានទាំងថ្នាក់ដឹកនាំនៃស្ថាប័នទាំងបី និងបណ្តាអ្នកសារព័ត៌មានផងដែរ។

តាមរយៈភាពជាដៃគូនេះអតិថិជនទាំងអស់នឹងអាចទូទាត់សងប្រាក់កម្ចីទៅកាន់ធនាគារជាប្រាក់រៀល ឬប្រាក់ដុល្លារដោយងាយស្រួល និងសុវត្ថិភាពតាមរយៈភ្នាក់ងារតារាផេជាង ២៧០០ កន្លែងនៅទូទាំងប្រទេសកម្ពុជា។ ដោយមិនចាំបាច់ចំណាយពេលធ្វើដំណើរទៅកាន់សាខារបស់ធនាគារ និងមីក្រូហិរញ្ញវត្ថុឡើយ។ អតិថិជនទាំងអស់អាចទូទាត់សងប្រាក់កម្ចីបាននៅភ្នាក់ងារណាមួយរបស់តារាផេដែលមានទីតាំងនៅជិតផ្ទះ ឬកន្លែងធ្វើការរបស់ពួកគាត់បាន។

ពិព័រណ៍ការងារ និងផលិតភាពជាតិឆ្នាំ២០១៩

នាថ្ងៃទី០២-០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅសាលពិព័រណ៍កោះពេជ្រ ធនាគារប្រៃសណីយ៍កម្ពុជាក.អបានចូលរួមជាមួយទីភ្នាក់ងារជាតិមុខរបរ និងការងារនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈក្រោមកិច្ចសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា រាជធានីភ្នំពេញ និងសមាគមន៍រោងចក្រកាត់ដេរ នៅកម្ពុជា (GMAC) ក្នុងការប្រារព្ធមហាព្រឹត្តិការណ៍ពិព័រណ៍ការងារដ៏ធំប្រចាំឆ្នាំគឺ «ពិព័រណ៍ការងារ និងផលិតភាពជាតិឆ្នាំ២០១៩» ក្នុងគោលបំណងបើកទទួលស្វាគមន៍ សម្រាប់និយោជក អ្នកស្វែងរកការងារធ្វើ និងនិយោជិក សិស្សនិស្សិត ក្នុងការទទួលបានឱកាសការងារជាច្រើនកន្លែង។

ព្រឹត្តិការណ៍លើកកម្ពស់ប្រពៃណីខ្មែរ តាមរយៈការបង្ហាញសម្លៀកបំពាក់ប្រពៃណីខ្មែរ

ព្រឹត្តិការណ៍លើកកម្ពស់ប្រពៃណីខ្មែរ តាមរយៈការប្រឡងបង្ហាញសម្លៀកបំពាក់ប្រពៃណីខ្មែរ ដែលទទួលបានការគាំទ្រយ៉ាងខ្លាំងក្នុងឆ្នាំ២០១៨ឥឡូវនេះធនាគារប្រៃសណីយ៍កម្ពុជាក.អក៏បានបង្កើតព្រឹត្តិការណ៍ដ៏ធំមួយនេះក្នុងឆ្នាំ២០១៩ ជាថ្មីម្តងទៀត ដើម្បីបន្តការលើកកម្ពស់សម្លៀកបំពាក់ប្រពៃណីខ្មែរ ក្នុងរដូវបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ ដែលប្រព្រឹត្តទៅនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៩ នៅសាលពិព័ណ៌កោះពេជ្យ (អគារ I)។

ការចូលរួមចំណែកក្នុងសង្គម

ការឧបត្ថម្ភបង់អង្គុយជូនសាលាក្រុងតាខ្មៅ

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានឧបត្ថម្ភបង់អង្គុយថ្មដុសជូនសាលាក្រុងតាខ្មៅ ដើម្បីចូលរួមក្នុងវិស័យសាធារណៈសម្រាប់ការចូលរួមចំណែកក្នុងសង្គម និងការអភិវឌ្ឍន៍សហគមន៍។

គំនិតផ្តួចផ្តើមទាំងនេះ គឺជាផ្នែកមួយនៃការប្តេជ្ញាចិត្ត របស់ធនាគារចំពោះសង្គមដែរយើងកំពុងធ្វើប្រតិបត្តិការ។ ធនាគារក៏ជឿជាក់លើការរីកចម្រើនដែលយើងចង់ក្លាយជាផ្នែកមួយនៃសហគមន៍សម្រាប់និរន្តរភាពជ័យូរអង្វែង។

ការឧបត្ថម្ភបង់អង្គុយជូនសាលាស្រុកសំឡូត ខេត្តបាត់ដំបង

នាថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៩ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានធ្វើការឧបត្ថម្ភបង់អង្គុយជូនដល់សាលាស្រុកសំឡូតក្នុងការដាក់បម្រើជាប្រយោជន៍ដល់ប្រជាពលរដ្ឋតាមទីសាធារណៈ នៅតាមបណ្តាឃុំក្នុងស្រុកសំឡូត ខេត្តបាត់ដំបង។

ការបរិច្ចាកឈាមជូនមជ្ឈមណ្ឌលជាតិផ្តល់ឈាម

នាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ គណៈគ្រប់គ្រង រួមជាមួយបុគ្គលិកគ្រប់ជាន់ថ្នាក់នៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានបង្ហាញភាពក្លាហានក្នុងនាមជាអ្នកបរិច្ចាគឈាមដោយស្ម័គ្រចិត្ត ដើម្បីរួមចំណែកក្នុងការជួយសង្គ្រោះជីវិតជូនដល់ប្រជាពលរដ្ឋកម្ពុជា ដែលត្រូវការឈាមសម្រាប់ការសង្គ្រោះបន្ទាន់។ គណៈគ្រប់គ្រង និងបុគ្គលិកគ្រប់ជាន់ថ្នាក់នៃធនាគារពិតជាមានសេចក្តីពេញចិត្តជាខ្លាំងដែលបានធ្វើការផ្តល់ឈាមជូនដល់ជនរងគ្រោះដែលត្រូវការឈាមសម្រាប់ទ្រទ្រង់ជីវិត ដោយប្រកាន់នូវគោលជំហរថាការបរិច្ចាគឈាម គឺជាការជួយសង្គ្រោះជីវិត។

ការបរិច្ចាកសម្ភារៈប្រើប្រាស់ជូនក្រុមកីឡាករប្រណាំងទូកង ខេត្តឧត្តរមានជ័យ

នាឱកាសក្នុងការអបអរសាទរ ព្រះរាជពិធីបុណ្យអុំទូកនេះ នៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៩ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាខេត្តឧត្តរមានជ័យ បានចូលរួមជាមួយសាលាក្រុងសំរោង ក្រោមអធិបតីភាពដឹកនាំដោយលោក អ៊ុន សុភ័ក្រ្ត អភិបាលក្រុងសំរោង ដោយនាំយកអាវយឺតចំនួន ១០០ អាវ និងស្បោងបរិស្ថានចំនួន ១០០ ដល់សាលាក្រុងសំរោង ដើម្បីឧបត្ថម្ភដល់កីឡាករប្រណាំងទូកង សម្រាប់ការប្រើប្រាស់ក្នុងការប្រណាំងទូក។

ប្រវត្តិអតិថិជនជោគជ័យ

ប្រវត្តិជោគជ័យរបស់ម្ចាស់ចម្ការក្រូចរាប់ហិចតា និងហ្វាំរ៉ាស់សាំង ក្នុងខេត្តពោធិ៍សាត់

លោក វ៉ាន់ វ៉ន និងភរិយា លោកស្រី គង់ រី មានទីលំនៅបច្ចុប្បន្ន និងដីចម្ការក្រូច នៅក្នុងភូមិរវៀង ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ គាត់មានកូនស្រីចំនួន ៣នាក់។ ដោយសារតែកត្តាអំណោយផលពីធម្មជាតិដំណាំក្រូចអាចឱ្យផលបានរហូតដល់ ២ដងក្នុងមួយឆ្នាំ ហើយត្រូវបានប្រជាពលរដ្ឋស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ចាត់ទុកជាមុខរបរដែលអាចរកប្រាក់ចំណូល សម្រាប់ផ្គត់ផ្គង់គ្រួសារបាន។

ជាដំបូងគាត់បានប្រើប្រាស់កម្ចីពីធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ លើកដំបូង នៅខែធ្នូ ឆ្នាំ២០១៥ ក្នុងទំហំទឹកប្រាក់ ៣០,០០០ដុល្លារ ក្នុងគោលបំណងរៀបចំប្រព័ន្ធទឹកក្នុងចំការក្រូច។

ភោគផលដំណាំក៏កាន់តែកើនឡើង ទើបគាត់សម្រេចចិត្តប្រើប្រាស់កម្ចីជាលើកទី២ នាខែកក្កដា ឆ្នាំ២០១៧ ក្នុងទំហំទឹកប្រាក់ ១១,០០០ដុល្លារ សម្រាប់ទិញដីដាក់ដំណាំក្រូចរបស់គាត់។ ដំណាំក្រូចក៏កាន់តែមានតម្រូវការលើទីផ្សារ ទើបគាត់បានសម្រេចចិត្តខ្ចីប្រាក់ជាលើកទី៣ នាខែសីហា ឆ្នាំ២០១៩ ក្នុងទំហំទឹកប្រាក់ ៥០,០០០ដុល្លារ ដើម្បីទិញដីចម្ការដាំក្រូចបន្ថែម។

ក្រោយពីគាត់បានប្រើប្រាស់ឥណទានរបស់ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ រួចមក ជីវភាពរបស់ពួកគាត់កាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ដែលបានមកពីទុនដែលពួកគាត់ទទួលបានពីដំណាំក្រូចរបស់គាត់។

លោក និងភរិយាក៏អាចដំណើរការហ្វាំរ៉ាស់សាំងរបស់ពួកគាត់ប្រកបដោយប្រសិទ្ធភាព ជាមួយនឹងកំណើននៃចម្ការក្រូច ដែលធ្វើឲ្យអាជីវភាពពួកគាត់កាន់តែប្រសើរឡើង។

ពួកគាត់ក៏សូមថ្លែងអំណរគុណយ៉ាងជ្រៅចំពោះធនាគារ ដែលផ្តល់ឥណទានរបស់ ដែលបានផ្តល់ហិរញ្ញប្បទានក្នុងការជួយបំពេញនូវភាពរីកចម្រើននៃមុខរបរ របស់ពួកគាត់។

ប្រវត្តិជោគជ័យម្ចាស់ហាងលក់វត្ថុអនុស្សាវរីយ៍ដ៏ធំ ក្នុងខេត្តសៀមរាប

លោកស្រី ចាន់ សុខហេង អាយុ ២៨ឆ្នាំ និងស្វាមី លោកប៊ុន ពានរះ អាយុ ៣៨ឆ្នាំ បច្ចុប្បន្នស្វាមីលោកស្រីមានមុខរបរឡានដឹកភ្ញៀវទេសចរតាមប្រាសាទក្នុង និងក្រៅខេត្តសៀមរាប អស់រយៈពេល៩ឆ្នាំមកហើយ។ លោកមានកូនប្រុសចំនួន ០២នាក់ និងស្នាក់នៅជាមួយឪពុកម្តាយរបស់លោក។

លោកស្រីមានមុខរបរលក់វត្ថុអនុស្សាវរីយ៍ក្នុងផ្សាររាត្រី សៀមរាប អារត៏ សិនធ័រ ស្ថិតក្នុងភូមិវត្តដំណាក់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប។

លោកស្រីជាអតិថិជនស្មោះត្រង់របស់ធនាគារ ហើយលោកស្រីបានប្រើប្រាស់សេវាឥណទានជាមួយធនាគារ ចំនួន ០២លើករួចមកហើយ។ លើកទី១ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ លោកស្រីចាន់សុខហេងបានស្នើសុំខ្ចីចំនួន ២៥,០០០ដុល្លារ ដើម្បីទិញតូបចំនួន ០២ កន្លែង ដើម្បីលក់វត្ថុអនុស្សាវរីយ៍ និងលើកទី២ នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩ អតិថិជនបានស្នើសុំខ្ចីចំនួន ២៥,០០០ដុល្លារ ដើម្បីបង់ផ្តាច់កម្ចីចាស់ និងចំនួនសល់សម្រាប់ទិញតូប ០១ កន្លែងបន្ថែមក្នុងផ្សាររាត្រីសៀមរាប អារត៏ សិនធ័រ។ បន្ទាប់ពីទទួលបានសេវាឥណទានពីធនាគារ អាជីវកម្មរបស់គាត់ក៏មានការរីកចម្រើនធំធាត់បានល្អប្រសើជាងមុន ហើយជីវភាពគ្រួសាររបស់គាត់ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ។

បច្ចុប្បន្ននេះគាត់មានតូបលក់វត្ថុអនុស្សាវរីយ៍ចំនួន ០៣ ហើយដែលបានមកពីឥណទានរបស់ធនាគារ និងការខិតខំប្រឹងប្រែងរបស់ពួកគាត់។

សូមថ្លែងអំណរអគុណដល់ធនាគារដែលបានផ្តល់ ប្រាក់កម្ចីមកដល់រូបខ្ញុំបាទដើម្បីពង្រីកមុខរបរ និងទទួលបានការជោគជ័យដូចសព្វថ្ងៃ។

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ហិរញ្ញវត្ថុរួម
និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019
និង
របាយការណ៍របស់សវនករឯករាជ្យ

ព័ត៌មានអំពីធនាគារ	**ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ**	
ចុះបញ្ជីពាណិជ្ជកម្មលេខ	CO. 1794 ម/2013	
ទីស្នាក់ការចុះបញ្ជី	អគារលេខ 265-269 ផ្លូវអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា	
ភាគទុនិក	កាណាឌីយ៉ា អ៊ីនវេសមេន ហូលឌីង ក.អ Fullerton Financial Capital Pte. Ltd. ("Fullerton") ប្រៃសណីយ៍កម្ពុជា ប.ក	
ក្រុមប្រឹក្សាភិបាល	អ្នកឧកញ៉ា ពុង ឃាវសេ	ប្រធានក្រុមប្រឹក្សាភិបាល
	លោក Yeo Hong Ping	អនុប្រធានក្រុមប្រឹក្សាភិបាល (តែងតាំងនៅថ្ងៃទី 23 ខែ ធ្នូ ឆ្នាំ 2019)
	លោក. Gan Chee Yen	អនុប្រធានក្រុមប្រឹក្សាភិបាល (លាលែងពីតំណែងនៅថ្ងៃទី 30 កញ្ញា 2019)
	លោក រស់ ភីរុណ	អភិបាល
	លោកស្រី Pung Carolyne	អភិបាល
	លោក Neo Poh Kiat	អភិបាលឯករាជ្យមិនប្រតិបត្តិ
	លោក Giang Sovann	អភិបាលឯករាជ្យមិនប្រតិបត្តិ
	លោក Teo Meng Poh Philip	អភិបាលមិនប្រតិបត្តិ (តែងតាំងនៅថ្ងៃទី 14 ខែ មករា ឆ្នាំ 2019)
សវនករ	ខេភីអឹមជី ខេមបូឌា ចំកាត់	

មាតិកា ទំព័រ

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ៤២

របាយការណ៍របស់សវនករឯករាជ្យ ៤៥

របាយការណ៍ហិរញ្ញវត្ថុរួម៖ ៤៧
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម
- របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម
- របាយការណ៍ស្តីពីបម្រែបម្រួលមូលធនរួម
- របាយការណ៍លំហូរទឹកប្រាក់រួម

របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក៖ ៥០
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុដាច់ដោយឡែក
- របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗដាច់ដោយឡែក
- របាយការណ៍ស្តីពីបម្រែបម្រួលមូលធនដាច់ដោយឡែក
- របាយការណ៍លំហូរទឹកប្រាក់ដាច់ដោយឡែក

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានសេចក្តីរីករាយសូមដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ហៅកាត់ថា ("ធនាគារ") និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលតទៅនេះ ទាំងធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវហៅកាត់ថា ("សម្ព័ន្ធធនាគារ") និង របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក របស់ធនាគារសម្រាប់ការិយបរិច្ឆេទដែលបាន បញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ។

សកម្មភាពចម្បង

អំពីធនាគារ

សកម្មភាពចម្បងរបស់ធនាគារ រួមមានការផ្តល់សេវាប្រតិបត្តិការធនាគារនិងសេវាកម្មហិរញ្ញវត្ថុពាក់ព័ន្ធជាច្រើនទៀត តាមរយៈស្នាក់ការកណ្តាល និងសាខារបស់ធនាគារ នៅរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តនានា ។

ពុំមានការប្រែប្រួលដែលគួរឱ្យកត់សម្គាល់ នូវសកម្មភាពជាចម្បងរបស់ធនាគារក្នុងអំឡុងការិយបរិច្ឆេទនេះទេ ។

អំពីក្រុមហ៊ុនបុត្រសម្ព័ន្ធ

នៅថ្ងៃទី 11 ខែ មេសា ឆ្នាំ 2017 ធនាគារបានក្លាយម្ចាស់ជាកម្មសិទ្ធិ 100% របស់ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ដែលជាក្រុមហ៊ុនផ្តល់សេវាមីក្រូហិរញ្ញវត្ថុ ដើម្បីបង្កើនជីវភាពប្រជាពលរដ្ឋតាមរយៈទីស្នាក់ការកណ្តាលរបស់ខ្លួននៅ រាជធានីភ្នំពេញ និងសាខាតាមបណ្តាខេត្ត និងស្រុកមួយចំនួនទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារមានដូចខាងក្រោម៖

	2019 ដុល្លារអាមេរិក	2018 ដុល្លារអាមេរិក	2019 ពាន់រៀល	2018 ពាន់រៀល
សម្ព័ន្ធធនាគារ				
ប្រាក់ចំណេញមុនដកពន្ធ	2 5,888, 517	20,73 5,7 57	104,900,271	83,876,138
ចំណាយពន្ធលើប្រាក់ចំណេញ	(5,528,199)	(4,182,719)	(22,400,262)	(16,919,098)
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	20,360,318	16, 5 53,038	82, 500,009	66,9 57,040
ធនាគារ				
ប្រាក់ចំណេញមុនដកពន្ធ	22,174,36 5	17, 542,272	89,8 50, 528	70,9 58,491
ចំណាយពន្ធលើប្រាក់ចំណេញ	(4,551,838)	(3, 536,069)	(18,444,048)	(14,303,399)
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	17,622, 527	14,006,203	71,406,480	56,6 5 5,092

ភាគលាភ

ពុំមានការប្រកាស ឬការបែងចែកភាគលាភ ហើយក្រុមប្រឹក្សាភិបាលក៏ពុំមានអនុសាសន៍ ឱ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទនេះទេ ។

ដើមទុន

ដើមទុនរបស់សម្ព័ន្ធធនាគារ និងធនាគារ នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 មានចំនួន 76 លានដុល្លារអាមេរិក ឬ 304 ពាន់លានរៀល (31 ខែ ធ្នូ ឆ្នាំ 2018៖ 76 លានដុល្លារអាមេរិក ឬ 304 ពាន់លានរៀល) ។

ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុង របាយការណ៍ហិរញ្ញវត្ថុនេះ។

ឥណទាន និងបុរេប្រទាន

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាល បានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបបំបាត់ចោល ឥណទាន និងបុរេប្រទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទាន និងបុរេប្រទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលមានការជឿជាក់ថារាល់ឥណទាន និងបុរេប្រទានដែលបានដឹងថាមិនអាចទារបានត្រូវបាន លុបបំបាត់ចោល ហើយសំវិធានធនគ្រប់គ្រាន់ត្រូវបានកំណត់ឡើងសម្រាប់ឥណទាននិងបុរេប្រទានអាក្រក់ និង ជាប់សង្ស័យ ។

នាថ្ងៃចេញរបាយការណ៍នេះក្រុមប្រឹក្សាភិបាលពុំបានដឹងពីស្ថានភាពណាមួយដែលនឹងបណ្តាលឱ្យចំនួននៃការ លុបបំបាត់ចោលឥណទាន និងបុរេប្រទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនលើឥណទាន និងបុរេប្រទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានចំនួនខ្វះខាតជាសារវន្តនោះឡើយ ។

ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ សម្ព័ន្ធធនាគារនិងធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មចរន្តទាំងអស់ លើកលែងតែ បំណុលដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យ ហើយសន្និដ្ឋានថា មានតម្លៃមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃ ដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការ កំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារថាមានភាពមិនត្រឹមត្រូវនោះទេ។

វិធីសាស្រ្តវាយតម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ដែលធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្រ្តដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅ ក្នុងរបាយការណ៍ ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារថាមាន ភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ ។

បំណុលយថាហេតុ និងបំណុលផ្សេងៗទៀតនាថ្ងៃចេញរបាយការណ៍នេះពុំមាន៖

(ក) ការដាក់បញ្ចាំនូវទ្រព្យសកម្មណាមួយ របស់សម្ព័ន្ធធនាគារនិងធនាគារត្រូវបានធ្វើឡើងចាប់តាំងពីថ្ងៃចុង ការិយបរិច្ឆេទក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះសម្ព័ន្ធធនាគារ ឬធនាគារ ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទ មកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារឡើយ ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់សម្ព័ន្ធធនាគារ និង ធនាគារ ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេល ដប់ពីរខែបន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទដែលនឹងធ្វើឱ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់នោះទេ ។

ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញសភាពការណ៍ណាមួយដែលមិនបាន រែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលនឹងបណ្តាលឱ្យមានតួលេខនៃចំនួនណាមួយ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ ។

ប្រតិបត្តិការមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់សម្ព័ន្ធធនាគារនិងធនាគារក្នុង ការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុង ការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្តនិងមិនប្រក្រតីកើតមានឡើងដែលអាចនាំឱ្យប៉ះពាល់ដល់ លទ្ធផលនៃប្រតិបត្តិការរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

ការរំពឹងលើការបាត់បង់ឥណទាននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ2019 ត្រូវបានប៉ាន់ស្មានដោយផ្អែកលើស្ថានភាព សេដ្ឋកិច្ចដែលបានព្យាករណ៍នាកាលបរិច្ឆេទនោះ។ នាកាលបរិច្ឆេទបន្ទាប់មានការផ្ទុះឡើងនៃវីរុសកូរ៉ូណាបានរីករាលដាលពាសពេញប្រទេសចិន និងបណ្តាលប្រទេសដ៏ទៃទៀត ដែលបង្កឱ្យមានការរំខានដល់ សកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច។ ផលប៉ះពាល់លើកំណើនផលិតផលក្នុងស្រុកដុល (GDP) និងសូចនាករសំខាន់ផ្សេងៗ នឹងត្រូវបានពិចារណាក្នុងការកំណត់ភាពធ្ងន់ធ្ងរ និងភាពដែលអាចទៅរួចនៃការធ្លាក់ចុះនៃស្ថានភាពសេដ្ឋកិច្ច ដែលនឹងត្រូវបានប្រើប្រាស់ក្នុងការប៉ាន់ប្រមាណការរំពឹងទុកលើការខាតបង់ឥណទានក្រោម ស.រ.ហ.អ.ក 9 ក្នុងឆ្នាំ 2020 ។

ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលដែលបានបម្រើការក្នុង ការិយបរិច្ឆេទរាយការណ៍ និងនាថ្ងៃចេញរបាយការណ៍នេះ រួមមាន៖

អ្នកឧកញ៉ា ពុង ឃាវសែ	ប្រធានក្រុមប្រឹក្សាភិបាល
លោកYeo Hong Ping	អនុប្រធានក្រុមប្រឹក្សាភិបាល (តែងតាំងនៅថ្ងៃទី 23 ខែ ធ្នូ ឆ្នាំ 2019)
លោក រស់ ភីរុណ	អភិបាល
លោកស្រី Pung Carolyne	អភិបាល
លោក Neo Poh Kiat	អភិបាលឯករាជ្យ និងមិនប្រតិបត្តិ
លោក Giang Sovann	អភិបាលឯករាជ្យ និងមិនប្រតិបត្តិ
លោក Teo Meng Poh Philip	អភិបាលមិនប្រតិបត្តិ (តែងតាំងនៅថ្ងៃទី14 ខែ មករា ឆ្នាំ 2019)
លោក Gan Chee Yen	អនុប្រធានក្រុមប្រឹក្សាភិបាល (លាលែងនៅថ្ងៃទី 30 ខែ កញ្ញា ឆ្នាំ 2019)

ភាគហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

អ្នកឧកញ៉ា ពុង ឃាវសែ ប្រធានក្រុមប្រឹក្សាភិបាល និងជាភាគទុនិករបស់ ក្រុមហ៊ុន កាណាឌីយ៉ា អ៊ិនវេសមេន ហូលឌីង ក.អ ("កាណាឌីយ៉ា") និងជាភាគទុនិករបស់សម្ព័ន្ធធនាគារ និង ធនាគារ ។

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុង និងនាចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយដែលមានធនាគារជាគូភាគីមួយក្នុងគោល បំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់សម្ព័ន្ធធនាគារ និងធនាគារ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយ មធ្យោបាយទិញយកភាគហ៊ុននោះទេ ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុឆ្នាំកន្លងទៅ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលរបស់សម្ព័ន្ធធនាគារ និងធនាគារណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូល នៅក្នុងចំនួនបរិលាភសរុបទទួលបាន ឬដល់កំណត់ទទួលបាន ដោយសមាជិកក្រុមប្រឹក្សាភិបាលដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈកិច្ចសន្យាដែលធ្វើឡើងដោយសម្ព័ន្ធធនាគារ និងធនាគារ ដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុន ដែលក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅលើរបាយការណ៍ហិរញ្ញវត្ថុ ។

ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីចង្អុលបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(i) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាង សមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព ។

(ii) អនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“ស.រ.ទ.ហ.អ.ក”) ឬបើមានការផ្លាស់ប្តូរ ពីនេះដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ គឺត្រូវបង្ហាញនិងពន្យល់ឱ្យបានច្បាស់លាស់ និងកំណត់បរិមាណនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

(iii) ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ និងរក្សាទុកនូវបញ្ជី គណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព ។

(iv) វាយតម្លៃនូវលទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្មទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹង និរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការសម្ព័ន្ធធនាគារ និងធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ ។ និង

(v) ត្រួតពិនិត្យ និងដឹកនាំធនាគារឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងអស់ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវ បានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តរាល់តម្រូវការដូចបានរាយការណ៍ខាងលើ ក្នុងការរៀបចំរបាយការណ៍ ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ។

ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលបានភ្ជាប់មកជាមួយ ដែលជាមតិរបស់យើងខ្ញុំបានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាព ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ចុះហត្ថលេខាដោយយោងទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលៈ

អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ
ប្រធានក្រុមប្រឹក្សាភិបាល

លោក គួច ចៅចេក
ប្រធាននាយកប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៖

របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគទុនិកនៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរួម របស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ហៅកាត់ថា ("ធនាគារ") និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលតទៅនេះទាំងធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវហៅកាត់ថា ("សម្ព័ន្ធធនាគារ") និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ធនាគារ ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម និងដាច់ដោយឡែក នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងលំហូរទឹកប្រាក់រួម និងដាច់ដោយឡែក សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និង កំណត់សម្គាល់ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី 11 ដល់ទី 196 (ហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ") ។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរួម និងដាច់ដោយឡែករបស់សម្ព័ន្ធធនាគារ និងធនាគារ នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់សម្ព័ន្ធធនាគារ និងធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃ កម្ពុជា ("ស.រ.ទ.ហ.អ.ក") ។

មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("ស.គ.អ.ក") ។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។

យើងខ្ញុំ មានភាពឯករាជ្យពីសម្ព័ន្ធធនាគារ និងធនាគារ ដោយស្របទៅតាមតម្រូវការក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវលើក្រមសីលធម៌វិជ្ជាជីវៈ ស្របតាមតម្រូវការរបស់ស្តង់ដារទាំងនោះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

បញ្ហាផ្សេងៗ

ដូចបានបង្ហាញនៅក្នុងកំណត់សម្គាល់ 36 នៃរបាយការណ៍ហិរញ្ញវត្ថុសម្ព័ន្ធធនាគារ និងធនាគារបានអនុវត ស.រ.ទ.ហ.អ.ក នៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2019 ដែលមានកាលបរិច្ឆេទអន្តរកាល នៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ។ ស្តង់ដារទាំងនេះ គឺត្រូវអនុវត្តតាមវិធីសាស្ត្រប្រតិសកម្ម លើព័ត៌មានប្រៀបធៀបនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ រួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម និងដាច់ដោយឡែក នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និងថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ព្រមទាំងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍ស្តីពីបម្រែបម្រួលមូលធននិងរបាយការណ៍លំហូរទឹកប្រាក់រួម និងដាច់ដោយឡែក សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និងកំណត់ពន្យល់ពាក់ព័ន្ធផ្សេងៗ ។ យើងខ្ញុំ មិនតម្រូវឱ្យធ្វើសវនកម្មលើព័ត៌មានប្រៀបធៀប ដែលបានកែប្រែឡើងវិញឡើយ ហើយព័ត៌មានទាំងនេះ មិនត្រូវបានធ្វើសវនកម្មទេ ។ ការទទួលខុសត្រូវរបស់យើងខ្ញុំលើព័ត៌មានប្រៀបធៀបទាំងនេះ គឺត្រូវកំណត់ថាតើរបាយការណ៍ហិរញ្ញវត្ថុ បានរួមបញ្ចូលនូវ ព័ត៌មាន ប្រៀបធៀបដែលតម្រូវដោយ ស.រ.ទ.ហ.អ.ក និងថាតើព័ត៌មានប្រៀបធៀបទាំងនេះត្រូវបានធ្វើចំណាត់ ថ្នាក់សមស្របឬទេ។

ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលបានទទួលត្រឹមកាលបរិច្ឆេទ នៃរបាយការណ៍សវនកម្មនេះ គឺរបាយការណ៍របស់អ្នកគ្រប់គ្រង ដែលបានបង្ហាញនៅទំព័រទី1 ដល់ ទី 6 និង របាយការណ៍ប្រចាំឆ្នាំរបស់ធនាគារ ដែលរំពឹងថានឹងរួចរាល់ បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ ។ មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មាននេះទេ ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត ។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឱ្យយើងខ្ញុំ សន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាព ជាក់ស្តែង ។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ ។

ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាព របស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាព នៃគណនេយ្យ លើកលែងតែ អ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការសម្ព័ន្ធធនាគារ និង ធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់សម្ព័នធនាគារ និងធនាគារ ។

ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុគោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការ បង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលមតិសវនកម្មរបស់យើងខ្ញុំ ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែ

វាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវកាបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ ។ កាបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយម ក្នុងអំឡុងពេលសវនកម្ម ។

យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្មដើម្បីឆ្លើយតប ទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សម្រាប់ជា មូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្ត ដែលកើតឡើងដោយសារតែ ការក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពី កំហុសឆ្គងដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង ។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មក្នុងគោលបំណងដើម្បីរៀបចំនូវ នីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញ មតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់សម្ព័ន្ធធនាគារ និងធនាគារឡើយ ។
- ការវាយតម្លៃលើភាពសមស្រប នៃគោលនយោបាយគណនេយ្យដែលសម្ព័ន្ធធនាគារ និងធនាគារ បានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង ។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃ ការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់សារវន្ត ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឱ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារដើម្បីបន្តនិរន្តរភាពអាជីវកម្ម ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា ។ ការសន្និដ្ឋានរបស់យើងខ្ញុំគឺផ្អែកតាមភស្តុតាងសវនកម្មដែល ប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឱ្យធនាគារបញ្ឈប់និរន្តរភាព នៃអាជីវកម្ម ។
- វាយតម្លៃលើការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និង វាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ ។
- ទទួលបាននូវភស្តុតាងសវនកម្មដែលសមស្រប និងគ្រប់គ្រាន់ពាក់ព័ន្ធនឹងព័ត៌មានហិរញ្ញវត្ថុ សម្រាប់បណ្តាបុត្រសម្ព័ន្ធនៅក្នុងសម្ព័ន្ធធនាគារដើម្បីបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុរួម ។ យើងខ្ញុំទទួលខុសត្រូវក្នុងការដឹកនាំ ការត្រួតត្រាមើល និងការប្រត្តិបត្តិនៃសវនកម្មរបស់សម្ព័ន្ធធនាគារ។ យើងខ្ញុំ រក្សាការទទួលខុសត្រូវលើមតិសវនកម្មរបស់យើងខ្ញុំ ។

យើងខ្ញុំ ផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ស្តីពីបញ្ហាផ្សេងទៀតវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែលមានរួមបញ្ចូលទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម ។

តំណាងក្រុមហ៊ុន ខេភីអឹមជី ខេមបូឌា ចំកាត់

ង៉ែ ហ៊ុយ

Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 31 ខែ មីនា ឆ្នាំ 2020

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួមនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

		ថ្ងៃទី 31ខែធ្នូ		ថ្ងៃទី 31ខែធ្នូ		ថ្ងៃទី 1ខែមករា ឆ្នាំ 2018	
		ឆ្នាំ 2019	ឆ្នាំ2018	ឆ្នាំ 2019	ឆ្នាំ2018		
	កំណត់សម្គាល់	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)
ទ្រព្យសកម្ម							
សាច់ប្រាក់ក្នុងដៃ	6	25,158,725	19,223,992	102,521,804	77,242,000	17,613,161	71,104,331
ប្រាក់បញ្ញើនៅធនាគារនានា	7	52,179,640	169,270,270	212,632,033	680,127,945	128,667,834	519,432,046
ប្រាក់តម្កល់តាមច្បាប់	8	69,247,853	71,251,369	282,185,001	286,288,001	52,617,717	212,417,724
ឥណទាន និងបុរេប្រទាន ផ្តល់ដល់អតិថិជន សុទ្ធ	9	661,928,721	510,413,845	2,697,359,538	2,050,842,829	365,106,621	1,473,935,429
ទ្រព្យសកម្មផ្សេងៗ	10	1,525,391	1,220,802	6,215,968	4,905,182	705,710	2,848,951
ទ្រព្យសកម្មអរូបី	11	960,421	927,010	3,913,716	3,724,726	920,419	3,715,732
ទ្រព្យ និងបរិក្ខារ	12	4,230,499	3,044,922	17,239,283	12,234,497	2,898,731	11,702,177
សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	13	6,007,571	5,156,269	24,480,852	20,717,889	5,699,211	23,007,715
តម្លៃកេរ្តិ៍ឈ្មោះ	14	754,215	754,215	3,073,426	3,030,436	754,215	3,044,766
ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ	22	1,926,961	1,731,187	7,852,366	6,955,909	1,560,087	6,298,071
សរុបទ្រព្យសកម្ម		823,919,997	782,993,881	3,357,473,987	3,146,069,414	576,543,706	2,327,506,942
បំណុល និងមូលធនរបស់ភាគទុនិក							
បំណុល							
ប្រាក់បញ្ញើរបស់អតិថិជន	15	471,060,211	510,710,185	1,919,570,360	2,052,033,523	359,822,419	1,452,603,106
ប្រាក់បញ្ញើរបស់ធនាគារនានា	16	81,168,815	72,667,791	330,762,921	291,979,184	72,070,152	290,947,204
ប្រាក់កម្ចី	17	89,819,019	67,731,583	366,012,502	272,145,500	41,915,222	169,211,751
បំណុលបន្ទាប់បន្សំ	18	34,000,000	6,300,000	138,550,000	25,313,400	-	-
បំណុលភតិសន្យា	19	5,931,948	5,013,684	24,172,688	20,144,982	5,280,482	21,317,306
បំណុលផ្សេងៗ	20	19,820,196	19,634,474	80,767,298	78,891,318	15,044,261	60,733,682
សំវិធានធនសម្រាប់អត្ថប្រយោជន៍និយោជិត	21	410,049	666,900	1,670,950	2,679,604	111,874	451,635
បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ	22	4,784,108	3,703,931	19,495,240	14,882,395	2,287,001	9,232,623
សរុបបំណុល		706,994,346	686,428,548	2,881,001,959	2,758,069,906	496,531,411	2,004,497,307
មូលធនរបស់ភាគទុនិក							
ដើមទុន	23	76,000,000	76,000,000	304,093,780	304,093,780	70,790,000	283,160,000
ទុនបម្រុងតាមបទប្បញ្ញត្តិ	24	5,734,785	3,955,873	23,164,489	15,915,423	1,090,822	4,403,648
ប្រាក់ចំណេញរក្សាទុក		35,190,866	16,609,460	142,313,066	67,062,123	8,131,473	32,550,638
ទុនបម្រុងសម្រាប់ការប្តូររូបិយប័ណ្ណ		-	-	6,900,693	928,182	-	2,895,349
សរុបមូលធនរបស់ភាគទុនិក		116,925,651	96,565,333	476,472,028	387,999,508	80,012,295	323,009,635
សរុបបំណុល និងមូលធនរបស់ភាគទុនិក		823,919,997	782,993,881	3,357,473,987	3,146,069,414	576,543,706	2,327,506,942

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

	កំណត់សម្គាល់	2019 ដុល្លារអាមេរិក	2018 ដុល្លារអាមេរិក	2019 ពាន់រៀល (កំណត់សម្គាល់ 5)	2018 ពាន់រៀល (កំណត់ សម្គាល់ 5)
ចំណូលប្រតិបត្តិការ					
ចំណូលពីការប្រាក់	25	84,417,468	68,983,551	342,059,580	279,038,464
ចំណាយលើការប្រាក់	26	(37,111,532)	(30,600,228)	(150,375,928)	(123,777,922)
ចំណូលពីការប្រាក់សុទ្ធ		47,305,936	38,383,323	191,683,652	155,260,542
ចំណូលកម្រៃជើងសា	27	409,400	100,465	1,658,889	406,381
ចំណូលផ្សេងៗ	28	3,276,763	2,960,371	13,277,444	11,974,701
ប្រាក់ចំណេញប្រតិបត្តិការសរុប		50,992,099	41,444,159	206,619,985	167,641,624
ចំណាយលើបុគ្គលិក	29	(13,145,838)	(11,618,646)	(53,266,936)	(46,997,423)
ចំណាយប្រតិបត្តិការផ្សេងៗ	30	(9,005,217)	(7,842,800)	(36,489,139)	(31,724,126)
ចំណាយប្រតិបត្តិការសរុប		(22,151,055)	(19,461,446)	(89,756,075)	(78,721,549)
ប្រាក់ចំណេញប្រតិបត្តិការមុន ឱនភាពនៃតម្លៃ		28,841,044	21,982,713	116,863,910	88,920,075
ឱនភាពនៃតម្លៃខាតបង់លើ ឧបករណ៍ហិរញ្ញវត្ថុ	9	(2,952,527)	(1,246,956)	(11,963,639)	(5,043,937)
ប្រាក់ចំណេញមុនដកពន្ធ		25,888,517	20,735,757	104,900,271	83,876,138
ចំណាយពន្ធលើប្រាក់ចំណេញ	22	(5,528,199)	(4,182,719)	(22,400,262)	(16,919,098)
ប្រាក់ចំណេញសុទ្ធសម្រាប់ ការិយបរិច្ឆេទ		20,360,318	16,553,038	82,500,009	66,957,040
លទ្ធផលលម្អិតផ្សេងៗ					
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	-	5,972,511	(1,967,167)
លទ្ធផលលម្អិតសរុបសម្រាប់ ការិយបរិច្ឆេទ		**20,360,318**	**16,553,038**	**89,142,692**	**64,989,873**

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

របាយការណ៍ស្តីពីបម្រែបម្រួលមូលធនរួម
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

	ដើមទុន		ទុនបម្រុងតាមបទប្បញ្ញត្តិ		ប្រាក់ចំណេញរក្សាទុក		លម្អៀងពីការប្តូររូបិយប័ណ្ណ		សរុប	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)
សមតុល្យនាថ្ងៃទី 1 ខែមករា ឆ្នាំ 2018	70,790,000	283,160,000	1,090,822	4,403,648	8,131,473	32,550,638	-	2,895,349	80,012,295	323,009,635
ប្រតិបត្តិការដែលបានទទួលស្គាល់ដោយផ្ទាល់ នៅក្នុងមូលធន										
ផ្ទេរទៅដើមទុនធនាគារ	5,210,000	20,933,780	-	-	(5,210,000)	(20,933,780)	-	-	-	-
ផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅ ប្រាក់បម្រុងតាមបទប្បញ្ញត្តិ	-	-	2,865,051	11,511,775	(2,865,051)	(11,511,775)	-	-	-	-
លទ្ធផលលម្អិត										
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	-	-	-	-	16,553,038	66,957,040	-	-	16,553,038	66,957,040
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	(1,967,167)	-	(1,967,167)
សមតុល្យនាថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2018	76,000,000	304,093,780	3,955,873	15,915,423	16,609,460	67,062,123	-	928,182	96,565,333	387,999,508
សមតុល្យនាថ្ងៃទី 1 ខែមករា ឆ្នាំ 2019	76,000,000	304,093,780	3,955,873	15,915,423	16,609,460	67,062,123	-	928,182	96,565,333	387,999,508
ប្រតិបត្តិការដែលបានទទួលស្គាល់ ដោយផ្ទាល់ នៅក្នុង មូលធន										
ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅប្រាក់ បម្រុងតាមបទប្បញ្ញាតិ	-	-	1,778,912	7,249,066	(1,778,912)	(7,249,066)	-	-	-	-
លទ្ធផលលម្អិត										
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	-	-	-	-	20,360,318	82,500,009	-	-	20,360,318	82,500,009
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	5,972,511	-	5,972,511
សមតុល្យនាថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019	76,000,000	304,093,780	5,734,785	23,164,489	35,190,866	142,313,066	-	6,900,693	116,925,651	476,472,028

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍លំហូរទឹកប្រាក់រួម
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

	កំណត់សម្គាល់	2019 ដុល្លារអាមេរិក	2018 ដុល្លារអាមេរិក	2019 ពាន់រៀល (កំណត់សម្គាល់ 5)	2018 ពាន់រៀល (កំណត់សម្គាល់ 5)
លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ					
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ		20,360,318	16,553,038	82,500,009	66,957,040
និយ័តភាពលើ៖					
រំលស់លើទ្រព្យសកម្មរូបិយ និងអរូបិយ		3,641,925	3,189,813	14,757,080	12,902,794
ចំណេញពីការលក់ទ្រព្យនិងបរិក្ខារ		(12,769)	(60,957)	(51,740)	(246,572)
ចំណាយពន្ធលើប្រាក់ចំណេញ		5,528,199	4,182,719	22,400,262	16,919,098
សំវិធានលើឱនភាពនៃតម្លៃ		2,927,294	1,329,245	11,861,395	5,376,796
សំវិធានធនសម្រាប់អត្ថប្រយោជន៍និយោជិត		(256,851)	555,026	(1,040,760)	2,245,080
		32,188,116	25,748,884	130,426,246	104,154,236
បម្រែបម្រួលនៃ៖					
ប្រាក់បញ្ញើនៅធនាគារនានា		(260,886)	(133,836)	(1,063,110)	(545,382)
ឥណទាន និងបុរេប្រទាន		(154,442,170)	(146,636,469)	(629,351,843)	(589,185,332)
ប្រាក់តម្កល់តាមច្បាប់		2,003,516	(18,633,652)	8,164,328	(74,870,014)
ទ្រព្យសកម្មផ្សេងៗ		(304,589)	(515,092)	(1,241,200)	(2,069,640)
ប្រាក់បញ្ញើរបស់អតិថិជន		(39,649,974)	150,887,766	(161,573,644)	606,267,044
ប្រាក់បញ្ញើរបស់ធនាគារនានា		8,501,024	597,639	34,641,673	2,401,314
បំណុលផ្សេងៗ		1,103,986	4,323,415	4,498,743	17,371,481
សាច់ប្រាក់ទទួលបានពី/(ប្រើប្រាស់ក្នុង)ប្រតិបត្តិការ		(150,860,977)	15,638,655	(615,498,807)	63,523,707
ពន្ធលើប្រាក់ចំណេញបានបង់		(4,643,796)	(2,936,889)	(18,816,661)	(11,879,716)
សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ		(155,504,773)	12,701,766	(634,315,468)	51,643,991
លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ					
ការទិញទ្រព្យនិងបរិក្ខារនិងទ្រព្យសកម្មអរូបី	10	(3,126,744)	(1,839,912)	(12,669,567)	(7,442,444)
សាច់ប្រាក់បានពីការលក់ទ្រព្យនិងបរិក្ខារ		29,882	95,231	121,082	385,209
សាច់ប្រាក់ប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ		(3,096,862)	(1,744,681)	(12,548,485)	(7,057,235)
លំហូរទឹកប្រាក់ទទួលបានពីសកម្មភាពហិរញ្ញប្បទាន					
សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី		37,064,551	26,811,881	150,185,561	108,454,059
ការទូទាត់សងប្រាក់កម្ចី		(14,977,115)	(995,520)	(60,687,270)	(4,026,878)
សាច់ប្រាក់ទទួលបានពីបំណុលបន្ទាប់បន្សំ		27,700,000	6,300,000	112,240,400	25,483,500
ការទូទាត់បំណុលភតិសន្យា		(2,602,584)	(994,015)	(10,545,670)	(4,020,791)
សាច់ប្រាក់ប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន		47,184,852	31,122,346	191,193,021	125,889,890
(ការថយចុះ)/កើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល		(111,416,783)	42,079,431	(455,670,932)	170,476,646
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ		188,510,410	146,430,979	757,434,827	591,141,862
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	-	12,392,635	(4,183,681)
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ	6	**77,093,627**	**188,510,410**	**314,156,530**	**757,434,827**

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុដាច់ដោយឡែក
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

		ថ្ងៃទី 31ខែធ្នូ		ថ្ងៃទី 31ខែធ្នូ		ថ្ងៃទី 1ខែមករា ឆ្នាំ 2018	
	កំណត់សម្គាល់	ឆ្នាំ 2019 ដុល្លារអាមេរិក	ឆ្នាំ2018 ដុល្លារអាមេរិក	ឆ្នាំ 2019 ពាន់រៀល (កំណត់សម្គាល់ 5)	ឆ្នាំ2018 ពាន់រៀល (កំណត់សម្គាល់ 5)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)
ទ្រព្យសកម្ម							
សាច់ប្រាក់ក្នុងដៃ	6	24,813,127	18,934,494	101,113,493	76,078,797	17,445,018	70,425,538
ប្រាក់បញ្ញើនៅធនាគារនានា	7	51,442,981	169,028,908	209,630,148	679,158,152	126,840,708	512,055,938
ប្រាក់តម្កល់តាមច្បាប់	8	68,847,853	70,851,369	280,555,001	284,680,801	52,217,717	210,802,924
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនសុទ្ធ	9	606,971,782	464,005,091	2,473,410,012	1,864,372,456	337,318,052	1,361,752,976
ទ្រព្យសកម្មផ្សេងៗ	10	1,279,231	1,018,778	5,212,866	4,093,449	619,838	2,502,285
ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ		8,685,818	8,685,818	35,394,708	34,899,617	8,685,818	35,064,647
ទ្រព្យសកម្មអរូបី	11	854,876	784,756	3,483,620	3,153,150	748,863	3,023,160
ទ្រព្យនិងបរិក្ខារ	12	3,631,392	2,815,384	14,797,922	11,312,213	2,708,293	10,933,379
សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	13	4,614,191	4,476,878	18,802,828	17,988,096	5,023,823	20,281,173
ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ	22	1,803,309	1,466,811	7,348,484	5,893,647	1,300,726	5,251,031
សរុបទ្រព្យសកម្ម	ស	**772,944,560**	**742,068,287**	**3,149,749,082**	**2,981,630,378**	**552,908,856**	**2,232,093,051**
បំណុល និងមូលធនរបស់ភាគទុនិក							
បំណុល							
ប្រាក់បញ្ញើរបស់អតិថិជន	15	471,597,891	510,710,185	1,921,761,406	2,052,033,523	359,822,419	1,452,603,106
ប្រាក់បញ្ញើរបស់ធនាគារនានា	16	81,168,815	72,752,693	330,762,921	292,320,320	72,103,410	291,081,466
ប្រាក់កម្ចី	17	49,220,859	31,039,821	200,575,000	124,718,001	19,000,000	76,703,000
បំណុលបន្ទាប់បន្សំ	18	31,000,000	6,300,000	126,325,000	25,313,400	-	-
បំណុលភតិសន្យា	19	4,633,170	4,429,827	18,880,168	17,799,045	4,701,390	18,979,511
បំណុលផ្សេងៗ	20	18,941,161	18,854,628	77,185,232	75,757,897	14,726,070	59,449,145
សំវិធានធនសម្រាប់អត្ថប្រយោជន៍និយោជិត	21	356,525	500,171	1,452,839	2,009,687	-	-
បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ	22	4,067,233	3,144,583	16,573,974	12,634,934	2,225,391	8,983,903
សរុបបំណុល		660,985,654	647,731,908	2,693,516,540	2,602,586,807	472,578,680	1,907,800,131
មូលធនរបស់ភាគទុនិក							
ដើមទុន	23	76,000,000	76,000,000	304,093,780	304,093,780	70,790,000	283,160,000
ទុនបម្រុងតាមបទប្បញ្ញត្តិ	24	5,384,020	3,598,243	21,755,507	14,478,466	1,090,822	4,403,647
ប្រាក់ចំណេញរក្សាទុក		30,574,886	14,738,136	123,885,975	59,756,536	8,449,354	34,110,042
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	-	6,497,280	714,789	-	2,619,231
សរុបមូលធនរបស់ភាគទុនិក		111,958,906	94,336,379	456,232,542	379,043,571	80,330,176	324,292,920
សរុបបំណុល និងមូលធនរបស់ភាគទុនិក		772,944,560	742,068,287	3,149,749,082	2,981,630,378	552,908,856	2,232,093,051

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ
របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

	កំណត់សម្គាល់	2019 ដុល្លារអាមេរិក	2018 ដុល្លារអាមេរិក	2019 ពាន់រៀល (កំណត់សម្គាល់ 5)	2018 ពាន់រៀល (កំណត់សម្គាល់ 5)
ចំណូលប្រតិបត្តិការ					
ចំណូលពីការប្រាក់	25	72,304,870	58,801,878	292,979,333	237,853,597
ចំណាយលើការប្រាក់	26	(34,003,111)	(28,051,516)	(137,780,606)	(113,468,382)
ចំណូលពីការប្រាក់សុទ្ធ		38,301,759	30,750,362	155,198,727	124,385,215
ចំណូលកម្រៃជើងសារ	27	409,400	100,465	1,658,889	406,381
ចំណូលផ្សេងៗ	28	2,901,438	2,568,143	11,756,627	10,388,138
ចំណូលប្រតិបត្តិការផ្សេងៗ		41,612,597	33,418,970	168,614,243	135,179,734
ចំណាយលើបុគ្គលិក	29	(10,014,641)	(8,267,665)	(40,579,325)	(33,442,705)
ចំណាយប្រតិបត្តិការផ្សេងៗ	30	(6,816,725)	(6,121,944)	(27,621,369)	(24,763,263)
ចំណាយលើប្រតិបត្តិការសរុប		(16,831,366)	(14,389,609)	(68,200,694)	(58,205,968)
ចំណេញពីប្រតិបត្តិការមុនឱនភាពនៃតម្លៃ		24,781,231	19,029,361	100,413,549	76,973,766
សំវិធានធនលើការខាតបង់លើ ឱនភាពនៃ តម្លៃឧបករណ៍ហិរញ្ញវត្ថុ	9	(2,606,866)	(1,487,089)	(10,563,021)	(6,015,275)
ប្រាក់ចំណេញមុនដកពន្ធ		22,174,365	17,542,272	89,850,528	70,958,491
ចំណាយពន្ធលើប្រាក់ចំណេញ	22	(4,551,838)	(3,536,069)	(18,444,048)	(14,303,399)
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ		17,622,527	17,622,527	14,006,203	71,406,480
លទ្ធផលលម្អិតផ្សេងៗ					
ទុនបម្រុងលើការប្តូររូបិយប័ណ្ណ		-	-	5,782,491	(1,904,442)
លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ		17,622,527	14,006,203	77,188,971	54,750,650

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
របាយការណ៍ស្តីពីបម្រែបម្រួលមូលធនដាច់ដោយឡែក
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

	ដើមទុន		ទុនបម្រុងតាមបទប្បញ្ញត្តិ		ប្រាក់ចំណេញរក្សាទុក		លម្អៀងពីការប្តូររូបិយប័ណ្ណ		សរុប	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)
សមតុល្យនាថ្ងៃទី 1ខែមករា ឆ្នាំ 2018	70,790,000	283,160,000	1,090,822	4,403,647	8,449,354	34,110,042	-	2,619,231	80,330,176	324,292,920
ប្រតិបត្តិការដែលបានទទួលស្គាល់ដោយផ្ទាល់ នៅក្នុងមូលធន										
ផ្ទេរទៅដើមទុនធនាគារ	5,210,000	20,933,780	-	-	(5,210,000)	(20,933,780)	-	-	-	-
ផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅប្រាក់បម្រុងតាមបទប្បញ្ញត្តិ	-	-	2,507,421	10,074,818	(2,507,421)	(10,074,818)	-	-	-	-
លទ្ធផលលម្អិត										
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	-	-	-	-	14,006,203	56,655,092	-	-	14,006,203	56,655,092
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-		-	(1,904,442)	-	(1,904,442)
សមតុល្យនាថ្ងៃទី 31ខែធ្នូ ឆ្នាំ 2018	76,000,000	304,093,780	3,598,243	14,478,466	14,738,136	59,756,536	-	714,789	94,336,379	379,043,571
សមតុល្យនាថ្ងៃទី 1ខែមករាឆ្នាំ 2019	76,000,000	304,093,780	3,598,243	14,478,466	14,738,136	59,756,536	-	714,789	94,336,379	379,043,571
ប្រតិបត្តិការដែលបានទទួលស្គាដោយផ្ទាល់នៅក្នុងមូលធន										
ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅប្រាក់បម្រុងតាមបទប្បញ្ញាតិ	-	-	1,785,777	7,277,041	(1,785,777)	(7,277,041)	-	-	-	-
លទ្ធផលលម្អិត										
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	-	-	-	-	17,622,527	71,406,480	-	-	17,622,527	71,406,480
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	5,782,491	-	5,782,491
សមតុល្យនាថ្ងៃទី 31ខែធ្នូ ឆ្នាំ 2019	76,000,000	304,093,780	5,384,020	21,755,507	30,574,886	123,885,975	-	6,497,280	111,958,906	456,232,542

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
របាយការណ៍លំហូរទឹកប្រាក់ដាច់ដោយឡែក
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

	កំណត់សម្គាល់	2019 ដុល្លារអាមេរិក	2018 ដុល្លារអាមេរិក	2019 ពាន់រៀល (កំណត់សម្គាល់ 5)	2018 ពាន់រៀល (កំណត់សម្គាល់ 5)
លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ					
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ		17,622,527	14,006,203	71,406,480	56,655,092
និយ័តកម្មលើ៖					
រំលស់		2,928,182	2,564,581	11,864,993	10,373,730
ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ		(12,768)	(50,251)	(51,736)	(203,265)
ចំណាយពន្ធលើប្រាក់ចំណេញ		4,551,838	3,536,069	18,444,048	14,303,399
សំវិធានធនលើការបាត់បង់ ឱនភាពនៃម្លៃ		2,581,633	1,569,378	10,460,777	6,348,134
សំវិធានធនសម្រាប់អត្ថប្រយោជន៍និយោជិត		(143,646)	500,171	(582,054)	2,023,192
		27,527,766	22,126,151	111,542,508	89,500,282
បម្រែបម្រួលនៃ៖					
ប្រាក់បញ្ញើនៅធនាគារនានា		(272,007)	(82,289)	(1,108,429)	(335,328)
ឥណទាន និងបុរេប្រទាន		(145,548,324)	(128,256,417)	(593,109,420)	(515,334,284)
ប្រាក់តម្កល់តាមច្បាប់		2,003,516	(18,633,652)	8,164,328	(74,870,014)
ទ្រព្យសកម្មផ្សេងៗ		(260,453)	(398,940)	(1,061,346)	(1,602,941)
ប្រាក់បញ្ញើរបស់អតិថិជន		(39,112,294)	150,887,766	(159,382,598)	606,267,044
ប្រាក់បញ្ញើរបស់ធនាគារនានា		8,416,122	649,283	34,295,697	2,608,819
បំណុលផ្សេងៗ		289,876	3,856,995	1,181,245	15,497,406
សាច់ប្រាក់ទទួល(ប្រើប្រាស់ក្នុង)ប្រតិបត្តិការ		(146,955,798)	30,148,897	(599,478,015)	121,730,984
ពន្ធលើប្រាក់ចំណេញបានបង់		(3,965,686)	(2,782,962)	(16,068,960)	(11,257,081)
សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ		(150,921,484)	27,365,935	(615,546,975)	110,473,903
លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ					
ការទិញទ្រព្យ និងបរិក្ខារនិងទ្រព្យសកម្មអរូបី		(2,590,766)	(1,634,633)	(10,497,784)	(6,612,090)
សាច់ប្រាក់បានពីការលក់ទ្រព្យ និងបរិក្ខារ		29,882	80,588	121,082	325,978
សាច់ប្រាក់ប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ		(2,560,884)	(1,554,045)	(10,376,702)	(6,286,112)
លំហូរទឹកប្រាក់ទទួលបានពីសកម្មភាពហិរញ្ញប្បទាន					
សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី		31,181,038	12,039,821	126,345,566	48,701,076
ការទូទាត់សងប្រាក់កម្ចី		(13,000,000)	-	(52,676,000)	-
សាច់ប្រាក់ទទួលបានពីបំណុលបន្ទាប់បន្សំ		24,700,000	6,300,000	100,084,400	25,483,500
ចំណាយបំណុលភតិសន្យា		(1,377,971)	(556,324)	(5,583,538)	(2,250,331)
សាច់ប្រាក់ប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន		41,503,067	17,783,497	168,170,428	71,934,245
ការថយចុះ/កើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល		(111,979,301)	43,595,387	(457,753,249)	176,122,036
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ		187,975,711	144,380,324	755,286,407	582,863,368
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	-	12,152,213	(3,698,997)
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ	6	75,996,410	187,975,711	309,685,371	755,286,407

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ
កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

១. អំពីធនាគារ

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ហៅកាត់ថា ("ធនាគារ") និងក្រុមហ៊ុន បុត្រសម្ព័ន្ធ ដែលតទៅនេះទាំងធនាគារនិងក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវ ហៅកាត់ថា ("សម្ព័ន្ធធនាគារ")ជាក្រុមហ៊ុនដែលបានបង្កើតឡើង និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ធនាគារ

ធនាគារ ជាធនាគារពាណិជ្ជដែលធ្វើអាជីវកម្ម ដោយអនុលោមទៅតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា និង តាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា និងអនុលោមតាមអាជ្ញាប័ណ្ណលេខ 38 ដែលបានផ្តល់ដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី 20 ខែ កញ្ញា ឆ្នាំ 2013 ។

ភាគទុនិកសំខាន់ៗរបស់ធនាគារ រួមមាន កាណាឌីយ៉ា អ៊ិនវេសមេនហូលឌីង ក.អ ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និង Fullerton Financial Capital Pte. Ltd. ("Fullerton") ជាក្រុមហ៊ុនបង្កើតនៅសឹង្ហបុរី ។

សកម្មភាពចម្បងរបស់ធនាគារ រួមមានការផ្តល់សេវាប្រតិបត្តិការធនាគារ និងសេវាកម្មហិរញ្ញវត្ថុពាក់ព័ន្ធជាច្រើនទៀតតាមរយៈស្នាក់ការកណ្តាល និងសាខារបស់ធនាគារនៅរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្ត នានា ។

ទីស្នាក់ការចុះបញ្ជីរបស់ធនាគារបច្ចុប្បន្នមានទីតាំងស្ថិតនៅអគារលេខ 265-269 ផ្លូវអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ធនាគារមានសាខាចំនួន 51សាខា ដែលមានទីតាំងនៅទីក្រុងភ្នំពេញ និងតាមបណ្តាខេត្តធំៗនៃព្រះរាជាណាចក្រកម្ពុជា។

ពុំមានការប្រែប្រួលដែលគួរឱ្យកត់សម្គាល់ នូវសកម្មភាពជាចម្បងរបស់ ធនាគារក្នុងអំឡុងការិយបរិច្ឆេទនេះទេ ។

ដើមទុនដែលបានបង់របស់ធនាគារ គិតត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ2019 មានចំនួន 76,000,000 ដុល្លារអាមេរិក (2018: 76,000,000 ដុល្លារអាមេរិក) ។

នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ក្រុមហ៊ុនមានបុគ្គលិកចំនួន 1,585 នាក់ (2018: 1,441 នាក់) ។

ក្រុមហ៊ុនបុត្រសម្ព័ន្ធ

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ (ក្រុមហ៊ុនបុត្រសម្ព័ន្ធ") ។ ក្រុមហ៊ុនបុត្រសម្ព័ន្ធ មានសាខា ចំនួន 51 នៅជុំវិញប្រទេសកម្ពុជា ដែលផ្តល់ប្រាក់កម្ចីខ្នាតតូច និងមធ្យម ។

ក្រុមហ៊ុនបុត្រសម្ព័ន្ធ នេះត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជា ហើយបានចុះបញ្ជីជាមួយក្រសួង ពាណិជ្ជកម្ម ជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតក្រោមបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនលេខ2133**KH**2015 ដែលបានចុះនៅថ្ងៃទី17 ខែ មិថុនា ឆ្នាំ 2015 ។

២. មូលដ្ឋាននៃគណនេយ្យ

របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារ របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហៅកាត់ថា ("ស.រ.ទ.ហ.អ.ក")។ នេះគឺជារបាយការណ៍ហិរញ្ញវត្ថុលើកដំបូងរបស់សម្ព័ន្ធធនាគារ និងធនាគារដែលត្រូវបានរៀបចំឡើងដោយអនុលោមទៅតាម ("ស.រ.ហ.អ.ក") ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ("ស.រ.ទ.ហ.អ.ក") អន្តរជាតិនៃកម្ពុជា 1 ការអនុវត្តដំបូងនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

